# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ
# ជាសាធារណៈលើកដំបូងរបស់
# ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ប្រាក់ ពុទ្ធានី**

**លោក លាង សេងហ៊ុយ**

ណែនាំដោយ

**លោកស្រី ហេង ច័ន្ទបូលីន**


ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ
# ជាសាធារណៈលើកដំបូងរបស់
# ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា ប្រាក់ ពុទ្ធានី**
**លោក លាង សេងហ៊ុយ**

ណែនាំដោយ
**លោកស្រី ហេង ច័ន្ទបូលីន**


ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរដែលរួមមាន ប្រាក់ ពុទ្ធានី និង លាង សេងហ៊ុយ ជានិស្សិតឆ្នាំទី៤ ជំនាន់ទី១៧ នៃថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២៣-២០២៤៖

យើងខ្ញុំទាំងពីរនាក់ ពិតជាមានសេចក្តីសោមនស្ស និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក និងអ្នកម្តាយ របស់យើងខ្ញុំទាំងពីរនាក់ ដែលបានផ្តល់កំណើត បង្ហាត់បង្រៀន ចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំតាំងពីតូច រហូតមកដល់ពេលនេះ ដោយលោកទាំងពីរបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការមើលថែ អប់រំ ប្រៀនប្រដៅ ទំនុកបម្រុងសព្វគ្រប់បែបយ៉ាង ដើម្បីឱ្យកូនៗបានសិក្សាមានចំណេះដឹងខ្ពង់ខ្ពស់រហូតចប់ចុងចប់ដើម និងដើម្បីយកទៅប្រើប្រាស់សម្រាប់ចិញ្ចឹមជីវិតនៅពេលខាងមុខ។ យើងខ្ញុំទាំងពីរនាក់ សូមក្រាបប្រណិបត្តិ និងសំដែងកត្តញ្ញូតាធម៌ចំពោះលោកអ្នកមានគុណ និងសូមបួងសួង និងជូនពរលោកទាំងបួនឱ្យមានសេចក្តីសុខចម្រើន អាយុយឺនយូរ និងសុខភាពមាំមួន។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ បុគ្គលិកនៃសាកលវិទ្យាល័យ ដែលបានជួយជ្រោមជ្រែងដល់យើងខ្ញុំឱ្យសម្រេចក្នុងការធ្វើកិច្ចការនានាទៅបានយ៉ាងរលូន។

លោកស្រី ហេង ច័ន្ទបូលីន ដែលបានណែនាំក្នុងកិច្ចការស្រាវជ្រាវមួយនេះ។ លោកស្រីបានផ្តល់នូវបច្ចេកទេសក្នុងការសរសេរ ផ្តល់ជាគំនិត មតិយោបល់ល្អៗ កែតម្រូវនូវកំហុសឆ្គងទាំងឡាយ ដែលបានកើតឡើងនៅក្នុងដំណើរការនៃការសរសេរសារណាមួយនេះ តាំងពីដើមរហូតដល់ចប់។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមជូនពរដល់អ្នកមានគុណទាំងអស់រួមមាន លោកឪពុក អ្នកម្តាយ សាស្រ្តាចារ្យណែនាំ សិស្សច្បងនិស្សិត ព្រមទាំងមិត្តនិស្សិតទាំងអស់ ឱ្យជួបតែសេចក្តីសុខចម្រើន សុខភាពមាំមួន សំណាងល្អ ជោគជ័យគ្រប់ភារកិច្ច និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ  វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាំងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី១៧ ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា២០២៣-២០២៤ ទទួលបានឱកាសក្នុងការធ្វើការស្រាវជ្រាវ និងចងក្រងសារណានេះឡើងក្នុងគោលបំណងជាសមិទ្ធិផលចុងក្រោយនៃការបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរ ជាមួយនឹងចំណេះដឹងដែលបានសិក្សាអស់រយៈពេល ៤ ឆ្នាំ នៃថ្នាក់បរិញ្ញាបត្រកន្លងមកនេះ។

ដោយឃើញថាវិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជា ជាវិស័យមួយដែលមានសក្តានុពលដែលអាចជួយឱ្យប្រទេសជាតិមួយមានការអភិវឌ្ឍ ដូច្នេះហើយយើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសយកប្រធានបទស្តីពី « **ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក** » សម្រាប់ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមួយនេះ។ នេះគឺជាគំនិតស្តួចស្តើងមួយដែលលេចឡើងជារូបរាង ដោយសារការខិតខំប្រឹងប្រែងរបស់ក្រុមយើងខ្ញុំ និងការដឹកនាំកែលំអពីសំណាក់លោកស្រី ហេង ច័ន្ទបូលីន ដែលនឹងអាចជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗ ទុកជាគំរូឯកសារក្នុងការសិក្សាស្រាវជ្រាវបន្តទៀត និងក្លាយជាផ្នែកមួយក្នុងការជម្រុញឱ្យមានការចាប់អារម្មណ៍ទៅលើការជួញដូរមូលបត្រនៅក្នុងប្រទេសកម្ពុជា។

សារណានេះនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេតែទោះជាយ៉ាងណា យើងខ្ញុំសង្ឃឹមថា សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់នឹងមានការអធ្យាស្រ័យនូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា ហើយយើងខ្ញុំទាំងពីរនឹងទទួលនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងអស់ដែលជាទុនក្នុងការកែលម្អសារណារបស់យើងខ្ញុំឱ្យកាន់តែប្រសើរឡើង។

# មាតិកា


ទំព័រ

បញ្ជីអក្សរកាត់......................................................................................................... vi

បញ្ជីតារាង .............................................................................................................vii

បញ្ជីរូបភាព ...........................................................................................................viii

បញ្ជីក្រាប.............................................................................................................viii


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ....................................................................................... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..................................................................................... ១

៣. គោលបំណងនៃការស្រាវជ្រាវ .......................................................................................២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ..............................................................................២

៥. សារៈសំខាន់នៃការស្រាវជ្រាវ.......................................................................................៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ..........................................................................................៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ....................................................................................... ៤


## ជំពូកទី១
## រំលឹកទ្រឹស្តី


១.១. ទីផ្សារមូលបត្រ ........................................................................................................ ៦

១.១.១. និយមន័យ ......................................................................................................... ៦

១.១.២. តួនាទីនៃទីផ្សារមូលបត្រ.......................................................................................... ៦

១.២. ប្រភេទមូលបត្រ......................................................................................................... ៦

១.២.១. មូលបត្រកម្មសិទ្ធិ .................................................................................................. ៦

១.២.២. មូលបត្របំណុល......................................................................................................៧

១.២.៣. ឧបករណ៍និស្សន្ទ...................................................................................................... ៨

១.៣. ប្រភេទនៃទីផ្សារមូលបត្រ.............................................................................................. ៨

១.៣.១. ទីផ្សារដំបូង (Primary Market) ............................................................................... ៨

១.៣.២. ទីផ្សារបន្ទាប់ (Secondary Market)........................................................................... ៨

១.៤. តួអង្គសំខាន់ៗដែលចូលរួមក្នុងការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារមូលបត្រកម្ពុជា ........................ ៨
១.៤.១. និយ័តករមូលបត្រកម្ពុជា ........................ ៨
១.៤.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................ ៩
១.៤.៣. ក្រុមហ៊ុនមូលបត្រ ........................ ១០
១.៤.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រ ........................ ១១
១.៤.៥. ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ........................ ១៣
១.៤.៦. ក្រុមហ៊ុនផ្តល់សេវាបកប្រែ ........................ ១៤
១.៤.៧. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ........................ ១៤
១.៤.៨. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ........................ ១៨
១.៤.៩. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធមូលបត្រ ........................ ១៩
១.៤.១០. ភ្នាក់ងារបញ្ជីកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ........................ ១៩
១.៤.១១. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ........................ ២១
១.៥. លក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ........................ ២២
១.៥.១. លក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ........................ ២៣
១.៥.២. លក្ខខណ្ឌតម្រូវដើម្បីចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ........................ ២៣
១.៦. យន្តការក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងក្នុងទីផ្សារមូលបត្រកម្ពុជា ........................ ២៥
១.៧. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ ........................ ២៨
១.៧.១. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន ........................ ២៨
១.៧.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ ........................ ២៩
១.៧.៣. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ ........................ ៣០

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

២.១. ប្រវត្តិក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ........................ ៣២
២.២. បេសកកម្ម ចក្ខុវិស័យនិងគុណតម្លៃស្នូលរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ........................ ៣៤
២.២.១. បេសកកម្មរបស់ក្រុមហ៊ុន ........................ ៣៤

២.២.២. ចក្ខុវិស័យរបស់ក្រុមហ៊ុន ........ ៣៤
២.២.៣. គុណតម្លៃស្នូលរបស់ក្រុមហ៊ុន ........ ៣៤
២.៣. រចនាសម្ព័ន្ធ និងព័ត៌មានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ........ ៣៥
២.៣.១. រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ........ ៣៥
២.៣.២. ព័ត៌មានក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ........ ៣៦
២.៤. អត្ថប្រយោជន៍ប្រកួតប្រជែង ផែនការអនាគត និងយុទ្ធសាស្ត្រអាជីវកម្ម ........ ៣៦
២.៤.១. អត្ថប្រយោជន៍ប្រកួតប្រជែង ........ ៣៦
២.៤.២. ផែនការអនាគត និងយុទ្ធសាស្ត្រអាជីវកម្ម ........ ៣៧
២.៤.៣. ការប្រកួតប្រជែងក្នុងទីផ្សារ ........ ៣៨
២.៥. ប៉ាតង់ សញ្ញាសម្គាល់ ឈ្មោះពាណិជ្ជកម្ម អាជ្ញាប័ណ្ណ និង/ឬកិច្ចព្រមព្រៀងផ្សេងទៀតស្តីពីសិទ្ធិកម្មសិទ្ធិបញ្ញា ........ ៣៩
២.៦. ផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន ........ ៤១
២.៦.១. សាលារៀន អន្តរទ្វីប អាមេរិកាំង "AIS" ........ ៤១
២.៦.២. មជ្ឈមណ្ឌលភាសា អេ អាយ អាយ "Aii" ........ ៤២
២.៦.៣. សេវាកម្មផ្សេងៗទៀតរបស់សាលា ........ ៤៣
២.៧. បណ្ដាញនៃសាខាសាលារៀនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ........ ៤៩
២.៨. កត្តាហានិភ័យ ........ ៥៦
២.៩. ការគ្រប់គ្រងហានិភ័យ ........ ៥៧

## ជំពូកទី៣
## ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

៣.១. ព័ត៌មានក្រុមហ៊ុននៃក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង ........ ៥៩
៣.១.១. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ........ ៥៩
៣.១.២. ក្រុមហ៊ុនធានាទិញមូលបត្រ ........ ៥៩
៣.១.៣. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ ........ ៦២
៣.១.៤. ក្រុមហ៊ុនសេវាកម្មផ្នែកច្បាប់ ........ ៦៣

៣.១.៥. ភាគរយនៃផាប់ប្លិកហ្លូត និងឡុកអាប់ ............ ៦៣
៣.២. ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ............ ៦៥
៣.២.១. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ............ ៦៥
៣.២.២. របាយការណ៍ប្រាក់ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ ............ ៦៦
៣.៣. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាសាធារណៈលើកដំបូង ............ ៦៧
៣.៣.១. ព័ត៌មានអំពីការដាក់សំណើការផ្សាយលក់មូលបត្រកម្មសិទ្ធិ ............ ៦៧
៣.៣.២. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ ............ ៦៨
៣.៣.៣. តម្លៃមួយឯកតានៃមូលបត្រកម្មសិទ្ធិ ............ ៦៩
៣.៣.៤. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ............ ៧១
៣.៣.៥. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ............ ៧៣
៣.៣.៥.១. ការចំណាយក្រុមហ៊ុនធានាទិញមូលបត្រ និងកម្រៃជើងសារ ............ ៧៣
៣.៣.៥.២. ការចំណាយលើការដាក់ជូន និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ............ ៧៤
៣.៣.៥.៣. ការចំណាយលើការចុះបញ្ជី ............ ៧៤
៣.៣.៥.៤. ការចំណាយលើការផ្សព្វផ្សាយ ការធ្វើដំណើរ ការធ្វើរ៉ូដសូ និងការបោះពុម្ព ............ ៧៤
៣.៣.៥.៥. ការចំណាយផ្នែកវិជ្ជាជីវៈ ............ ៧៤
៣.៣.៥.៦. ការចំណាយលើសេវាភ្នាក់ងារបញ្ជីកាមូលបត្រ ............ ៧៤
៣.៣.៥.៧. ការចំណាយលើការបញ្ចុះតម្លៃលើថ្លៃបោះផ្សាយលក់ភាគហ៊ុនលើកដំបូងសម្រាប់បុគ្គលិក និងចំណាយផ្សេងៗ ............ ៧៤
៣.៤. កាតព្វកិច្ចភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក ............ ៧៤
៣.៤.១. សិទ្ធិរបស់ភាគហ៊ុនិក ............ ៧៤
៣.៤.២. ការការពារសិទ្ធិភាគហ៊ុនិក និងការអនុវត្ត ............ ៧៥
៣.៤.៣. ការការពារសិទ្ធិភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនតិច និងការអនុវត្ត ............ ៧៥
៣.៤.៤. មហាសន្និបាតភាគហ៊ុនិក ............ ៧៥
៣.៥. គោលនយោបាយភាគលាភ ............ ៧៦
៣.៦. ដំណើរការបរិវិសកម្ម ............ ៧៧
៣.៦.១. ព័ត៌មានលម្អិតនៃកម្មវិធីរ៉ូដសូជាសាធារណៈ ............ ៧៧
៣.៦.២. ការធ្វើបរិវិសកម្មជាសាធារណៈ និងគម្រោងពេលរំពឹងទុកនៃការបោះផ្សាយ ............ ៧៧

៣.៦.៣. លទ្ធផលនៃការធ្វើបរិវិសកម្ម ........................................................................................ ៧៨
៣.៧. ស្ថានភាពភាគហ៊ុនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នៅទីផ្សារមូលបត្រ.............. ៧៨
៣.៧.១. ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិម៉េងលី ជេ. គួច អេឌ្យូខេសិន នៅ ផ.ម.ក. .................. ៧៨
៣.៧.២. ការជួញដូរមូលបត្រកម្មសិទ្ធិ ម៉េងលី ជេ. គួច អេឌ្យូខេសិន នៅ ផ.ម.ក. ក្នុងរយៈពេល១ខែ ដំបូង .............................................................................................................. ៧៩
៣.៧.៣. ការជួញដូរមូលបត្រកម្មសិទ្ធិ ម៉េងលី ជេ. គួច អេឌ្យូខេសិន នៅ ផ.ម.ក. ក្នុងរយៈពេល៦ខែ ដំបូង ..............................................................................................................៨២
៣.៨. ទំនាក់ទំនងវិនិយោគិន........................................................................................... ៨៣
៣.៨.១. យន្តការ និងនីតិវិធីសម្រាប់ទំនាក់ទំនងជាមួយវិនិយោគិន................................................ ៨៣
៣.៨.២. ទំនាក់ទំនងជាមួយវិនិយោគិនក្នុង១ឆ្នាំចុងក្រោយ ..........................................................៨៤

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

**១. សេចក្តីសន្និដ្ឋាន** ..............................................................................................................៨៥
**២. អនុសាសន៍**.......................................................................................................................៨៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| គ.ម.ក. | ៖ | គណៈកម្មការមូលបត្រកម្ពុជា |
| ន.ម.ក. | ៖ | និយ័តករមូលបត្រកម្ពុជា |
| ផ.ម.ក. | ៖ | ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា |
| ម.ក | ៖ | ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត |
| ឯ.ក | ៖ | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ABC | : | ACLEDA Bank Plc. (ធនាគារ អេស៊ីលីដា ភីអិលស៊ី) |
| Aii | : | មជ្ឈមណ្ឌលភាសា អេ អាយ អាយ |
| AIS | : | សាលារៀន អន្តរទ្វីប អាមេរិកាំង |
| FPE | : | រយៈពេលនៃបំណាច់ហិរញ្ញវត្ថុបានបញ្ចប់/បញ្ចប់នៅថ្ងៃទី៣១ ខែតុលាតាមករណី |
| FYE | : | បំណាច់ឆ្នាំហិរញ្ញវត្ថុបានបញ្ចប់/បញ្ចប់នៅថ្ងៃទី៣១ ខែធ្នូតាមករណី |
| IPO | : | Initial Public Offering (ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង) |
| JSL | : | JS Land PLC. (ជេអេស លែន ភីអិលស៊ី) |
| MJQE | : | MENGLY J. QUACH EDUCATION PLC. (ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក) |
| PAS | : | Sihanoukville Autonomous Part (កំពង់ផែស្វយ័តក្រុងព្រះសីហនុ) |
| PEPC | : | PESTECH (Cambodia) Plc. (ផេសថិក ខេមបូឌា ម.ក) |
| PPAP | : | Phnom Penh Autonomous Part (កំពង់ផែស្វយ័តភ្នំពេញ) |
| PPSP | : | Phnom Penh SEZ Plc. (ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី) |
| PWSA | : | Phnom Penh Water Supply Authority (រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ) |

# បញ្ជីតារាង

តារាង១.១. : តារាងនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាមួយថ្ងៃបោះផ្សាយ និងរូបសញ្ញា ....................១២
តារាង១.២. : តារាងនៃក្រុមហ៊ុនផ្តល់សេវាសវនកម្ម..........................................................................១៥
តារាង១.៣. : តារាងនៃក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ..........................................................................១៨
តារាង១.៤. : តារាងនៃក្រុមហ៊ុនភ្នាក់ងារបញ្ជីកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ...២០
តារាង១.៥. : តារាងនៃភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល..............................................................២១
តារាង១.៦. : តារាងអំពីលក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ...............២៣
តារាង១.៧. : តារាងអំពីលក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីលក់ក្នុងមូលបត្រជាសាធារណៈ............................២៤
តារាង២.១. : តារាងបញ្ជីឈ្មោះក្រុមប្រឹក្សាភិបាល.......................................................................... ៣៦
តារាង២.២. : តារាងបញ្ជីឈ្មោះបុគ្គលិកជាន់ខ្ពស់.......................................................................... ៣៦
តារាង២.៣. : តារាងអាជ្ញាប័ណ្ណនិងពាណិជ្ជសញ្ញារបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក......... ៣៩
តារាង៣.១. : តារាងបង្ហាញពីព័ត៌មានទ្បុកអាប់ និងភាគហ៊ុនហ្វូតសេរីរបស់ក្រុមហ៊ុនបន្ទាប់ពីចុះបញ្ជីលក់មូលបត្រ ...................................................................................................... ៦៣
តារាង៣.២. : តារាងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ.......................................................................៦៥
តារាង៣.៣. : តារាងសង្ខេបនៃរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ.......................... ៦៧
តារាង៣.៤. : តារាងផែនការបែងចែកមូលបត្រកម្មសិទ្ធិ.....................................................................៦៩
តារាង៣.៥. : តារាងគោលបំណងនៃការប្រើប្រាស់សាច់ប្រាក់ដែលបានមកពី IPO............................... ៧១
តារាង៣.៦. : តារាងសង្ខេបអំពីការចំណាយ និងសោហ៊ុយទាំងអស់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ...........................................................................................................៧៣
តារាង៣.៧. : តារាងព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិម៉េងលី ជេ. គួច អេឌ្យូខេសិន នៅ ផ.ម.ក. ......... ៧៨
តារាង៣.៨. : តារាងការជួញដូរមូលបត្រកម្មសិទ្ធិរបស់ MJQE នៅ ផ.ម.ក. ក្នុងរយៈពេល ១ ខែដំបូង....... ៧៩
តារាង៣.៩. : តារាងការជួញដូរមូលបត្រកម្មសិទ្ធិរបស់ MJQE នៅ ផ.ម.ក. ក្នុងរយៈពេល ៦ ខែដំបូង....... ៨៣

# បញ្ជីរូបភាព

រូបភាពទី១.១. : និយ័តករមូលបត្រកម្ពុជា ........................................................................................ ៩
រូបភាពទី១.២. : ផ្សារមូលបត្រកម្ពុជា ............................................................................................... ១០
រូបភាពទី២.១. : ដ្យាក្រាមរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ................................................ ៣៥

# បញ្ជីក្រាប

ក្រាបទី៣.១. : ក្រាបបង្ហាញពីការប្រែប្រួលតម្លៃភាគហ៊ុន MJQE ក្នុង១ខែដំបូង ......................................៨២
ក្រាបទី៣.២. : ក្រាបបង្ហាញពីការប្រែប្រួលទំហំជួញដូររបស់ភាគហ៊ុន MJQE ក្នុង១ខែដំបូង.....................៨២

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសជាតិមួយអាចរីកចម្រើនទៅមុខបាន គឺត្រូវតែចូលរួមពីកត្តាជាច្រើន។ ដើម្បីជម្រុញឲ្យប្រទេសមួយមានការអភិវឌ្ឍ គឺត្រូវរួមចំណែកពីគ្រប់វិស័យទាំងអស់ ដូចជាវិស័យធនាគារ វិស័យទេសចរណ៍ និងវិស័យផ្សេងៗទៀតផងដែរ។ យ៉ាងណាមិញ បើយើងក្រឡេកមើលលើវិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជាឃើញថាវិស័យមួយនេះ ក៏ជាវិស័យមួយយ៉ាងសំខាន់ ដែលបានរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ដោយសារនៅពេលបច្ចុប្បន្ន ទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា កំពុងត្រូវបានយកចិត្តទុកដាក់ និងអភិវឌ្ឍ និងមានក្រុមហ៊ុន/សហគ្រាស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារពាណិជ្ជ ជាដើម ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា ដែលហៅកាត់ថា (ន.ម.ក.) ក្នុងការបោះផ្សាយលក់មូលបត្រ និងចុះបញ្ជីជួញដូរមូលបត្រ។ ទីផ្សារមូលបត្របានធ្វើឲ្យមានលំហូរសាច់ប្រាក់ ពីអ្នកដែលមានមូលធនច្រើនទៅដល់អ្នកដែលខ្វះទុន ទាំងវិស័យឯកជន សាធារណៈក៏ដូចជាផ្តល់ទុនសម្រាប់គម្រោងវិនិយោគថ្មី និងបង្កើនភាពសម្បូរបែបនៃផលិតកម្មទាំងទំនិញ និងសេវាកម្ម។

ស្របពេលជាមួយគ្នានេះ វិស័យអប់រំនៅប្រទេសកម្ពុជាក៏មានការរីកចម្រើនផងដែរ។ វិស័យអប់រំជាវិស័យមួយដ៏សំខាន់ ក្នុងការជម្រុញនូវកំណើនសេដ្ឋកិច្ចប្រទេសមួយ ព្រោះថាកាលណាវិស័យមួយនេះមានភាពល្អប្រសើរ នោះធនធានមនុស្សនៅក្នុងប្រទេសនោះ នឹងកាន់តែមានការកើនឡើង និងមានភាពល្អប្រសើរដូចគ្នា។ ដើម្បីឱ្យវិស័យអប់រំមានការរីកចម្រើនបាន រាជរដ្ឋាភិបាល ម្ចាស់គ្រឹះស្ថានសិក្សាឯកជននានា បានរិះរកគ្រប់មធ្យោបាយ ដើម្បីធ្វើឱ្យវិស័យមួយនេះអាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ដោយខិតខំបង្កើតសាលារៀនឱ្យបានច្រើន ពង្រឹងកម្មវិធីសិក្សាឱ្យកាន់តែល្អប្រសើរ ជ្រើសរើសលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យពូកែៗ និងបំពាក់បរិក្ខារទំនើបៗក្នុងថ្នាក់រៀនទៀតផង។

ដោយឃើញពីការរីកចម្រើននៃវិស័យមូលបត្រ រួមជាមួយនឹងវិស័យអប់រំនេះ ម្ចាស់គ្រឹះស្ថានសិក្សាអប់រំឯកជនបានចូលរួមទៅក្នុងវិស័យមូលបត្រនេះ ដើម្បីប្រមូលមូលធនបន្ថែម ដើម្បីអភិវឌ្ឍគម្រោងរបស់ខ្លួន ជាពិសេសអាចបង្កើតប្រាក់ចំណូលបន្ថែមដល់ស្ថាប័នរបស់ខ្លួន រួមទាំងវិនិយោគិនដែលបានទិញមូលបត្ររបស់ខ្លួនផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទីផ្សារមូលបត្រនៅកម្ពុជា ត្រូវបានបង្កើតឡើងជាង១០ឆ្នាំប៉ុណ្ណោះ ដោយស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងវិស័យហិរញ្ញវត្ថុឲ្យមានការអភិវឌ្ឍកាន់តែខ្លាំង និងគាំទ្រដល់កំណើនសេដ្ឋកិច្ច

ជាតិប្រកបដោយចីរភាព។ ដោយយើងមើលឃើញថា ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក គឺជាក្រុមហ៊ុនមួយដែលមានសក្តានុពល បានចុះបញ្ជីជាមួយនឹងផ្សារមូលបត្រកម្ពុជាក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូច្នេះក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ យើងនឹងស្រាវជ្រាវពីប្រធានបទមួយនេះឲ្យកាន់តែលម្អិតដោយឆ្លើយតបទៅនឹងកម្រងសំណួរទាំង៣ខាងក្រោម៖

- តើស្ថានភាពទូទៅរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានលក្ខណៈយ៉ាងណាខ្លះ?
- តើតួអង្គសំខាន់ៗក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានអ្វីខ្លះ?
- តើដំណើរការនៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនៃសារណាបញ្ចប់ការសិក្សានេះ គឺផ្តោតសំខាន់ទៅលើប្រធានបទ "ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក" ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ បន្ថែមពីលើអ្វីដែលបានសិក្សាកន្លងមកនេះ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- សិក្សាស្វែងយល់លម្អិតពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក
- សិក្សាស្វែងយល់ពីតួអង្គសំខាន់ៗដែលចូលរួមនៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក
- សិក្សាស្វែងយល់ពីដំណើរការនៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ គឺផ្តោតសំខាន់ទៅលើដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ផ្ទាល់។ យើងនឹងបង្ហាញពីស្ថានភាពទូទៅនៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ជាមួយនឹងតួអង្គសំខាន់ៗដែលចូលរួមនៅក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ស្ថាប័នមួយនេះ និងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ដោយផ្អែកលើឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ដែលចេញផ្សាយក្នុងឆ្នាំ២០២៣។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវអំពីប្រធានបទនេះ ត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៍រួម ផ្តល់ជាចំណេះដឹង និងសារៈសំខាន់ដូចជា៖

- ទទួលបាននូវចំណេះដឹងបន្ថែមទាក់ទងទៅនឹងវិស័យមូលបត្រ បន្ថែមទៅលើទ្រឹស្តីដែលបានសិក្សាកន្លងមក
- បង្កើតបានជាសមិទ្ធផលមួយសម្រាប់និស្សិតជំនាន់ក្រោយក្នុងការស្រាវជ្រាវបន្ត ជាជំនួយសម្រាប់ធ្វើកិច្ចការស្រាវជ្រាវបញ្ចប់ការសិក្សា
- ជាឯកសារស្នាដៃដែលអាចឱ្យសាធារណជនបង្វែរចំណាប់អារម្មណ៍មកលើវិស័យមូលបត្រកាន់តែច្រើន
- ជាឯកសារដែលជួយឱ្យយល់ច្បាស់ពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក
- ជាឯកសារ និងចំណេះដឹងសម្រាប់ក្រុមហ៊ុន និងសាធារណៈជនដែលមានបំណងចង់វិនិយោគទៅលើវិស័យមូលបត្រ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការសរសេរសារណាលើប្រធានបទ ស្តីពីដំណើរការនៃការបោះផ្សាយមូលបត្រជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក គឺធ្វើតាមវិធីសាស្ត្របែបពិពណ៌នាដោយរៀបរាប់ពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន គោលការណ៍ និងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ចំពោះទិន្នន័យដែលយកមកប្រើប្រាស់នៅក្នុងការស្រាវជ្រាវមួយនេះគឺជាទិន្នន័យបន្ទាប់បន្សំ ឬទិន្នន័យដែលមានស្រាប់ដែលមានប្រភពចេញពី៖

- ច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំ និងបទប្បញ្ញត្តិផ្សេងៗរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា
- ឯកសារបោះពុម្ពជាភាសាខ្មែរ សៀវភៅសិក្សា ដែលទាក់ទងទៅនឹងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក
- ព័ត៌មានអំពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើគេហទំព័ររបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

- ទិន្នន័យផ្សេងៗដែលនៅក្នុងគេហទំព័រផ្លូវការរបស់និយ័តករមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក
- ទិន្នន័យតាមគេហទំព័រនានាដែលទាក់ទងនៅនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ ត្រូវបានបែងចែកជា ៥ផ្នែកសំខាន់ៗដូចខាងក្រោម៖

- **សេចក្តីផ្តើម**

ក្នុងផ្នែកនេះ យើងនឹងបង្ហាញពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ទំហំ និងដែនកំណត់សារៈសំខាន់ វិធីសាស្ត្រ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទនេះ។

- **ជំពូកទី១៖ រំលឹកទ្រឹស្តី**

ក្នុងជំពូកនេះ យើងនឹងបង្ហាញអំពីនិយមន័យ ប្រភេទនៃមូលបត្រ ប្រភេទនៃទីផ្សារមូលបត្រតួអង្គសំខាន់ៗដែលចូលរួមក្នុងដំណើរការបោះផ្សាយ លក្ខខណ្ឌដើម្បីធ្វើការបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រ រួមទាំងយន្តការនៃការបោះផ្សាយលក់មូលបត្រលក់ជាសាធារណៈលើកដំបូងផងដែរ។

- **ជំពូកទី២៖ ស្ថានភាពទូទៅនៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក**

ក្នុងជំពូកនេះ យើងនឹងបង្ហាញអំពីប្រវត្តិរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក រចនាសម្ព័ន្ធ ផែនការអនាគត យុទ្ធសាស្ត្រអាជីវកម្ម ផលិតផល សេវាកម្មរបស់ក្រុមហ៊ុន បណ្តាញនៃសាខាសាលារៀនរបស់ក្រុមហ៊ុន កត្តាហានិភ័យ និងការគ្រប់គ្រងហានិភ័យ។

- **ជំពូកទី៣៖ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក**

ក្នុងជំពូកនេះ យើងនឹងធ្វើការបង្ហាញពីព័ត៌មានរបស់ក្រុមហ៊ុននៃក្រុមការងារបោះផ្សាយមូលបត្រជាសាធារណៈលើកដំបូង ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ការពិពណ៌អំពីមូលបត្រកម្មសិទ្ធិបោះផ្សាយលក់មូលបត្រជាសាធារណ កាតព្វកិច្ចភាគហ៊ុនិក ការការពារសិទ្ធិរបស់ភាគហ៊ុនិកគោលនយោបាយភាគលាភ ដំណើរបរិវិសកម្ម ស្ថានភាពភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងទីផ្សារមូលបត្រ និងទំនាក់ទំនងវិនិយោគិន។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

# រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សេចក្តីផ្តើម

↓

ជំពូកទី១៖ រំលឹកទ្រឹស្តី

↓

ជំពូកទី២៖ ស្ថានភាពទូទៅនៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

↓

ជំពូកទី៣៖ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

↓

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី១
# រំលឹកត្រីស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ទីផ្សារមូលបត្រ

### ១.១.១. និយមន័យ

ទីផ្សារមូលបត្រ គឺជាកន្លែងដែលមូលបត្រ ដូចជាភាគហ៊ុននិងសញ្ញាបណ្ណ ត្រូវបានទិញនិងលក់ដោយវិនិយោគិនផ្សេងៗ រួមទាំងជាតិ និងអន្តរជាតិ។[1]

### ១.១.២. តួនាទីនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាសរសៃឈាមដ៏សំខាន់សម្រាប់សេដ្ឋកិច្ចជាតិទាំងមូលដែលក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងវិនិយោគិនជាអ្នកដើរតួនាទីស្នូល។ ផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញនូវសេដ្ឋកិច្ចរបស់ប្រទេសមួយ ដោយវាបានអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម៉្យាងវិញទៀត ទីផ្សារនេះទៀតសោតក៏បានផ្តល់ឱកាសដល់អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ (ជាមួយមូលបត្រដែលមានហានិភ័យទាប) ផងដែរ។ នៅពេលដែលមានលំហូរមូលធនពីអ្នកមានប្រាក់ទៅកាន់អ្នកដែលត្រូវការប្រាក់កើតឡើងប្រកបដោយប្រសិទ្ធភាព នោះសកម្មភាពសេដ្ឋកិច្ចដូចជាពាណិជ្ជកម្ម និងផលិតកម្មនឹងរីកលូតលាស់ ព្រមទាំងបង្កើតឱ្យមានការងារ និងទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅផងដែរ។

## ១.២. ប្រភេទមូលបត្រ

មូលបត្រ គឺជាកិច្ចសន្យាហិរញ្ញវត្ថុដែលអាចជួញដូរបាន ដែលកិច្ចសន្យានេះបញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិ ឬម្ចាស់បំណុលលើក្រុមហ៊ុនមួយហើយយើងក៏អាចធ្វើការជួញដូរមូលបត្រនេះបានដែរ។ មូលបត្រមាន ៣ ប្រភេទគឺភាគហ៊ុន សញ្ញាបណ្ណ និង ឧបករណ៍និស្សន្ទ។[2]

### ១.២.១. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ សំដៅទៅលើភាគហ៊ុនដែលអាចមានប្រភេទផ្សេងៗគ្នា។ ក្រុមហ៊ុនបោះផ្សាយមូលបត្រនឹងលក់វាជាឯកជន ឬជាសាធារណៈ ព្រោះតែវាជាមធ្យោបាយសម្រាប់ក្រុមហ៊ុនក្នុងការបង្កើនទុន

---

[1] https://csx.com.kh/news/faq/listPosts.do?lang=kh&MNCD=7060&postId=6#sec1_1 (ចូលទស្សនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤)

[2] https://whjww.linkedin.com/pulse/%E1%9Ekk%98%E1%9E%9B%E1%9E%94%E1%9E%8F%E1%9E%9Asecurities-sok-sotheara (ចូលទស្សនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤)

សម្រាប់ការចំណាយលើសកម្មភាពពាណិជ្ជកម្មរបស់ពួកគេ។ មូលបត្រកម្មសិទ្ធិជាឧបករណ៍ហិរញ្ញវត្ថុ ដែលអ្នកទិញវានឹងក្លាយជាម្ចាស់កម្មសិទ្ធិឬភាគហ៊ុនិករបស់ក្រុមហ៊ុន ហើយមានសិទ្ធិទទួលយកផលប្រយោជន៍ពីចំណូល និងទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

មូលបត្រកម្មសិទ្ធិ ផ្តល់ឱ្យភាគហ៊ុនិកនូវសក្តានុពល សម្រាប់កំណើនមូលធននាពេលអនាគត ក៏ដូចជាទទួលបានការទូទាត់ភាគលាភជាដើម ប៉ុន្តែក្រុមហ៊ុនគ្មានកាតព្វកិច្ចផ្លូវច្បាប់ណាមួយក្នុងការទូទាត់ ភាគលាភឱ្យភាគហ៊ុនិកនោះទេ។ ផលប្រយោជន៍ទាំងនេះ អាចជាប់ពន្ធកាត់ទុកទៅតាមការកំណត់នានារបស់ច្បាប់នៃប្រទេសនីមួយៗផងដែរ។

មូលបត្រកម្មសិទ្ធិ តំណាងពីភាពជាម្ចាស់កម្មសិទ្ធិនៅក្នុងក្រុមហ៊ុនមានន័យថា ភាគហ៊ុនិកមានសិទ្ធិមួយចំនួនដូចជា ចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលជាដើមសម្រាប់គ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

ការទិញ–លក់មូលបត្រកម្មសិទ្ធិជាការវិនិយោគ ហើយការវិនិយោគលើមូលបត្រកម្មសិទ្ធិជាការវិនិយោគរយៈពេលវែង និងផ្សារភ្ជាប់ជាមួយហានិភ័យ។ បានន័យថាភាគហ៊ុនិកមិនមែនត្រឹមរួមចំណែកក្នុងការទទួលបានជោគជ័យនោះទេ គឺរួមចំណែកផងដែរក្នុងបរាជ័យរបស់អាជីវកម្មនៃក្រុមហ៊ុន។ នៅពេលក្រុមហ៊ុនក្ស័យធន ភាគហ៊ុនិកជាបុគ្គលចុងក្រោយគេ ដែលទទួលបានសំណងនៃការខូចខាតរបស់ខ្លួន បន្ទាប់ពីម្ចាស់សញ្ញាប័ណ្ណ និងម្ចាស់បំណុលជាដើម។ មូលបត្រកម្មសិទ្ធិមានច្រើនប្រភេទ ប៉ុន្តែជាទូទៅមូលបត្រកម្មសិទ្ធិ ត្រូវបានបែងចែកជា ២ ប្រភេទគឺភាគហ៊ុនធម្មតា (Common Stock) និងភាគហ៊ុនបុរិមា (Preferred Stock)។[3]

### ១.២.២. មូលបត្របំណុល

មូលបត្របំណុល គឺជាមូលបត្រដែលបញ្ជាក់ពីកាតព្វកិច្ចបំណុលរបស់អាជីវកម្ម ឬរដ្ឋាភិបាលចំពោះអ្នកកាន់។ មូលបត្របំណុលផ្តល់ប្រាក់ចំណូលជាការប្រាក់ នេះគឺជាប្រាក់ចំណូលថេរធម្មតា ហើយវាមិនអាស្រ័យលើលទ្ធផលអាជីវកម្មទេ។ មូលបត្របំណុលគឺជាមូលបត្រដ៏សំខាន់ ដូច្នេះក្នុងករណីដែលក្រុមហ៊ុនត្រូវរំលាយ ឬក្ស័យធន ភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវតែទូទាត់ជាមុនទៅឱ្យអ្នកកាន់សញ្ញាប័ណ្ណជាកាតព្វកិច្ចចាំបាច់។ បន្ទាប់ពីភាគហ៊ុនត្រូវបានសងទៅកាន់ម្ចាស់មូលបត្របំណុលរួចរាល់ ភាគហ៊ុនដែលនៅសល់ត្រូវបានចែកចាយដល់ម្ចាស់ភាគហ៊ុន។[4]

[3] https://www.facebook.com/100038469349584/posts/161192842325308/ (ចូលទស្សនានៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤)

[4] https://www.vietnam.vn/km/trai-phieu-la-gi-va-nhung-dieu-can-biet (ចូលទស្សនាថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤)

**១.២.៣. ឧបករណ៍និស្សន្ទ**

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ សំដៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឲ្យបុគ្គលណាមួយដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញ លក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើប្រាស់សិទ្ធិនេះក៏ដោយ។[5]

## ១.៣. ប្រភេទនៃទីផ្សារមូលបត្រ

ជាទូទៅ ការចូលរួមនៃវិនិយោគិននៅក្នុងផ្សារមូលបត្រ គឺសំដៅដល់ការទិញលក់ភាគហ៊ុននៅទីផ្សារបន្ទាប់ (នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា) គឺជាការទិញលក់ភាគហ៊ុនពីវិនិយោគិនទៅវិនិយោគិន។

**១.៣.១. ទីផ្សារដំបូង** ( Primary Market )

ទីផ្សារដំបូង (Primary Market) គឺជាទីផ្សារដែលភាគហ៊ុន (ទើបបោះផ្សាយជាសាធារណៈលើកដំបូង IPO ដោយក្រុមហ៊ុនមួយ) ត្រូវបានដាក់ឱ្យជួញដូរជាលើកដំបូង។ បានសេចក្ដីថា ជាទីផ្សារដែលវិនិយោគិនសាធារណៈទិញភាគហ៊ុនដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ គឺប្រៀបបាននឹងការទិញទំនិញមួយដោយអ្នកប្រើប្រាស់ដោយផ្ទាល់ពីក្រុមហ៊ុនផលិតដូច្នោះដែរ។[6]

**១.៣.២. ទីផ្សារបន្ទាប់** ( Secondary Market )

ទីផ្សារបន្ទាប់ (Secondary Market) វិនិយោគិនដែលទិញភាគហ៊ុននៅទីផ្សារដំបូង ហើយចង់លក់ភាគហ៊ុននោះចេញដើម្បីយកសាច់ប្រាក់មកវិញ ត្រូវលក់ភាគហ៊ុននោះទៅឱ្យវិនិយោគិនដទៃទៀត គឺមិនមែនលក់ទៅឱ្យក្រុមហ៊ុនបោះផ្សាយវិញទេ។ ការទិញលក់តទៅនេះ រវាងវិនិយោគិន(អ្នកទិញ) និងវិនិយោគិន(អ្នកលក់) ត្រូវបានគេហៅថាជាការទិញលក់នៅទីផ្សារបន្ទាប់ គឺប្រៀបបាននឹងការជួញដូរវត្ថុ« ជជុះ »រវាងអ្នកប្រើប្រាស់ដូចគ្នាដូច្នោះដែរ គ្រាន់តែភាគហ៊ុនមិនចេះសឹករិចរិលប៉ុណ្ណោះ។ ការជួញដូរនៅទីផ្សារបន្ទាប់គឺធ្វើឡើងនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(ផ.ម.ក.)។

## ១.៤. តួអង្គសំខាន់ៗដែលចូលរួមក្នុងការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារមូលបត្រកម្ពុជា

នៅក្នុងដំណើរការប្រព្រឹត្តទៅនៃការបោះផ្សាយលក់មូលបត្រមានតួអង្គសំខាន់ៗចូលរួមដូចជា៖

**១.៤.១. និយ័តករមូលបត្រកម្ពុជា**

និយ័តករមូលបត្រ គឺជានីតិបុគ្គលដែលបង្កើតឡើងដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការមូលបត្រ។

[5] ហេង ច័ន្ទបូលីន៖ ទីផ្សារមូលបត្រកម្ពុជា (២០២៤) ទំព័រទី៣១

[6] https://bizkhmer.com/articles/58832 (ចូលទស្សនាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤)

និយ័តករមូលបត្រនៅក្នុងប្រទេសកម្ពុជា គឺជានិយ័តករមូលបត្រកម្ពុជាដែលហៅកាត់ថា ន.ម.ក. (Securities and Exchange Regulator of Cambodia/SERC)។ និយ័តករមូលបត្រគឺជាអ្នកបង្កើតច្បាប់បទបញ្ញត្តិផ្សេងៗដែលទាក់ទងទៅនឹងការជួញដូរមូលបត្រ។ បន្ថែមពីនេះនិយ័តករមូលបត្រជាអ្នកអនុញ្ញាត និងផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនដែលមានបំណងចូលរួមនៅក្នុងវិស័យមូលបត្រ និងជាអ្នកដោះស្រាយវិវាទដែលកើតឡើងនៅក្នុងវិស័យមូលបត្រផងដែរ។ គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៨ ដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងដាក់សម្ពោធជាផ្លូវការថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩។ នៅដើមឆ្នាំ២០២១ ត្រូវបានប្តូរឈ្មោះទៅជានិយ័តករមូលបត្រ (ន.ម.ក.)។[7]

**រូបភាពទី ១.១៖** និយ័តករមូលបត្រកម្ពុជា

### ១.៤.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ឬ ផ.ម.ក. ត្រូវបានអ្នកវិនិយោគគិតក្នុងប្រទេសកម្ពុជាបានទទួលស្គាល់យ៉ាងច្បាស់ថាជា ប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុននេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ដែលភាគហ៊ុន ៥៥% កាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ៤៥% ទៀតកាន់កាប់ដោយផ្សារមូលបត្រកូរ៉េ។ ផ្សារមូលបត្រកម្ពុជាទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជា ក្នុងការធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករទូទាត់ ផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។ ក្រុមហ៊ុននេះផ្តោត សំខាន់លើការលើកកម្ពស់កំណើនសេដ្ឋកិច្ចដោយជួយសម្រួលដល់ការវិនិយោគ ការគាំទ្រដល់ដំណើរការពង្រីកវិស័យឯកជននិងជំរុញលំហូរចូលរួមនូវមូលធន។ ផ.ម.ក. មានតួនាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសល្អប្រសើរដល់អ្នកចូលរួមនៅក្នុងទីផ្សារមូលបត្រ ជាពិសេសការជំរុញ និងការលើកទឹកចិត្តដល់វិនិយោគិន និងក្រុមហ៊ុនក្នុងស្រុក តាមរយៈការបង្កើតឱ្យមាននូវសន្ទនីយភាពទីផ្សារ និងការការពារផលប្រយោជន៍វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។

[7] ហេង ច័ន្ទបូលីន៖ ទីផ្សារមូលបត្រកម្ពុជា (២០២៤) ទំព័រទី៧០

**រូបភាពទី ១.២៖** ផ្សារមូលបត្រកម្ពុជា

### ១.៤.៣. ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រ ជាក្រុមហ៊ុនដែលដើរតួយ៉ាងសំខាន់ក្នុងដំណើរការទិញលក់មូលបត្រនៅក្នុងផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនមូលបត្រមានតួនាទីក្នុងការជួយដល់វិនិយោគិនក្នុងដំណើរការជួញដូរ(ទិញ-លក់) មូលបត្រ នៅក្នុងទីផ្សារមូលបត្រព្រោះវិនិយោគិនមិនអាចធ្វើការជួញមូលបត្រដោយផ្ទាល់នៅលើទីផ្សារដោយខ្លួនឯងបាននោះទេ។ ក្រុមហ៊ុនមូលបត្រ បម្រើសេវាកម្មក្នុងនាមជាអន្តរការីក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងវិនិយោគិន និងតួអង្គដទៃទៀតនៅក្នុងទីផ្សារមូលបត្រ និងស្វែងរកប្រាក់ចំណេញតាមរយៈការគិតកម្រៃសេវាពីវិនិយោគិន។ ក្រុមហ៊ុនមូលបត្រត្រូវបានចែកចេញជាច្រើនប្រភេទ ហើយការបែងចែកនេះ ត្រូវបានកំណត់ដោយកម្រិតនៃប្រភេទសេវាកម្មដែលក្រុមហ៊ុនអាចផ្តល់ជូនទៅដល់វិនិយោគិន។ ក្រុមហ៊ុនមូលបត្រមានដូចជា ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនជួញដូរមូលបត្រ ក្រុមហ៊ុនជើងសារមូលបត្រ និងក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ ហើយក្រុមហ៊ុនទាំងអស់នេះត្រូវតែទទួលបានអាជ្ញាប័ណ្ណពីនិយ័តករមូលបត្រកម្ពុជាជាមុនសិនទើបអាចធ្វើអាជីវកម្មបាន។[8]

- **ក្រុមហ៊ុនធានាទិញមូលបត្រ៖** ក្រុមហ៊ុនធានាទិញមូលបត្រ ជាស្ថាប័នដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចេញលក់និងផ្សព្វផ្សាយមូលបត្រជាសាធារណៈពីសារជីវកម្ម។ តួនាទីស្នូលរបស់ក្រុមហ៊ុននេះ គឺជួយក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់ភាគហ៊ុនលើកដំបូង (IPO) ជាសារធារណៈក្នុងទីផ្សារដំបូង (Primary market)។ ក្រុមហ៊ុននេះមានសិទ្ធិក្នុងការសម្របសម្រួល និងជួញដល់ក្រុមហ៊ុនទាំងឡាយណាដែលមានបំណងចង់បោះផ្សាយលក់មូលបត្រជាសាធារណៈ និងអាចធ្វើការជួញដូរមូលបត្រសម្រាប់គណនីក្រុមហ៊ុនផ្ទាល់ និងជួញដូរតាមការបញ្ជារបស់វិនិយោគិន។[9]

[8] https://www.serc.gov.kh/khmer/m52.php?pn=6 ( ចូលទស្សនាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤)

[9] https://bizkhmer.com/articles/59658 (ចូលទស្សនាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤)

- **ក្រុមហ៊ុនជួញដូរមូលបត្រ៖** មានសិទ្ធក្នុងការជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងហានិភ័យដោយខ្លួនឯង។
- **ក្រុមហ៊ុនជើងសារមូលបត្រ៖** ក្រុមហ៊ុនជើងសារមូលបត្រមានតួនាទីក្នុងនាមជាអ្នកទិញ ឬលក់មូលបត្រតាមបញ្ជាអតិថិជនរបស់ខ្លួនដោយទទួលបានកម្រៃជើងសារ។

### ១.៤.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រ

តួអង្គសំខាន់មួយទៀតនៅក្នុងទីផ្សារមូលបត្រ គឺក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការជួញដូរអាចប្រព្រឹត្តទៅបានលុះត្រាតែមានក្រុមហ៊ុនបោះផ្សាយមូលបត្រចូលរួម ព្រមទាំងមានជំនួញពីក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយមានសិទ្ធបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ មូលបត្របំណុល នៅក្នុងទីផ្សារមូលបត្រ ក្នុងគោលបំណងគៀងគរមូលនិធិពីសំណាក់សាធារណៈជន និងវិនិយោគិនទាំងក្នុង និងក្រៅប្រទេស ដើម្បីពង្រីកអាជីវកម្ម ព្រមទាំងអភិវឌ្ឍប្រតិបត្តិការអាជីវកម្មរបស់ខ្លួនឱ្យរីកចម្រើនទៅមុខ។ ក្រុមហ៊ុនបោះផ្សាយអាចតបស្នងទៅកាន់វិនិយោគិនវិញក្នុងទម្រង់ជាហិរញ្ញវត្ថុ(ភាគលាភ ការប្រាក់) ឬសិទ្ធិផ្សេងៗ (សិទ្ធិក្នុងការបោះឆ្នោត)។ លើសពីនេះ ក្រុមហ៊ុនដែលមានសិទ្ធិអាចបោះផ្សាយលក់មូលបត្រនៅលើទីផ្សារមូលបត្របាន លុះត្រាតែក្រុមហ៊ុននោះជាក្រុមហ៊ុនសាជីវកម្ម ឬក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ឬក្រុមហ៊ុនបរទេសប្រហាក់ប្រហែល ហើយក្រុមហ៊ុនទាំងនោះត្រូវចាំបាច់សម្តែងនូវឆន្ទៈ ក្នុងការប្រើប្រាស់ហិរញ្ញវត្ថុដែលទទួលបានពីការបោះផ្សាយ និងទស្សនៈក្នុងការអភិវឌ្ឍក្រុមហ៊ុននាពេលអនាគត។ បន្ថែមពីនេះ ក្រុមហ៊ុនបោះផ្សាយមានតួនាទីក្នុងការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុនានាជាសាធារណៈ ដើម្បីឱ្យមហាជនទូទៅ រួមទាំងវិនិយោគិនទទួលបានព័ត៌មានគ្រប់គ្រាន់ មុននឹងធ្វើការសម្រេចចិត្តក្នុងការវិនិយោគជាមួយក្រុមហ៊ុនបោះផ្សាយណាមួយផងដែរ។ នៅពេលបោះផ្សាយមូលបត្រជាសាធារណៈលើកដំបូង ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណនិយ័តករមូលបត្រ និងជ្រើសរើសក្រុមហ៊ុនសេវាសវនកម្ម ព្រមទាំងមេធាវីដែលទទួលបានការទទួលស្គាល់ពីនិយ័តករមូលបត្រ ដើម្បីបង្កើតជាក្រុមការងារសម្រាប់បោះផ្សាយមូលបត្រជាសាធារណៈលើកដំបូង(IPO)។

គិតត្រឹមខែមិថុនា ឆ្នាំ២០២៣ ផ្សារមូលបត្រកម្ពុជា មានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិចំនួន ១១ ក្រុមហ៊ុនដូចជា៖[10]

[10] https://csx.com.kh/data/lstcom/listPosts.do?MNCD=5010 (ចូលទស្សនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៤)

**តារាងទី ១.១៖** តារាងនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាមួយថ្ងៃបោះផ្សាយ និងរូបសញ្ញា៖

| និមិត្តសញ្ញាក្រុមហ៊ុន | បញ្ជីឈ្មោះក្រុមហ៊ុនបោះផ្សាយ | កាលបរិច្ឆេទចុះបញ្ជី |
|---|---|---|
| | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) | ១៨ មេសា ២០១២ |
| | ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី(GTI) | ១៦ មិថុនា ២០១៤ |
| | កំពង់ផែស្វយ័តភ្នំពេញ(PPAP) | ០៩ ធ្នូ ២០១៥ |
| | រ៉ូយ៉ាល់គ្រុប ភ្នំពេញ អេសអីហ្សិត ម.ក (PPSP) | ៣០ ឧសភា ២០១៦ |
| | កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) | ០៨ មិថុនា ២០១៦ |
| | ធនាគារ អេស៊ីលីដា ភីអិលស៊ី (ABC) | ១៥ ឧសភា ២០២០ |
| | ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (PEPC) | ១២ សីហា ២០២០ |

| | | |
|---|---|---|
| DBD ENGINEERING | ឌី ប៊ី ឌី អ៊ីនជីនារីង ម.ក(DBDE) | ០៩ កញ្ញា ២០២១ |
| LAND | ជេអេស លែន ភីអិលស៊ី(JSL) | ១០ កុម្ភៈ ២០២២ |
| cellcard \| 4G LTE Proudly Khmer | ក្រុមហ៊ុន ខេម ជីអេសអេម ម.ក (CGSM) | ២៧ មិថុនា ២០២៣ |
| MJQ MENGLY J. QUACH EDUCATION | ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក(MJQE) | ២៨ មិថុនា ២០២៣ |

### ១.៤.៥. ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

ក្រុមហ៊ុនមេធាវី ឬមេធាវីដែលជាអ្នកផ្តល់ការប្រឹក្សាយោបល់លើបញ្ហាផ្លូវច្បាប់ទាំងអស់ដែលទាក់ទងនឹងពាក្យស្នើសុំ និងឯកសារផ្តល់ព័ត៌មាន ជាពិសេសការពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់របស់ក្រុមហ៊ុនដែលមានបំណងចុះបញ្ជី និងធ្វើការផ្ទៀងផ្ទាត់ទៅលើឯកសារផ្សេងៗឱ្យត្រឹមត្រូវតាមច្បាប់។

ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ដែលទទួលបានការទទួលស្គាល់ពី ន.ម.ក.ចំនួន១៧ក្រុមហ៊ុនដូចជា៖[11]

- ក្រុមហ៊ុនមេធាវី អេច ប៊ី អេស
- ការិយាល័យមេធាវី អ អេន ជី សុខ អេន ហេង
- ការិយាល័យមេធាវី សុក ស៊ីផាន់ណា និងសហការីជាសមាជិក
- ការិយាល័យមេធាវី សិទ្ធិស័ក្តិ
- ក្រុមមេធាវី អាស៊ី កម្ពុជា

[11] ហេង ច័ន្ទបូលីន៖ ទីផ្សារមូលបត្រកម្ពុជា (២០២៤) ទំព័រទី៨០ ដល់៨១

- ការិយាល័យមេធាវី ប៊ុន និងសហការី
- ការិយាល័យមេធាវី ភីរ៉ាយធី និងសហការី
- ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាគា
- ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន
- ការិយាល័យមេធាវី ស៊ិន & ផាតនើ
- ក្រុមមេធាវី កម្ពុជាបាយ៉ន (ស៊ី ប៊ី អិល)
- ក្រុមមេធាវី មេគង្គ
- ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ
- ក្រុមមេធាវី ស៊ី អេស ភី និងសហការី
- ការិយាល័យមេធាវី សេដ្ឋាល័យ
- ក្រុមមេធាវី ស្កាយ & សហការី
- ក្រុមហ៊ុនមេធាវី កម្ពុជា កិច្ចការអន្តរជាតិ

### ១.៤.៦. ក្រុមហ៊ុនផ្តល់សេវាបកប្រែ

ក្រុមហ៊ុនផ្តល់សេវាបកប្រែ ជាក្រុមហ៊ុនបកប្រែឯកសារពាក់ព័ន្ធនឹងIPOឱ្យបានត្រឹមត្រូវតាមអត្ថន័យដើម។ ក្រុមហ៊ុនផ្តល់សេវាបកប្រែនៅក្នុងវិស័យមូលបត្រក្នុងប្រទេសកម្ពុជាដែលទទួលស្គាល់ដោយ ន.ម.ក. មានចំនួនតែ១ប៉ុណ្ណោះ។ ស្ថាប័ននោះគឺ មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ហើយអ្នកទទួលខុសត្រូវលើការបកប្រែមានចំនួន២ រូបគឺៈ[12]

- លោក តាន់ហ៊ាង ដាវ៉ែណ
- លោក យិន លីហួត

### ១.៤.៧. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

ក្រុមហ៊ុនផ្តល់សេវាសវនកម្មនឹងជួយក្រុមហ៊ុនបោះផ្សាយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានតាមលក្ខខណ្ឌតម្រូវក្នុងឯកសារផ្តល់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗ។ ខាងក្រោមនេះជាបញ្ជីឈ្មោះក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យផ្តល់សេវានៅក្នុងវិស័យមូលបត្រៈ[13]

[12] ហេង ច័ន្ទបូលីនៈ ទីផ្សារមូលបត្រកម្ពុជា (២០២៤) ទំព័រទី៩០

[13] https://www.serc.gov.kh/khmer/m53.php?pn6 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

**តារាងទី ១.២៖** តារាងនៃក្រុមហ៊ុនផ្តល់សេវាសវនកម្ម

| នាមករណ៍ក្រុមហ៊ុន | អាស័យដ្ឋាន និងលេខទំនាក់ទំនង |
|---|---|
| ១. ក្រុមហ៊ុន ប្រាយវ៉តធ័រ ហាវខូភើស៍ (ខេមបូឌា)<br>PricewaterhouseCoopers (Cambodia) Ltd.<br>២. សវនករឯករាជ្យ មានចំនួន ០៤រូប៖<br>• លោក គុយ លីម<br>• លោក ឡាង ហ៊ី<br>• លោកស្រី ហង្សសូផាត ម៉ូលីប្បាណា<br>• លោកស្រី ទូច សុវណ្ណារ៉ា | អគារលេខ ៥៨C មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៨៦០ ៦០៦<br>ទូរសារ : ០២៣ ២១១ ៥៩៤<br>អ៊ីម៉ែល : pwc.cambodia@kh.pwc.com<br>គេហទំព័រ : www.pwc.com/cambodia |
| ១. ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា<br>KPMG CAMBODIA LTD<br>២. សវនករឯករាជ្យ មានចំនួន ០៦ រូប ៖<br>• លោក ង៉ែ ហ៊ុយ<br>• កញ្ញា តាំង យុគហ្វុង<br>• លោកស្រី ហ្គេក ទាវ<br>• លោក Phor Auvarin<br>• លោក Low Seh Kit<br>• លោក យឹម ឡុងឌី | អគារ GIA ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០១៧ ៦៦៦ ៥៣៧<br>អ៊ីម៉ែល : audit@kpmg.com.kh<br>គេហទំព័រ : www.kpmg.com |
| ១. ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត<br>BDO CAMBODIA LIMITED<br>២. សវនករឯករាជ្យ មានចំនួន ០៦ រូប៖<br>• លោក Gan Ah Tee<br>• លោក Tang Seng Choon<br>• លោក Law Kian Huat<br>• លោក Lim Seng Siew<br>• លោក Lee Ken Wai<br>• កញ្ញា សុង ស្រីរដ្ឋា | សណ្ឋាគារកាំបូឌីយ៉ាណា លេខ៣១៣ បន្ទប់លេខ២៨ វិថីព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៩៣ ២២៦<br>ទូរសារ : ០២៣ ៩៩៣ ២២៥<br>អ៊ីម៉ែល : info@bdo.com.kh<br>គេហទំព័រ : www.bdo.com.kh |

| | |
|---|---|
| ១. ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា)<br>ERNST & YOUNG (CAMBODIA) LTD.<br>២. សវនករឯករាជ្យ មានចំនួន ០៤ រូប ៖<br>• លោកស្រី ឡុន ស៊ីនរតនា<br>• លោកស្រី Maria Cristina Calimbas<br>• លោក Emmanuel Alalid Guelas<br>• លោក ខាវ ហុង | អាគារ Emerald Building លេខ ៦៤ ជាន់ទី៥ មហាវិថីព្រះនរោត្តម កែងផ្លូវលេខ ១៧៨ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២១៧ ៨១៤/៨២៤/៨២៥<br>ទូរសារ : ០២៣ ២១៧ ៨០៥<br>អ៊ីម៉ែល : eykoc@vn.ey.com<br>គេហទំព័រ : www.ey.com |
| ១. ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត<br>Grant Thornton (Cambodia) Limited.<br>២. សវនករឯករាជ្យ មានចំនួន ០៤ រូប ៖<br>• លោក Jasani Narendrakumar<br>• លោក Hooi Kok Mun<br>• លោក Almera Ronald Coronel<br>• លោក Ng Yee Zent | វិមានកាណាឌីយ៉ា លេខ ៣១៥ ជាន់ទី២០ មហាវិថីព្រះមុន្នីវង្ស កែងផ្លូវព្រះអង្គ ឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។<br>ទូរស័ព្ទ : +៨៥៥ ២៣ ៩៦៦ ៥២០<br>ទូរសារ : +៨៥៥ ២៣ ៩៦៦ ៥២៦<br>អ៊ីម៉ែល : Info@kh.gt.com<br>គេហទំព័រ : www.grantthornton.com.kh |
| ១. ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក<br>Crowe(KH) Co.,Ltd.<br>២. សវនករឯករាជ្យ មានចំនួន ០៣ រូប ៖<br>• លោក Poon Yew Hoe<br>• លោក Onn Kien Hoe<br>• លោក Chan Kuan Chee | អគារលេខ ១៤៨ ផ្លូវ ២៤៥ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ។<br>ទូរស័ព្ទ : ០២៣ ២១៦ ៧១៧<br>ទូរសារ : ០២៣ ២១៦ ៧២៧<br>អ៊ីម៉ែល : info@crowe.com.kh<br>គេហទំព័រ : www.crowe.com.kh |
| ១. ក្រុមហ៊ុន ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី<br>DELOITTE (CAMBODIA) CO., LTD<br>២. សវនករឯករាជ្យ មានចំនួន ០២ រូប ៖<br>• លោក ខូយ គឹមលេង<br>• លោក អ៊ឹង គឹមសុភ័ក្រ្តា | ជាន់ទី៨ អគារ វឌ្ឍនៈកាពីតាល់ លេខ ៦៦ មហាវិថីព្រះមុន្នីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៣ ៧៧៧<br>ទូរសារ : ០២៣ ៩៦៣ ៧៧៨<br>អ៊ីម៉ែល : khinfo@deloitte.com<br>គេហទំព័រ : www.deloitte.com/kh |

| | |
|---|---|
| ១. ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក<br>Baker Tilly (Cambodia) Co., Ltd<br>២. សវនករឯករាជ្យ មានចំនួន ០៦ រូប ៖<br>• លោក TAN KHEE MENG<br>• លោក ANDREW HENG<br>• លោក FU JOE HENG<br>• លោក LOCK PENG KUAN<br>• លោក Teh Chhay Haw<br>• លោក ពៅ ដារ៉ា | ផ្ទះលេខ ៨៧ B ផ្លូវលេខ ២៩៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៨៧ ១០០<br>ទូរសារ : ០២៣ ៩៨៧ ៣៨៨<br>អ៊ីម៉ែល : info@bakertilly.com.kh<br>គេហទំព័រ : www.bakertilly.com.kh |
| ១. ក្រុមហ៊ុន រីចស៍ & ផាតនើរ<br>REACHS & PARTNERS CO., LTD.<br>២. សវនករឯករាជ្យ មានចំនួន ០២ រូប ៖<br>• លោក អេ ប៊ុនថេត<br>• លោក រឿន ប៊ុនហេង | ផ្ទះលេខ ២២៨៣ ២២៨២ ២៣៩៩ ជាន់ផ្ទាល់ដី បន្ទប់G០១ ជាន់ទី១ បន្ទប់លេខ ១.០១ និងជាន់ទី២ បន្ទប់លេខ ២. ០១, ផ្លូវលេខ ១៩៧០ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២៣០ ៣៣៣ / ០១២ ៣៥៥ ៩៣៧<br>អ៊ីម៉ែល : info@reachspro.com<br>គេហទំព័រ : www.reachspro.com |
| ១. ក្រុមហ៊ុន អេហ្វអាយអាយ & អឹសូស៊ីអេត<br>Fii & Associates Co., Ltd.<br>២. សវនករឯករាជ្យ មានចំនួន ០៣ រូប ៖<br>• កញ្ញា ហេង សិតា<br>• លោក សេង ចាន់ថន<br>• លោកស្រី ឈុន ម៉ារ៉ា | អគារ C-៧ វិថីវិមានអាហារ ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វា រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០៩៦ ៥៥៥ ១៤ ៥៥<br>អ៊ីម៉ែល : info@3e-fii.com<br>គេហទំព័រ : www.fii-a.com |
| ១. ក្រុមហ៊ុន ប៊ីជី អាសូស៊ីអឹត<br>BG Associate Ltd.<br>២. សវនករឯករាជ្យ មានចំនួន ០៣ រូប ៖<br>• លោក ហុង ពិសិដ្ឋ<br>• លោកស្រី យឹម ណារី | អគារ Garden In The Air ជាន់ទី៣៣A បន្ទប់លេខ G៣៣A០២A ផ្លូវសុរកមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២១៨ ៤២៦ /០១២ ២១៨ ៤២៦<br>អ៊ីម៉ែល : info@bga.cambodia.com |

| | |
|---|---|
| • លោកស្រី ថ្លាង ស៊ីវឆេង<br>៣.បុគ្គលចំនួន ២ (ពីរ) រូប ត្រូវបានទទួលស្គាល់ក្នុងក្របខណ្ឌនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ៖<br>• លោក Arthur Law Hian Tat<br>• លោក Gabriel Teo Chun | គេហទំព័រ : www.moore-global.com/locations/bg-associates-ltd-phnom-penh |

### ១.៤.៨. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ

ក្រុមហ៊ុនបោះផ្សាយ ចាំបាច់ត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ ឬបុគ្គលវាយតម្លៃឯករាជ្យ ប្រសិនបើក្រុមហ៊ុនកាន់កាប់ទ្រព្យសម្បត្តិ ដីធ្លី ឬបរិក្ខារដែលត្រូវ វាយតម្លៃឡើងវិញ។ ក្រុមហ៊ុនវាយតម្លៃត្រូវរៀបចំរបាយការណ៍វាយតម្លៃដែលជាផ្នែកមួយនៃដំណើរការចុះបញ្ជី។ ក្រុមហ៊ុនវាយតម្លៃត្រូវរៀបចំរបាយការណ៍វាយតម្លៃដែលទទួលបានការទទួលស្គាល់ពី ន.ម.ក. មានចំនួន ៣ ក្រុមហ៊ុន៖

**តារាងទី ១.៣៖** តារាងនៃក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ

| | |
|---|---|
| ១.ក្រុមហ៊ុន វីត្រាស់ អេព្រេហ្សល<br>VTRUST APPRAISAL Co.,Ltd.<br>២.អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០៤ រូប៖<br>• លោក ភិន សុធារ<br>• លោក យឿន វាយោ<br>• លោក ជា សារ៉ាក<br>• លោក រស់ សារ៉ាយ | អគារលេខ១៤ ផ្លូវលេខ៣៤៩ ភូមិ៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ<br>ទូរស័ព្ទ :០២៣ ៨៨ ៤៤ ៣៧<br>អ៊ីម៉ែល : info@vtrustappraisal.com<br>គេហទំព័រ : www.vtrustappraisal.com |
| ១.ក្រុមហ៊ុន ណាយ ហ្វ្រែង (ខេមបូឌា)<br>Knight Frank (Cambodia) Pte., Ltd<br>២. អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០២ រូប៖<br>• លោក ROSS WHEBLE<br>• លោក ឡុង សេងគ្រី | បន្ទប់លេខ ១៦ B ជាន់ទី១៦ អគារកាណាឌីយ៉ា ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៦ ៨៧៨<br>ទូរស័ព្ទដៃ : ០១៥ ៥៣២ ០៧៥<br>ទូរសារ : ០២៣ ៩៨៦ ៦៤៨<br>អ៊ីម៉ែល : ross.wheble@kh.knightfrank.com<br>គេហទំព័រ : www.knightfrank.com.kh |

| | |
|---|---|
| ១.ក្រុមហ៊ុន អ៊ែតវ៉ាន់ធិច ប្រផឹធី សឺវីស ឯ.ក<br>Advantage Property Services Co., Ltd<br>២. អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០២ រូបៈ<br>• លោក SNOWLING LENNON LAWRENCE JOHN<br>• កញ្ញា ជិន ច័ន្ទដាលុច្ស | អគារលេខ១៤៦ ជាន់ទី១០ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៤ ០៩៩<br>អ៊ីម៉ែល : cambodia@cbre.com<br>គេហទំព័រ : www.cbre.com.kh |

### ១.៤.៩. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រគឺ ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដូចជាៈ ការផ្ទេរប្រាក់ ឬការបង្វែរសាច់ប្រាក់ រវាងគូភាគីជួញដូរ។ ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ប្រកបដោយសុវត្ថិភាព។ បំពេញប្រតិបត្តិការឱ្យដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ។ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រនៅក្នុងផ្សារមូលបត្ររួមមានៈ[14]

- ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
- ធនាគារ កាណាឌីយ៉ា ក.អ (Canadia Bank Plc.)
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (Bank for Investment and Development of Cambodia Plc.)
- ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី (Cambodian Public Bank Plc.)
- ធនាគារ ប៊ី. អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក (B.I.C (Cambodia) Bank Plc.)
- ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (Advanced Bank of Asia Limited)
- ធនាគារ វីង (ខេមបូឌា) ម.ក (Wing Bank (Cambodia) Plc.)

### ១.៤.១០. ភ្នាក់ងារបញ្ជីកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

ភ្នាក់ងារបញ្ជីកាមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់គឺសំដៅដល់អ្នកដែលទទួលបាននូវការអនុញ្ញាតក្នុងការផ្ដល់សេវាក្នុងនាមជាក្រុមហ៊ុនបោះផ្សាយដែលនៅក្នុងនោះៈ

[14] https://www.serc.gov.kh/khmer/m53.php?pn=6 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

- ភ្នាក់ងារបញ្ជីកាមូលបត្រ ៖ គ្រប់គ្រងនូវដំណើរការបរិវិសកម្មបែងចែកមូលបត្រឲ្យបានត្រឹមត្រូវកត់ត្រាបញ្ជីកម្មសិទ្ធិមូលបត្រធ្វើរបាយការណ៍ឲ្យក្រុមហ៊ុនបោះផ្សាយ និងនិយ័តករមូលបត្រកម្ពុជា ស្ដីពីការបញ្ចប់ដំណើរការបរិវិសកម្ម និងជូនដំណឹងដល់កម្មសិទ្ធិករមូលបត្រជាដើម។
- ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ៖ ពេលដែលមូលបត្រកម្មសិទ្ធិត្រូវបានបែងចែកទៅឱ្យអ្នកធ្វើបរិវិសកម្មរួច ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រត្រូវរក្សានិងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រធ្វើរបាយការណ៍ទាក់ទងទៅនឹងការផ្លាស់ប្ដូរកម្មសិទ្ធិ បញ្ជូនរបាយការណ៍ និងព័ត៌មានផ្សេងៗរួមមានការបែងចែកភាគលាភ ការបង់ប្រាក់ជាជូនដល់កម្មសិទ្ធិករមូលបត្រ និងសេវាពាក់ព័ន្ធផ្សេងៗ។
- ភ្នាក់ងារទូទាត់មូលបត្រ ៖ ដើរតួជាអ្នកគណនាភាគលាភ ការប្រាក់ ប្រាក់ដើមជាដើមទៅតាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ រួចហើយធ្វើការទូទាត់ជូនកម្មសិទ្ធិករមូលបត្រ និងភាគីពាក់ព័ន្ធរៀបចំរបាយការណ៍ និងបញ្ជូនព័ត៌មានចាំបាច់ទាក់ទងទៅនឹងការទូទាត់។ ខាងក្រោមនេះជាបញ្ជីឈ្មោះភ្នាក់ងារបញ្ជីកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់៖[15]

**តារាងទី ១.៤៖** តារាងនៃក្រុមហ៊ុនភ្នាក់ងារបញ្ជីកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

| នាមករណ៍ក្រុមហ៊ុន | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|
| ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | អាគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៩៨ ៧៧៧<br>ទូរសារ : ០២៣ ៩៩៨ ៦៦៦<br>អ៊ីម៉ែល : acledabank@acledabank.com.kh<br>គេហទំព័រ : www.acledabank.com.kh |
| ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី<br>Tricor Securities Services PLC. | អាគារលេខ អាអា០៦ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៨៧ ១០០<br>ទូរសារ : ០២៣ ៩៨៧ ៣៨៨<br>អ៊ីម៉ែល : info@tricorcambodia.com<br>គេហទំព័រ : www.tricorcambodia.com |

[15] https://www.serc.gov.kh/khmer/m53.php?pn=6 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

| | |
|---|---|
| ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities PLC. | អគារ វីត្រាស់ ថៅវ័រ ជាន់ទី២ មហាវិថីឆេកូស្លូវ៉ាគី (១៦៩) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៤២ ៦៩ ៩៩<br>អ៊ីម៉ែល : info@pps.com.kh<br>គេហទំព័រ : www.pps.com.kh |
| ធនាគារ វីង (ខេមបូឌា) ម.ក<br>Wing Bank (Cambodia) Plc. | វីងថៅវើ មហាវិថីព្រះមុនីវង្ស (ផ្លូវលេខ ៩៣) កែងមហាវិថីកម្ពុជាក្រោម (ផ្លូវលេខ ១២៨) ភូមិ៦ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>ទូរស័ព្ទ : (+៨៥៥) ២៣ ៩៩៩ ៩៨៩<br>អ៊ីម៉ែល : care.centre@wingbank.com.kh<br>គេហទំព័រ : www.wingbank.com.kh |

### ១.៤.១១. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល មានតួនាទីការពារផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល តាមដានទ្រព្យធានា តាមដានការអនុវត្តលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់ (Terms and Conditions) និងកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។ ដោះស្រាយការទាមទាររបស់ម្ចាស់មូលបត្របំណុលធានាថាមូលបត្របំណុលដែលបានធ្វើបដិវត្ត ឬទាត់សងត្រូវធ្វើឡើងដោយអនុលោមតាមលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់។ ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលមានដូចជា៖

**តារាងទី ១.៥៖** តារាងនៃភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

| នាមករណ៍ក្រុមហ៊ុន | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|
| អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី<br>ACLEDA Securities Plc. | នៅជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានី ភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៧២៣ ៣៨៨<br>ទូរសារ : ០២៣ ៧២៣ ៣៧៧<br>អ៊ីម៉ែល : info@acledasecurities.com.kh<br>acs.admin@acledasecurities.com.kh<br>គេហទំព័រ : www.acledasecurities.com.kh |

| | |
|---|---|
| កាណា ស៊ីឃ្យូរីធី អិលធីឌី<br>Cana Securities Ltd. | វិមានកាណាឌីយ៉ា ជាន់ទី ១៥ លេខ៣១៥ ផ្លូវព្រះអង្គឌួង កែងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៩៩ ៨៨៧ / ០២៣ ៨៦៨ ២២២<br>ទូរសារ : ០២៣ ៩៩០ ៦៨៦<br>អ៊ីម៉ែល : info@canasecurities.com.kh<br>គេហទំព័រ : www.canasecurities.com.kh |
| ធនាគារ វីង (ខេមបូឌា) ម.ក<br>Wing Bank (Cambodia) Plc | អគារលេខ ៧២១ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>ទូរស័ព្ទ : ០២៣ ៩៩៩ ៩៨៩ / ០៧៧ ៩៨៨ ៦៨៥<br>អ៊ីម៉ែល : care.centre@wingbank.com.kh<br>គេហទំព័រ : www.wingbank.com.kh |

## ១.៥. លក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ

ទីផ្សារមូលបត្រកម្ពុជាមាន២គឺ ទីផ្សារគោល និងទីផ្សារកំណើន។[16]

- **ទីផ្សារគោល** គឺជាផ្សារដំបូងបង្អស់ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការសម្រាប់ការចុះបញ្ជីរបស់ក្រុមហ៊ុនចុះបញ្ជីសក្តានុពលដែលមានស្តង់ដារ និងទំហំធំ។ ទីផ្សារនេះនឹងអនុញ្ញាតឱ្យក្រុមហ៊ុននាំយកភាគហ៊ុនទាំងអស់ក្រោយការបោះផ្សាយ មកចុះបញ្ជីនិងជួញដូរនៅក្នុងប្រព័ន្ធរបស់ ផ.ម.ក. ។
- **ទីផ្សារកំណើន** ជាទីផ្សារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀត សម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះ ដែលមានផលរបរសរុបប្រចាំឆ្នាំលើសពី ១០ពាន់លានដុល្លារអាមេរិក និងបង្កើតការងារចំនួន ១,៣ លានផងដែរ។

[16] https://csx.com.kh/kh/product/growthboard.jsp?MNCD=30103 (បានចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

### ១.៥.១. លក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ដើម្បីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបានក្រុមហ៊ុនត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖[17]

**តារាងទី ១.៦៖** តារាងអំពីលក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

| ល.រ | ទីផ្សារគោល | ទីផ្សារកំណើន |
|---|---|---|
| ១ | ត្រូវតែជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត(PLC) ឬនីតិបុគ្គលប្រតិស្រុត | |
| ២ | ត្រូវមានរបាយការណ៍ហិរញ្ញប្រវត្តិសាស្ត្រ និង/ឬ របាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម រយៈពេល ២ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ | ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម រយៈពេល ១ឆ្នាំ នៃឆ្នាំសារពើពន្ធចុងក្រោយដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។ |
| ៣ | ត្រូវមានមូលធនភាគហ៊ុនិក (Shareholder's equity) យ៉ាងតិច៣០ពាន់លានរៀល (ប្រហែល ៧,៥លានដុល្លារអាមេរិក)។ | ត្រូវមានមូលធនភាគហ៊ុនិក (Shareholder's equity) យ៉ាងតិច២ពាន់លានរៀល (ប្រហែល 0,៥លានដុល្លារអាមេរិក)។ |
| ៤ | ត្រូវមានប្រាក់ចំណេញសុទ្ធ (Net Profit) យ៉ាងតិច ២ពាន់រៀល (ប្រហែល ០,៥លានដុល្លារអាមេរិក) នៃឆ្នាំសារពើពន្ធចុងក្រោយ និង៣ពាន់លានរៀល (ប្រហែល ០,៧៥លានដុល្លារអាមេរិក) សម្រាប់រយៈពេល ២ឆ្នាំចុងក្រោយ។ | ត្រូវមានប្រាក់ចំណេញសុទ្ធ (Net Profit) នៅសារពើពន្ធចុងក្រោយ ឬមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន និងមានអត្រាចំណេញដុលយ៉ាងហោចណាស់១០%។ |
| ៥ | ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ | |
| ៦ | ត្រូវមានសកម្មភាពធុរកិច្ចស្របនឹងផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច និងធានានិរន្តភាពប្រតិបត្តិការធុរកិច្ច។ | |
| ៧ | ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ | |
| ៨ | ត្រូវមានឯកសារផ្តល់ព័ត៌មាន (Disclosure Document)។ | |

### ១.៥.២. លក្ខខណ្ឌតម្រូវដើម្បីចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ

ដើម្បីចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ក្រុមហ៊ុនត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

[17] ប្រកាសស្តីពី "ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

**តារាងទី ១.៧៖** តារាងអំពីលក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីលក់ក្នុងមូលបត្រជាសាធារណៈ

| លក្ខខណ្ឌបឋម | ទីផ្សារគោល | ទីផ្សារកំណើន |
|---|---|---|
| មូលធនភាគហ៊ុនិក | ៣០ពាន់លានរៀល (៧,៥លានដុល្លារអាម៉េរិក) | ២ពាន់លានរៀល(0,៥លានដុល្លារអាម៉េរិក) |
| ប្រាក់ចំណេញសុទ្ធ | ≥ ២ពាន់លានរៀល (៥00,000ដុល្លារអាម៉េរិក) សម្រាប់ឆ្នាំចុងក្រោយ, ហើយ ≥ ៣ពាន់លានរៀល (៧៥0,000ដុល្លារអាម៉េរិក)នៃប្រាក់ចំណេញសរុបសម្រាប់រយៈពេល២ឆ្នាំចុងក្រោយ | – មានប្រាក់ចំណេញសុទ្ធវិជ្ជមានសម្រាប់ឆ្នាំចុងក្រោយ, ឬ<br>– មានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន និងផលចំណេញសុទ្ធ |
| ភាគហ៊ុនិក | ≥ ២00ភាគហ៊ុនិក, ហើយ<br>≥ ៧% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប | ≥ ១00ភាគហ៊ុនិក, និង<br>≥ ១0%នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប |
| របាយការហិរញ្ញវត្ថុ | ពីរ (២) ឆ្នាំចុងក្រោយ | មួយ (១) ឆ្នាំចុងក្រោយ |
| អភិបាលកិច្ចសាជីវកម្ម | **ក. ក្រុមប្រឹក្សាភិបាល**<br>– សមាជិកក្រុមប្រឹក្សាភិបាល៖ យ៉ាងតិច៥នាក់<br>– អភិបាលឯករាជ្យ > ១/៥នាក់ នៃអភិបាលសរុប<br>– ប្រសិនបើ អភិបាលឯករាជ្យជាជនជាតិបរទេសត្រូវមានបទពិសោធធ្វើការនៅកម្ពុជាយ៉ាងហោចណាស់ ៦ខែ<br>**ខ. គណៈកម្មាធិការ**<br>– គណៈកម្មាធិការសវនកម្ម<br>– គណៈកម្មាធិការតែងតាំងនិងលាភការ | ក. ក្រុមប្រឹក្សាភិបាល<br>– សមាជិកក្រុមប្រឹក្សាភិបាល៖ យ៉ាងតិច៣នាក់<br>– អភិបាលឯករាជ្យ ≥ ១នាក់ ឬ ១/៥ នៃអភិបាលសរុប (ប្រសិនបើសមាជិកក្រុមប្រឹក្សាភិបាលមានអភិបាល ≥ ៥នាក់)<br>– អភិបាលមិនប្រតិបត្តិ (តំណាងឱ្យភាគហ៊ុនិកឯកជន) ≥ ១នាក់<br>**ខ . គណៈកម្មាធិការ**<br>– គណៈកម្មាធិការសវនកម្ម |

| | | |
|---|---|---|
| | – ក្រុមប្រឹក្សាភិបាលអាចពិចារណាបង្កើតគណៈកម្មាធិការ គ្រប់គ្រងហានិភ័យ ឬគណៈកម្មាធិការផ្សេងទៀតតាមការ ចាំបាច់ ឬតាមការតម្រូវរបស់ ន.ម.ក.។ | – គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ៖ ទ្រព្យសកម្ម ≥ ២០០ពាន់លានរៀល (៥០លានដុល្លារអាម៉េរិក)<br>– គណៈកម្មាធិការតែងតាំង (ជម្រើស)<br>– ក្រុមប្រឹក្សាភិបាលអាចពិចារណាបង្កើតគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការ ដទៃទៀតប្រសិនបើចាំបាច់ ឬតាមការតម្រូវរបស់ ន.ម.ក.។ |

## ១.៦. យន្តការក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងក្នុងទីផ្សារមូលបត្រកម្ពុជា

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូងតម្រូវឱ្យ ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាបុគ្គលពាក់ព័ន្ធ គប្បីត្រូវស្វែងយល់អំពីដំណើរការនេះឲ្យបានច្បាស់លាស់ដើម្បីអោយការបោះផ្សាយមានភាពរលូននិងទទួលបានជោគជ័យតាមការរំពឹងទុក។ ជាទូទៅ ដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនគប្បីអនុវត្តតាមគឺមានទាំង ១២ ដំណាក់កាលដូចខាងក្រោមនេះ៖

**យន្តការទី១៖ ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រជាសាធារណៈជូនមកនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.)**

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមកនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ដែលលិខិតមានខ្លឹមសារសំខាន់ ៣ ចំណុចដូចខាងក្រោម៖

១. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

២. គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

៣. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលរំពឹងទុក រួមមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវីឬក្រុមមេធាវីនិងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

**យន្តការទី២៖ ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ**

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រគឺជាដំណាក់កាលដ៏សំខាន់មួយព្រោះថា ក្រុមហ៊ុនធានាទិញមូលបត្រត្រូវផ្តល់សេវាកម្មដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រណាមួយក្នុងចំណោមក្រុមហ៊ុនទាំង ៧ ដែលទទួលបានអាជ្ញាប័ណ្ណពី ន.ម.ក.។

**យន្តការទី៣៖ ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង**

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធមួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលទទួលស្គាល់ពី ន.ម.ក. ដើម្បីចូលរួមក្នុងការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយលើការរជ្រើសរើសក្រុមហ៊ុន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

**យន្តការទី៤៖ ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់**

ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូងដែលរួមមាន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

**យន្តការទី៥៖ ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបាន បញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនមូលបត្រកម្ពុជា**

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនមូលបត្រត្រូវធ្វើការរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**យន្តការទី៦៖ ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក.**

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូបត្រកម្ពុជា នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំឯកសារដាក់ពាក្យដើម្បីស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទៅ ន.ម.ក.។ ហើយ ន.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយ

លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មានមុននឹងផ្តល់ការអនុញ្ញាតជាគោលការលើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។

**យន្តការទី៧៖ ការកំណត់ថ្លៃលក់មូលបុកតាមរយៈប៊ុកបៀលឌីង**

ក្រោយពីទទួលបានការអនុញ្ញាតិជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈ ប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគមុននិងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**យន្តការទី៨៖ ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របានដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រមានន័យថាអាចត្រូវបញ្ចូលទៅក្នុងប្រព័ន្ធជួញដូរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**យន្តការទី៩៖ ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីផ្តល់ព័ត៌មានពី ន.ម.ក.**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនានានៃសំណើលក់ដោយត្រូវធ្វើបច្ចុប្បន្នភាពឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន ន.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**យន្តការទី១០៖ ការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់និង ចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងជំពូកទី ៣ និងទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**យន្តការទី១១៖ ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ**

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផល

នៃការធ្វើបរិវិសកម្មមូលបត្រហើយត្រូវដាក់របាយការណ៍លទ្ធផលនៃបរិវិសកម្មមូលបត្រនេះភ្លាមជូនមកន.ម.ក។

**យន្តការទី១២៖ ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។[18]

## ១.៧. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

### ១.៧.១. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន

ការវិនិយោគនៅលើវិស័យមូលបត្រគឺអាស្រ័យទៅលើការរកស៊ីរបស់ក្រុមហ៊ុន ហើយមុនពេលជ្រើសរើសទិញមូលបត្រ របស់ក្រុមហ៊ុនណាមួយគឺគេបានមើលពីស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពក្រុមហ៊ុនរួចហើយ។ វិនិយោគិនទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រដូចជា៖

- ទទួលបានភាគលាភ (ប្រាក់ចំណូលអកម្ម)៖ នៅពេលក្រុមហ៊ុនបោះផ្សាយទទួលបានជោគ ជ័យក្នុងការវិនិយោគ ម្ចាស់កាន់កាប់មូលបត្រកម្មសិទ្ធិនឹងទទួលបាននូវចំណែកភាគលាភទៅតាមសមាមាត្រនៃសិទ្ធិដែលខ្លួនមាននៅក្នុងក្រុមហ៊ុន និងទទួលបានការប្រាក់ថេរទោះបីក្រុមហ៊ុនបោះផ្សាយទទួលបាន ផលចំណេញ ឬខាតបង់ក៏ដោយចំពោះម្ចាស់កាន់កាប់មូលបត្របំណុល។
- ប្រាក់ចំណេញពីការទិញ-លក់មូលបត្រ (ចំណេញមូលធន)៖ វិនិយោគិននឹងទទួលបានផលចំណេញផ្នែកមូលធននៅពេលដែលតម្លៃមូលបត្ររបស់ខ្លួនឡើងថ្លៃក្នុងទីផ្សារមូលបត្រ។ ម្យ៉ាងវិញទៀត ការវិនិយោគជាមួយភាគហ៊ុនច្រើនក្រុមហ៊ុនផ្សេងៗគ្នា នឹងជួយបង្កើនទ្រព្យសម្បត្តិរបស់វិនិយោគិន តាមរយៈឥទ្ធិពលកំណើនពីវិស័យផ្សេងៗក្នុងសេដ្ឋកិច្ច បើទោះបីជាថ្លៃភាគហ៊ុនខ្លះដែលវិនិយោគិនបានធ្លាក់ថ្លៃក៏ដោយ។
- ការធ្វើពិពិធកម្មការវិនិយោគ (Diversification)៖ វិនិយោគិនតែងមានការប្រើប្រាស់សាច់ ប្រាក់សន្សំច្បាស់លាស់ ដោយតែងតែលៃបម្រុងទុកពី ១៥% ទៅ២០% ដើម្បីវិនិយោគលើមូលបត្រធៀបនឹងការវិនិយោគសរុប។ សម្រាប់វិនិយោគិនដែលដាក់ប្រាក់វិនិយោគច្រើនប្រភេទផ្សេងៗគ្នា ការវិនិយោគក្នុងទីផ្សារមូលបត្រផ្តល់នូវអត្ថប្រយោជន៍សំខាន់មួយគឺពិពិធកម្ម។ ការវិនិយោគក្នុងទីផ្សារមូលបត្រប្រែប្រួលថ្លៃដោយមិនជាប់ទាក់ទងជាមួយការវិនិយោគផ្សេងៗទៀតដូចជាអចលនទ្រព្យនោះទេ។

[18] គោលការណ៍ណែនាំ លេខ០០១ គ.ម.ក./គ.ណ.ន ស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១

ការវិនិយោគក្នុង ទីផ្សារមូលបត្រអាចជួយកាត់បន្ថយការខាតបង់បានខ្លះ ក្នុងករណីវិនិយោគិនមានការខាតបង់ជាមួយការវិនិយោគក្នុងគម្រោងផ្សេងៗទៀត។

- ភាពជាម្ចាស់កម្មសិទ្ធិ៖ ការទិញភាគហ៊ុនគឺមានន័យថា លោកអ្នកទទួលយកចំណែកនៃភាព ជាម្ចាស់កម្មសិទ្ធិពីក្រុមហ៊ុនដែលបានលក់ភាគហ៊ុន ហើយលោកអ្នកក៏មានសិទ្ធិទទួលបាននូវចំណែកនៃប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបានផងដែរ។ ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោត និងមានសិទ្ធិចូលរួមប្រជុំសម្រេចចិត្តក្នុងអាជីកម្មរបស់ក្រុមហ៊ុនតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់កាប់។

**១.៧.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ**

- ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង៖ ការចុះបញ្ជីលក់មូលបត្រជាសាធារណៈផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រទទួលបាននូវប្រភពហិរញ្ញប្បទានថ្មីមួយ ដែលអនុញ្ញាតឱ្យក្រុមហ៊ុននេះ អាចប្រមូលបានមូលធនពីអ្នកវិនិយោគសាធារណៈសម្រាប់ពង្រីកការវិនិយោគ។ បន្ថែមពីនេះទៀត នៅពេលដែលក្រុមហ៊ុនបានចុះបញ្ជីបោះផ្សាយ និងលក់មូលបត្រ ក្រុមហ៊ុននឹងទទួលបានកេរ្តិ៍ឈ្មោះល្អ និងការគាំទ្រពីច្បាប់ ដែលក្រុមហ៊ុនអាចពង្រឹងអំណាចក្នុងការចរចារជាមួយធនាគារពីលទ្ធភាព ក្នុងការទទួលបានឥណទានរួមចំណែកក្នុងការអនុវត្តផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុនផងដែរ។
- ការលើកទឹកចិត្តពន្ធ៖ ក្រុមហ៊ុនទាំងអស់ដែលទទួលបានការអនុញ្ញាតពី ន.ម.ក. បោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ ផ.ម.ក. នឹងត្រូវបានលើកទឹកចិត្តផ្នែកពន្ធដារ។ ក្រុមហ៊ុនបោះផ្សាយទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធ ដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០ (ហាសិប) ភាគរយ ក្នុងរយៈពេលបីឆ្នាំដំបូង ហើយការលើកទឹកចិត្តនេះ នឹងត្រូវផ្តល់ជូនចំពោះការចុះបញ្ជី មុនខែមករា ឆ្នាំ២០២១។ ស្របពេលជាមួយគ្នានេះផងដែរ ក្រុមហ៊ុនក៏ទទួលបានការលើកលែងទាំងស្រុង ចំពោះបំណុលពន្ធលើប្រាក់ចំណេញសម្រាប់រយៈពេល១០ ឆ្នាំសារពើពន្ធកន្លងទៅ ដែលបានរកឃើញ ដោយស្នងការសវនកម្មឯករាជ្យក្រោយការធ្វើសវនកម្មពេញលេញរបស់អគ្គនាយកដ្ឋានពន្ធដារ។ បន្ថែម លើនេះទៀតប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១(មួយ)ភាគរយប្រចាំខែ ត្រូវបានព្យួរជាបណ្តោះអាសន្ន រយៈពេល៣ឆ្នាំ។
- ទទួលបាននិរន្តរភាពអាជីវកម្ម ជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែល រឹងមាំជាងមុន៖ នៅពេលដែលក្រុមហ៊ុនបានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឱ្យប្រសើរឡើង នូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឱ្យមានរចនា សម្ព័ន្ធក្រុមប្រឹក្សាភិបាលដែលនឹងមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើនេះទៀត ម្ចាស់អាជីវកម្ម

អាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រឹមត្រូវ ឬ ការតែបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផលអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រង ផ្ទៃក្នុងនឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឱ្យមានការរីកចំរើនប្រកបដោយនិរន្តរភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម នឹងអាចជួយដល់ការត្រៀមខ្លួនរបស់សហគ្រាសខ្នាតតូចនិងមធ្យម ក្នុងការប្រកួតប្រជែងជាមួយគូប្រកួតប្រជែងក្នុងតំបន់អាស៊ាន។

- ការធ្វើឱ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងភាពមើលឃើញរបស់ក្រុមហ៊ុន៖ ក្រុមហ៊ុនចុះបញ្ជីមួយជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេសតាមរយៈប្រព័ន្ធព័ត៌មាននិងសាធារណជន ហើយកិច្ចប្រតិបត្តិការអាជីវកម្មឬហិរញ្ញវត្ថុ តែងត្រូវបានផ្សព្វផ្សាយតាមរយៈកាសែត និងទូរទស្សន៍ ព្រមទាំងត្រូវបានលើកឡើងទាំងក្នុងនិងក្រៅប្រទេសផងដែរ។ ប្រការនេះអាចជួយកែលម្អ នូវរូបភាពនិងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ដែលអាចឱ្យសាធារណជនស្គាល់កាន់តែច្រើនអំពីផលិតផល និង សេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះ ក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមានុភាពការប្រកួតប្រជែងរបស់ខ្លួនចំពោះដៃគូប្រកួតប្រជែងដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ នៅក្នុងបរិបទនៃសេដ្ឋកិច្ចសកលភាវូបនីយកម្មដែលពោរពេញដោយការប្រកួតប្រជែងនេះ។

### ១.៧.៣. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ

ទីផ្សារមូលបត្រជាឧបករណ៍វាស់ស្ទង់សេដ្ឋកិច្ច មានន័យថា ទីផ្សារមូលបត្រ ត្រូវបានគេចាត់ទុកជាជីពចរនៃសេដ្ឋកិច្ច ឬជាកញ្ចក់ដែលឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ត្បិតទីផ្សារមូលបត្រ ជាសូចនាករសេដ្ឋកិច្ចសំខាន់ ដែលជាជំនួយសម្រាប់វិនិយោគិន ក្នុងការរៀបចំនិងសម្រេចចិត្តវិនិយោគឱ្យបានត្រឹមត្រូវ ហើយទីផ្សារមូលបត្រក៏អាចជួយពង្រីកចំណេះដឹងរបស់ប្រជាជន អំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសផងដែរ។ បន្ថែមពីនេះទីផ្សារមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយដោយវាអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាល អាចប្រមូលទុន ដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម៉្យាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ(ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់ហូរពីអ្នកមាន ឬអ្នកដែលមានសាច់ប្រាក់លើសតម្រូវការ ទៅអ្នកដែលត្រូវការប្រេកប ដោយប្រសិទ្ធភាព ពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជាផលិតកម្ម និងពាណិជ្ជកម្ម នឹងរីកលូតលាស់ទៅតាមនោះដែរព្រមទាំងបង្កើតឱ្យមានឱកាសការងារតាមរយៈការ វិនិយោគបន្ថែម និងបង្កើនទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។ លើសពីនេះ ការកើនឡើងនៃទីផ្សារមូលបត្រកម្ពុជា អាចធ្វើឱ្យមានការ ទាក់ទាញវិនិយោគិនមកប្រទេសកម្ពុជា ពីព្រោះថាក្រុមហ៊ុនបរទេសធំៗ ដែលមានបំណងមក

វិនិយោគនៅកម្ពុជា អាចបោះផ្សាយលក់មូលបត្រនៅទីផ្សារមូលបត្រកម្ពុជា និងវិនិយោគនៅកម្ពុជាតែម្តង។ នៅពេលមានទីផ្សារនេះអាចជួយជំរុញឱ្យក្រុមហ៊ុនត្រូវប្រកាន់ភ្ជាប់នូអភិបាលកិច្ចល្អ តម្លាភាពដោយផ្តល់នូវទំនុកចិត្តដល់សាធារណជន ដែលករណីនេះបង្កើតមានបរិយាកាសប្រកួតប្រជែង រវាងក្រុមហ៊ុនដែល មានអភិបាលកិច្ចល្អ មានតម្លាភាព និងក្រុមហ៊ុនដែលមានអភិបាលកិច្ចល្អ និងគ្មានតម្លាភាព។ ដូច្នេះ ទីផ្សារមូលបត្រមានសារៈសំខាន់សម្រាប់ជួយជំរុញឱ្យប្រភពមូលធនក្នុងស្រុកមានចលនារស់រវើក និងជាការពង្រីកនូវប្រភពហិរញ្ញវត្ថុសម្រាប់កំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសកម្ពុជា។[19]

[19] ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ ទំព័រទី៤ ដល់៦

# ជំពូកទី ២
# ស្ថានភាពទូទៅរបស់ក្រុមហ៊ុន
# ម៉េចលី ជេ. គ្លួច អេឌ្យូខេសិន ម.ក

# ជំពូកទី២
# ស្ថានភាពទូទៅរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

## ២.១. ប្រវត្តិក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ត្រូវបានបង្កើតនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនបានស្នើសុំការអនុញ្ញាតលើការផ្លាស់ប្តូរទម្រង់ទ្រាយក្រុមហ៊ុនពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដោយទទួលបានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារលើការផ្លាស់ប្តូរនេះ និងបានធ្វើវិសោធនកម្មលក្ខន្តិកៈក្រុមហ៊ុនចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ ដោយមានប្រថាប់ត្រារបស់ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨។

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិនជាគ្រឹះស្ថានអប់រំឯកជនឈានមុខគេមួយនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុននេះបានចូលរួមចំណែកជាចម្បងក្នុងការផ្តល់សេវាអប់រំដ៏ទូលំទូលាយ ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ នៅសាលារៀនអន្តរទ្វីបអាមេរិកាំង («AIS») និងផ្នែកភាសា (ភាសាអង់គ្លេស ភាសាចិន និងភាសាថៃ) ការបណ្តុះបណ្តាលឯកទេស និងការបណ្តុះបណ្តាលគរុកោសល្យគ្រូបង្រៀននៅមជ្ឈមណ្ឌលភាសា អេ អាយ អាយ («Aii»)។ ក្រុមហ៊ុនក៏ផ្តល់ផងដែរនូវសេវាកម្មក្នុងការនាំសិស្សទៅសិក្សានៅក្រៅប្រទេសតាមរយៈកម្មវិធី («SOGO») និងកម្មវិធីអនឡាញ (« i-Learn»)។

សាខាដំបូងរបស់ Aii ត្រូវបានបង្កើតឡើង នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ និងបន្តបើកសាខា AIS នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥។ ពេលដែលបើកដំបូង ក្រុមហ៊ុនមានអគារសិក្សាចំនួន ១ ខ្នង បុគ្គលិកចំនួន ៥ នាក់ និងសិស្សចំនួន ៤ នាក់។ ឥឡូវនេះក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានទីតាំងចំនួន ១៥ សាខា ដែលមានអគារសិក្សាសរុបចំនួន ២២ ខ្នង សិស្សមានចំនួនជាង ២០.០០០ នាក់បុគ្គលិក និងគ្រូបង្រៀនជាង ២.០០០ នាក់ និងមានអតីតសិស្សជាង ៥០.០០០ នាក់។

ក្រុមហ៊ុនផ្តោតលើការអប់រំប្រកបដោយគុណភាព សេវាកម្មស្តង់ដាខ្ពស់ និងបរិក្ខារសិក្សាបង្រៀនទំនើបៗ។ លើសពីនេះ កេរ្តិ៍ឈ្មោះដ៏យូរអង្វែងរបស់ក្រុមហ៊ុននេះ គឺជាចំណុចខ្លាំងមួយដែលអាចកំណត់ឱ្យពួកគេឈរលើទីតាំងមួយដែលដាច់ចេញពីគូប្រគួតប្រជែងរបស់ខ្លួន។

អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ជេ. គួច ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ គឺជាកម្លាំងចលករដ៏សំខាន់មួយនៅពីក្រោយភាពជោគជ័យរបស់ក្រុមហ៊ុន។ លោកបានបង្កើត

ក្រុមហ៊ុនដែលផ្តោតលើការអប់រំប្រកបដោយគុណភាព ដោយលោកជឿជាក់យ៉ាងមោះមុតថាការអប់រំគឺជាគន្លឹះក្នុងការលើកកម្ពស់សមធម៌សង្គមមាឱ្យមានភាពសុខដុមរមនា។

ក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ដោយការបើកដំណើរការ Aii សាខាម៉ៅសេទុង ដែលមានថ្នាក់ភាសាអង់គ្លេសជាភាសាបរទេស និងជាមជ្ឈមណ្ឌលតេស្ត TOEFL iBT ជាផ្លូវការក្នុងប្រទេសកម្ពុជា។

ក្រោយមក AIS ត្រូវបានសម្ពោធដាក់ឲដំណើរការនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ ជាសាលាចំណេះដឹងទូទៅឯកជនដែលផ្តល់ការអប់រំតាមកម្មវិធីជាតិ ដោយប្រើវិធីសាស្ត្របង្រៀនតាមបែបអាមេរិកាំង ចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២។

ក្នុងឆ្នាំ២០១៣ ក្រុមហ៊ុនបានចាប់ផ្តើមកម្មវិធីសិក្សាភាសាចិន (CSL) ។ កម្មវិធីសិក្សាភាសាចិន (CLS) ផ្តល់ជូននូវវគ្គសិក្សាភាសាចិនកុកងឺ ចាប់ពីកម្រិតដំបូងរហូតដល់កម្រិតខ្ពស់។ កម្មវិធីសិក្សានេះបានប្រើវិធីសាស្ត្ររួមបញ្ចូលគ្នាទៅនឹងជំនាញភាសាមូលដ្ឋាននៃការស្តាប់ ការនិយាយ ការអាន និងការសរសេរ។ បច្ចុប្បន្ននេះ សាលាមានសិស្សជាង ១.០០០ នាក់ហើយដែលបានចុះឈ្មោះក្នុងកម្មវិធីសិក្សាភាសាចិន (CSL)។

ក្នុងឆ្នាំ២០១៤ ក្រុមហ៊ុនបានបើកដំណើរការ Aii និង AIS សាខាទួលគោក។ ក្នុងរយៈពេលតែមួយឆ្នាំ Aii សាខាទួលគោកមានសិស្សចុះឈ្មោះចូលសិក្សាចំនួន ៨៥២ នាក់ ហើយនាពេលបច្ចុប្បន្នកំពុងដំណើរការប្រកបដោយភាពល្អប្រសើរ ដែលអាចទទួលសិស្សបានប្រមាណ ១.៥០០នាក់។ សម្រាប់ AIS សាខាទួលគោកនៅឆ្នាំដំបូងរបស់ខ្លួនសាខាមួយនេះទទួលបានសិស្ស ៧០៩ នាក់ហើយបច្ចុប្បន្នក៏កំពុងដំណើរការប្រកបដោយភាពល្អប្រសើរផងដែរ ដែលបានទទួលសិស្សសរុបប្រមាណ ២.២៥០នាក់។ បច្ចុប្បន្នសាខា AIS ទួលគោក គឺជាសាខាធំទីពីររបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក។

ក្រុមហ៊ុននេះបានពង្រីកសាខាទីបីនៅចាក់អង្រែក្នុងឆ្នាំ២០១៥។ ទីតាំងសាលាត្រូវបានបង្កើតឡើងដើម្បីសម្រាលបញ្ហាការធ្វើដំណើរ និងបំពេញតម្រូវការសម្រាប់វិស័យអប់រំប្រកបដោយគុណភាពនៅក្នុងតំបន់ដែលមានប្រាក់ចំណូលមធ្យមទៅខ្ពស់ស្ថិតនៅជាយក្រុង។

នៅក្នុងឆ្នាំ ២០១៦ Aii បានចុះអនុស្សរណៈនៃការយោគយល់ជាមួយកម្មវិធីអន្តរជាតិ AYC Thailand ដើម្បីបើកដំណើរការមជ្ឈមណ្ឌលបណ្តុះបណ្តាលគរុកោសល្យគ្រូបង្រៀន (TESOL House) និងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់អ្នកដែលកំពុងស្វែងរកការងារអាជីពជាគ្រូបង្រៀន។ ស្របពេលជាមួយគ្នានេះមជ្ឈមណ្ឌលបណ្តុះបណ្តាលគរុកោសល្យគ្រូបង្រៀនមួយនេះបម្រើជាមជ្ឈមណ្ឌលវិធីសាស្ត្របង្រៀនសម្រាប់លោកគ្រូ អ្នកគ្រូ របស់ Aii និង AIS ផងដែរ ដើម្បីបំពេញផែនការពង្រីករបស់ស្ថាប័នទាំងពីរ។

នៅឆ្នាំ២០១៩ ក្រុមហ៊ុនបានចាប់ផ្តើមផែនការពង្រីកដ៏ធំរបស់ខ្លួន ដោយបានបើកសាខាថ្មីចំនួន ៦ ពី Aii និង AIS សាខាចោមចៅ Aii និង AIS សាខាផ្សារថ្មី និង Aii និង AIS សាខាជ្រោយចង្វារដើម្បីបំពេញតម្រូវការតាមតំបន់ជាច្រើនទៀតនៃរាជធានីភ្នំពេញ។

ក្រុមហ៊ុនបានបើកសាខាដំបូងដែលមានទីតាំងនៅក្រៅពីទីក្រុងភ្នំពេញ គឺសាខាខេត្តសៀមរាប និងសាខាខេត្តតាកែវក្នុងឆ្នាំ ២០២២។ សាខាខេត្តថ្មីទាំងនេះបានបង្ហាញនូវតម្រូវការយ៉ាងខ្លាំងលើសេវាអប់រំរបស់ក្រុមហ៊ុននៅតាមបណ្តាខេត្ត។ ក្រុមហ៊ុនមានបំណងប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពី IPO ដើម្បីផ្តល់មូលនិធិដល់ការសាងសង់សាខាថ្មីចំនួនប្រាំមួយគឺ Aii និង AIS សាខាច្បារអំពៅ (ii) Aii និង AIS សាខាកំពង់ចាម និង Aii និង AISសាខាបាត់ដំបង។ ក្រុមហ៊ុនក៏បានបម្រុងទីតាំងសម្រាប់ការពង្រីកសាខាថ្មីផងដែរ។ នៅដំណាច់ឆ្នាំ២០២៣ ដោយបូករួមជាមួយនឹង សាខាសែនសុខ និង សាខាខេត្តតាកែវ ដែលបានកំពុងដំណើរការសាងសង់ក្រុមហ៊ុននឹងមានសាខាសរុបចំនួន ២៤។[20]

## ២.២. បេសកកម្ម ចក្ខុវិស័យនិងគុណតម្លៃស្នូលរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានបេសកកម្ម ចក្ខុវិស័យ និងគុណតម្លៃស្នូល ដូចជា៖

### ២.២.១. បេសកកម្មរបស់ក្រុមហ៊ុន

ក្រុមហ៊ុនម៉េងលី ជេ. គួចអេឌ្យូខេសិន ម.ក មានបេសកកម្មក្នុងការផ្តល់ចំណេះដឹងពិតដល់សិស្សានុសិស្សទូទៅតាមរយៈការបង្រៀនដែលប្រកបដោយគុណភាពការបំពាក់បរិក្ខារសិក្សាទំនើបៗ និងការប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយបំផុតក្នុងការសិក្សាស្រាវជ្រាវដោយអមជាមួយនឹងសកម្មភាពច្នៃប្រឌិតរបស់លោកគ្រូ អ្នកគ្រូ ដើម្បីលើកកម្ពស់ការសិក្សា និងបទពិសោធន៏រៀនសូត្រ របស់សិស្សនុសិស្សនិងសាធារណជនទូទៅ។

### ២.២.២. ចក្ខុវិស័យរបស់ក្រុមហ៊ុន

ក្រុមហ៊ុនម៉េងលី ជេ. គួចអេឌ្យូខេសិន ម.ក មានចក្ខុវិស័យច្បាស់លាស់ក្នុងការក្លាយខ្លួនទៅជាគ្រឹះស្ថានអប់រំឈានមុខគេក្នុងប្រទេសកម្ពុជា ដែលផ្តោតសំខាន់បំផុតទៅលើគុណភាព វិន័យ និងសេវាកម្ម។

### ២.២.៣. គុណតម្លៃស្នូលរបស់ក្រុមហ៊ុន

គុណតម្លៃស្នូលរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួចអេឌ្យូខេសិន ម.ក មានដូចខាងក្រោម៖

- ការបំពេញចិត្តអតិថិជន
- គណនេយ្យភាព
- តុល្យភាព
- ការទំនាក់ទំនងដោយបើកចំហរ
- ការបែងចែកភារកិច្ច និងសិទ្ធិសម្រេច
- ការងារជាក្រុម
- សុចរិតភាព
- ការគោរពគ្នាទៅវិញទៅមក
- ការផ្តោតទៅលើលទ្ធផលជាចម្បង
- សហគមន៍ និងបរិស្ថាន

[20] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី១៖ សេចក្តីសង្ខេបនៃឯកសាផ្តល់ព័ត៌មាន ទំព័រទី០១ ដល់០៣

## ២.៣. រចនាសម្ព័ន្ធ និងព័ត៌មានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានរចនាសម្ព័ន្ធ និងព័ត៌មានក្រុមប្រឹក្សាភិបាល ដូចតទៅៈ

### ២.៣.១. រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន

រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.កមានដូចខាងក្រោមៈ[21]

**រូបភាពទី ២.១៖** ដ្យាក្រាមរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន




[21] របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ក្រុមហ៊ុនម៉េលី ជេ. គួច អេឌ្យូខេសិន ម.ក ផ្នែកទី៣៖ ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ទំព័រទី២០

### ២.៣.២. ព័ត៌មានក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់

សមាសភាពនៃក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានដូចខាងក្រោមៈ

**ក. ក្រុមប្រឹក្សាភិបាល**

**តារាងទី ២.១៖** តារាងបញ្ជីឈ្មោះក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល |
|---|---|---|---|
| ១ | អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ | ៥ កញ្ញា ២០១២ |
| ២ | លោក គួច អាឡិច | អភិបាលប្រតិបត្តិ | ២៣ កុម្ភៈ ២០១៧ |
| ៣ | លោក គួច ផល | អភិបាលប្រតិបត្តិ | ៥ កញ្ញា ២០១៧ |
| ៤ | លោកជំទាវ អ៊ឹង លីហុង | អភិបាលប្រតិបត្តិ | ៤ តុលា ២០១៧ |
| ៥ | លោក គង់ វ៉ារ៉ា | អភិបាលឯករាជ្យ | ១៦ មករា ២០២៣ |

ឈ្មោះលេខាធិការរបស់ក្រុមហ៊ុនម៉េងលី ជេ គួច. អេឌ្យូខេសិន ម.ក គឺ កញ្ញា ស្រេង លាភា។

**ខ. បុគ្គលិកជាន់ខ្ពស់**

**តារាងទី ២.២៖** តារាងបញ្ជីឈ្មោះបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ប្រុស | ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ |
| ២ | លោក ឡាយ សុភា | ប្រុស | ប្រធាននៃមជ្ឈមណ្ឌលភាសា អេ អាយ អាយ |
| ៣ | លោកស្រី រស់ យ៉ាណា | ស្រី | ប្រធាននៃសាលារៀនអន្តរទ្វីប អាមេរិកាំង |
| ៤ | លោក សួង ចន្ថាត | ប្រុស | នាយកផ្នែកប្រតិបត្តិការជាន់ខ្ពស់ |
| ៥ | លោក សាវេត ញាណបញ្ញា | ប្រុស | នាយកផ្នែកហិរញ្ញវត្ថុជាន់ខ្ពស់ |
| ៦ | កញ្ញា ស្រេង លាភា | ស្រី | ប្រធានបុគ្គលិក |
| ៧ | លោក វង្ស សុវណ្ណារ័ត្ន | ប្រុស | នាយកផ្នែករដ្ឋបាល |
| ៨ | លោក តាំង សំអៀង | ប្រុស | នាយកផ្នែកព័ត៌មានវិទ្យា |
| ៩ | លោកស្រី សុង ចរិយា | ស្រី | នាយិកាស្តីទីផ្នែកធនធានមនុស្ស |

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ក្រុមហ៊ុនម៉េលី ជេ. គួច អេឌ្យូខេសិន ម.ក ផ្នែកទី៣៖ ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្មទំព័រទី២១

## ២.៤. អត្ថប្រយោជន៍ប្រកួតប្រជែង ផែនការអនាគត និងយុទ្ធសាស្ត្រអាជីវកម្ម

### ២.៤.១. អត្ថប្រយោជន៍ប្រកួតប្រជែង

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានចំណុចគាំទ្រសំខាន់ៗ និងគុណសម្បត្តិប្រកួតប្រជែង ដើម្បីទ្រទ្រង់អាជីវកម្ម ក៏ដូចជាគាំទ្រ ដល់ការរីកចម្រើនរបស់ក្រុមហ៊ុន។ អត្ថប្រយោជន៍ប្រកួតប្រជែងសំខាន់ៗ ទាំងនេះមានដូចខាងក្រោម៖

- ស្ថាប័ននេះត្រូវបានទទួលស្គាល់ជាស្ថាប័នអប់រំដែលមានគុណភាពខ្ពស់
- ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេទ្យខេសិន ម.ក អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី គឺជាបុគ្គលសាធារណៈ ដ៏ល្បីល្បាញក្នុងសហគមន៍អាជីវកម្ម
- ស្ថាប័ននេះគឺជាមហាគ្រួសារមួយដែលមានលោកគ្រូ អ្នកគ្រូ និងបុគ្គលិក ដែលមាន ទឹកចិត្តក្នុងការបំពេញការងារខ្ពស់ និងពោរពេញដោយសមត្ថភាព
- ស្ថាប័ននេះបានវិនិយោគយ៉ាងច្រើនទៅលើការបង្កើតសាខាថ្មីៗ និងបរិក្ខារទំនើបៗ ដែលបង្កើតឱ្យមានបរិស្ថានសិក្សាយ៉ាងល្អឥតខ្ចោះសម្រាប់សិស្សានុសិស្ស
- ទំហំ និងសេដ្ឋកិច្ចវិមាត្ររបស់ក្រុមហ៊ុននេះបានអនុញ្ញាតឱ្យពួកគេអាចបន្តវិនិយោគទៅលើ សេវាកម្ម និងនៅតែអាចរក្សាបាននូវភាពខ្លាំងនៃការប្រកួតប្រជែង
- ទីផ្សារគោលដៅរបស់ពួកគេគឺ មាតាបិតា ឬ អាណាព្យាបាលដែលមានជីវភាពមធ្យម និងលើមធ្យម
- ក្រុមហ៊ុននេះមានកម្មវិធីសិក្សា និងសកម្មភាពក្រៅកម្មវិធីសិក្សាបន្ថែមជាច្រើន
- សិស្សានុសិស្សរបស់ពួកគេ ត្រូវបានទទួលឱ្យចូលរៀននៅសាកលវិទ្យាល័យល្បីៗទូទាំង ពិភពលោក
- សិស្សានុសិស្សរបស់ពួកគេមានឱកាសទៅសិក្សានៅសហរដ្ឋអាមេរិកតាមរយៈកម្មវិធីផ្លាស់ប្តូរការសិក្សា ICES
- ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានថ្នាក់ដឹកនាំមានបទពិសោធន៍ និងការតាំងចិត្តខ្ពស់ ដែលអាចជំរុញដល់ការលូតលាស់នៃអាជីវកម្ម

### ២.៤.២. ផែនការអនាគត និងយុទ្ធសាស្ត្រអាជីវកម្ម

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានបំណងកំណត់យុទ្ធសាស្ត្រ ផែនការអនាគត ដើម្បីសម្រេចបាននូវកំណើន និងរក្សាបាននូវភាពប្រកួតប្រជែងដូចខាងក្រោម៖

- ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នឹងបន្តវិនិយោគទៅលើគុណភាពសេវាកម្ម និងបង្កើនចំណែកទីផ្សារ

- ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នឹងបន្តវិនិយោគទៅលើមូលដ្ឋាននៃសិស្សានុសិស្ស ហើយនឹងបន្តនាំមកនូវកម្មវិធីសិក្សាថ្មីៗ និងសកម្មភាពក្រៅកម្មវិធីសិក្សាបន្ថែមផងដែរ
- ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នឹងបន្តភាពលូតលាស់រីកចម្រើនតាមរយៈការដាក់ដំណើរការនូវសាខាថ្មីៗ បន្ថែមទៀត ទាំង សម្រាប់ Aii និងសម្រាប់ AIS
- ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នឹងនាំមកនូវកម្មវិធីសិក្សាអន្តរជាតិ
- ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នឹងឈានជើងចូលទៅកាន់វិស័យទារកដ្ឋាន ផ្នែកអប់រំឧត្តមសិក្សា សាលាអន្តរជាតិ និងវិស័យថែទាំសុខភាព។

### ២.៤.៣. ការប្រកួតប្រជែងក្នុងទីផ្សារ

ក្រុមហ៊ុនមានចំណុចគាំទ្រសំខាន់ៗ និងគុណសម្បត្តិប្រកួតប្រជែង ដើម្បីទ្រទ្រង់អាជីវកម្ម ក៏ដូចជាគាំទ្រដល់ការរីកចម្រើនរបស់ក្រុមហ៊ុន និងចំណែកទីផ្សារដូចខាងក្រោម៖

- ស្ថាប័នត្រូវបានទទួលស្គាល់ជាស្ថាប័នអប់រំដែលមានគុណភាពខ្ពស់
- ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឡូខេសិន ម.ក អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី គឺជាបុគ្គលសាធារណៈដ៏ល្បីល្បាញក្នុងសហគមន៍អាជីវកម្ម
- ស្ថាប័នគឺជាមហាគ្រួសារមួយដែលមានលោកគ្រូ អ្នកគ្រូ និងបុគ្គលិក ដែលមានទឹកចិត្តក្នុងការបំពេញការងារខ្ពស់ និងពោរពេញដោយសមត្ថភាព
- ស្ថាប័នបានវិនិយោគយ៉ាងច្រើនទៅលើការបង្កើតសាខាថ្មីៗ និងបរិក្ខារទំនើបៗ ដែលបង្កើតឱ្យមានបរិស្ថានសិក្សាយ៉ាងល្អឥតខ្ចោះសម្រាប់សិស្សានុសិស្ស
- ទំហំ និងសេដ្ឋកិច្ចវិមាត្ររបស់ក្រុមហ៊ុនបានអនុញ្ញាតឱ្យក្រុមហ៊ុនអាចបន្តវិនិយោគទៅលើសេវាកម្ម និងនៅតែអាចរក្សាបាននូវភាពខ្លាំងនៃការប្រកួតប្រជែង
- ទីផ្សារគោលដៅរបស់យើងគឺ មាតាបិតា ឬ អាណាព្យាបាលដែលមានជីវភាពមធ្យម និងលើមធ្យម
- ក្រុមហ៊ុនមានកម្មវិធីសិក្សា និងសកម្មភាពក្រៅកម្មវិធីសិក្សាបន្ថែមជាច្រើន
- សិស្សានុសិស្ស ត្រូវបានទទួលឱ្យចូលរៀននៅសាកលវិទ្យាល័យល្បីៗ ទូទាំងពិភពលោក
- ក្រុមហ៊ុនផ្តល់សេវាប្រឹក្សាយោបល់សិស្សានុសិស្សទៅសិក្សានៅបរទេសតាមរយៈកម្មវិធី SOGO
- ក្រុមហ៊ុនមានថ្នាក់ដឹកនាំមានបទពិសោធន៍ និងការតាំងចិត្តខ្ពស់ដែលអាចជំរុញដល់ការអភិវឌ្ឍនៃអាជីវកម្ម។[22]

[22] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី១៖ សេចក្តីសង្ខេបនៃឯកសាផ្តល់ព័ត៌មាន ទំព័រទី០៣ ដល់០៤

## ២.៥. ប៉ាតង់ សញ្ញាសម្គាល់ ឈ្មោះពាណិជ្ជកម្ម អាជ្ញាប័ណ្ណ និង/ឬកិច្ចព្រមព្រៀងផ្សេងទៀតស្តីពីសិទ្ធិកម្មសិទ្ធិបញ្ញា

- គិតត្រឹមកាលបរិច្ឆេទចុងក្រោយនៃឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនមានអាជ្ញាប័ណ្ណនិងពាណិជ្ជសញ្ញាដូចខាងក្រោមដែលបានចុះបញ្ជីក្រោមឈ្មោះអ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី៖

**តារាងទី ២.៣៖** តារាងអាជ្ញាប័ណ្ណនិងពាណិជ្ជសញ្ញារបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

| ល.រ | ម៉ាក | និមិត្តសញ្ញា | លេខចុះឈ្មោះ និង កាលបរិច្ឆេទ | ថ្ងៃផុតកំណត់ |
|---|---|---|---|---|
| ១ | Mengly J. Quach Student Health Centre | | KH/84342/21 (១២ សីហា ២០២១) | ១៦ កុម្ភៈ ២០៣១ |
| ២ | Smart Mart | | KH/32957/09/D (២៩ ធ្នូ ២០០៩) | ២៧ សីហា ២០១៩ |
| ៣ | American Intercon School | | KH/38440/11/D (២០ កញ្ញា ២០១១) | ០៧ កក្កដា ២០៣១ |
| ៤ | Alex Quach Auto Shop | | KH/38376/11/D (០៧ កញ្ញា ២០១១) | ២២ កុម្ភៈ ២០៣១ |
| ៥ | Intercon Transportation Services | | KH/40109/12/D (២៤ កុម្ភៈ ២០១២) | ០៦ ធ្នូ ២០៣១ |
| ៦ | Mengly J. Quach Education | | KH/43686/13 (០៣ មេសា ២០១៣) | ១៣ វិច្ឆិកា ២០៣២ |
| ៧ | Paul Quach Car Wash | | KH/38377/11/D (០៧ កញ្ញា ២០១១) | ២២ កុម្ភៈ ២០៣១ |
| ៨ | Mengly J. Quach Library | | KH/39589/11/D (១៦ ធ្នូ ២០១១) | ១២ កញ្ញា ២០៣១ |
| ៩ | Aii Language Center | | KH/84341/21 (១២ សីហា ២០២១) | ១៦ កុម្ភៈ ២០៣១ |

| | | | | |
|---|---|---|---|---|
| ១០ | Rooster Caf” | | KH/87648/22 (១៨ ឧសភា ២០២២) | ២២ កក្កដា ២០៣១ |
| ១១ | West Coast International School | | KH/52429/14 (០៣ ធ្នូ ២០១៤) | ១៣ មិថុនា ២០២៤ |
| ១២ | Mengly J. Quach University | | KH/52430/14 (០៣ ធ្នូ ២០១៤) | ១៣ មិថុនា ២០២៤ |
| ១៣ | i-Learning | | n/a | n/a |
| ១៤ | SOGO | | n/a | n/a |

ប្រភព៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី៤៖ ព័ត៌មានក្រុមហ៊ុន ទំព័រទី១៣០ ដល់១៣២

- ការប្រើប្រាស់ឈ្មោះ "ម៉េងលី ជេ. គួច"

តាមរយៈលិខិតអនុញ្ញាតចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៣ អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី អនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការប្រើប្រាស់នាម និងគោត្តនាមរបស់លោកគឺ ម៉េងលី ជេ. គួច (MENGLY J. QUACH) ជា និង/ឬនៅក្នុងនាមករណ៍ និង/ឬ ពាណិជ្ជនាម និង/ ឬ ម៉ាក (រួមទាំងពាក្យ ពាណិជ្ជសញ្ញា និងស្លាកសញ្ញាដែលពាក់ព័ន្ធ) របស់ក្រុមហ៊ុន។

- កិច្ចព្រមព្រៀងស្តីពី សិទ្ធិប្រកបអាជីវកម្ម "I.A.M.A Cambodia"

កាលបរិច្ឆេទ ៖ ថ្ងៃទី06 ខែមិថុនា ឆ្នាំ2019

គូភាគី ៖ លោក ឯក សុថារ័ត្ន ជាម្ចាស់អាជីវកម្ម និងក្រុមហ៊ុន ជាអ្នកទទួលសិទ្ធិអាជីវកម្ម

កម្មវត្ថុនៃកិច្ចព្រមព្រៀង ៖ ការផ្តល់ នឹងការទទួលសិទ្ធិប្រកបអាជីវកម្មដែលមានឈ្មោះថា "International Abacus Mental Arithmetic (I.A.M.A Cambodia)" ដែលជាកម្មវិធីសិក្សាគណនាលេខរហ័ស ដោយប្រើប្រាស់គ្រាប់ Bead នៅលើឧបករណ៍អាបេគើស (Mental Artihmetic Dr.Miang) នៅគ្រប់

| | |
|---|---|
| | សាលា អេ អាយ អេស របស់ក្រុមហ៊ុន និងការផ្តល់សិទ្ធិក្នុងការប្រើប្រាស់កម្មវិធីសិក្សា សម្ភារៈសិក្សា ពាណិជ្ជសញ្ញា និងពាណិជ្ជនាមសម្រាប់ប្រកបអាជីវកម្ម។ |
| ពាណិជ្ជនាម / ម៉ាកសញ្ញាពាណិជ្ជកម្ម | ៖ I.A.M.A Cambodia |
| រយៈពេល | ៖ ៥ ឆ្នាំគិតចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤[23] |

## ២.៦. ផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន

ស្ថាប័ននេះជួយជំរុញសិស្សានុសិស្សឱ្យសម្រេចនូវគោលដៅអប់រំ និងអាជីពការងាររបស់ពួកគេ។ ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក គឺជាស្ថាប័នដែលផ្តល់សេវាអប់រំជាសកល និងជាក្រុមហ៊ុនមេរបស់ AIS ដែលផ្តល់សេវាអប់រំចំណេះដឹងទូទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ និង Aii ដែលផ្តល់ជូនវគ្គបណ្តុះបណ្តាលភាសាអង់គ្លេស ភាសាចិន និងភាសាថៃ។

### ២.៦.១. សាលារៀន អន្តរទ្វីប អាមេរិកាំង "AIS"

AIS ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ ជាសាលាឯកជនមួយដែលផ្តល់នូវការអប់រំថ្នាក់ចំណេះទូទៅខ្មែរស្របតាមកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ ជាមួយនឹងវិធីសាស្ត្រ និងទស្សនវិជ្ជាបង្រៀនតាមបែបខ្មែរ អាមេរិកាំងដំបូងគេបង្អស់នៅព្រះរាជាណាចក្រកម្ពុជា។ គុណភាពអប់រំរបស់ក្រុមហ៊ុនទទួលបានការកោតសរសើរ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយពីសំណាក់មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នជាច្រើនជុំវិញពិភពលោក។ បេសកម្មអប់រំរបស់ក្រុមហ៊ុន គឺដើម្បីជួយកុមារ និងប្រជាជនកម្ពុជាទាំងអស់ឱ្យមានការរីកចម្រើនទៅមុខប្រកបដោយសុខដុមរមនា។

បច្ចុប្បន្ន AIS មានសាខាចំនួនប្រាំបីដូចជា ៖ សាខាម៉ៅសេទុង (MTT),សាខាទួលគោក (TK), សាខាចាក់អង្រែ (CA), សាខាចោមចៅ(CC), សាខាផ្សារថ្មី (PT) ,សាខាជ្រោយចង្វារ (CCV) ,សាខាសៀមរាប(SR) និង សាខាតាកែវ ដែលមានសិស្សចុះឈ្មោះជាច្រើននាក់ក្នុងមួយឆ្នាំៗ។ លើសពីនេះ ដើម្បីផ្តល់ភាពងាយស្រួលដល់មាតាបិតា អាណាព្យាបាល និងសិស្សានុសិស្ស ក្រុមហ៊ុននឹងពង្រីកសាខាទៅកាន់ទីតាំងដ៏មានសក្តានុពល

---

[23] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី៥៖ ព័ត៌មានក្រុមហ៊ុន ទំព័រទី១៣០ ដល់ ១៣២

ជាច្រើនទៀតនៅក្នុងរាជធានី និងតាមបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជាដែលនឹងមានដូចជា សាខាសែនសុខ សាខាចំការដូង សាខាច្បារអំពៅ សាខាទួលសង្កែ សាខាបាត់ដំបង សាខាកំពង់ចាម សាខាព្រះសីហនុ សាខាបន្ទាយមានជ័យ សាខារតនគិរី សាខាស្ទឹងត្រែងជាដើម។

សាខានីមួយៗរបស់សាលា AIS មានទីតាំង និងលក្ខណៈពិសេសផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយក៏ AIS ប្តេជ្ញាផ្តល់នូវប្រព័ន្ធអប់រំដែលមានស្តង់ដាតែមួយ និងបទពិសោធន៍សិក្សាដ៏រីករាយដល់សិក្សានុសិស្សទាំងអស់របស់ AIS ។ គ្រប់អគារសិក្សាទាំងអស់ ត្រូវបានបំពាក់ដោយគ្រឿងបរិក្ខារសិក្សា និងឧបករណ៍បច្ចេកវិទ្យាទំនើបៗ។

**២.៦.២. មជ្ឈមណ្ឌលភាសា អេ អាយ អាយ** "Aii"

Aii គឺជាមជ្ឈមណ្ឌលឯកទេសខាងភាសាដែលមានមូលដ្ឋានលើស្តង់ដារអាមេរិកខាងជើង។ មជ្ឈមណ្ឌលនេះ ផ្តល់ជូននូវកម្មវិធីបណ្តុះបណ្តាលភាសាអង់គ្លេស ចិន និងថៃ និងវគ្គត្រៀម TOEFL ដើម្បីបំពេញតម្រូវការផ្សេងៗរបស់អ្នកសិក្សាគ្រប់វ័យ។

ចាប់តាំងពីការចាប់ផ្តើមដំបូងរបស់ខ្លួនក្នុងឆ្នាំ២០២៥ ដែលមានបុគ្គលិក ៥ នាក់និងសិស្ស ៤ នាក់ បច្ចុប្បន្ន Aii គឺជាសាលាភាសាអង់គ្លេសដ៏ធំបំផុតមួយនៅក្នុងប្រទេសកម្ពុជាដោយមានសិស្សជិត ១០.០០០ នាក់ និងបុគ្គលិកជាង ១.៥០០នាក់ ហើយនិងអតីតសិស្សជាង ៥០០.០០០ នាក់។ បច្ចុប្បន្នសាលានេះមានសាខាចំនួន ៨ នៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត។ Aii គ្រោងនឹងមានសាខាយ៉ាងហោចណាស់មួយនៅក្នុងខេត្តទាំងអស់ទូទាំងប្រទេសកម្ពុជា។

Aii បន្តផ្តល់ជូននូវគុណភាពអប់រំដែលល្អបំផុតដែលរួមបញ្ចូលគ្នារវាងស្តង់ដារជាតិ និងអន្តរជាតិដោយផ្អែកលើកម្មវិធីសិក្សានៅក្នុងសតវត្សរ៍ទី២១។ សាលាក៏ផ្តល់នូវកម្មវិធីភាសាអង់គ្លេស និងភាសាចិនយ៉ាងទូលំទូលាយដើម្បីបំពេញតម្រូវការខុសៗគ្នារបស់សិស្សគ្រប់វ័យ និងគ្រប់កម្រិតចាប់ពីថ្នាក់មត្តេយ្យសិក្សា ដល់ថ្នាក់មនុស្សពេញវ័យ និងចាប់ពីថ្នាក់កម្រិតដំបូងរហូតដល់ទៅថ្នាក់ត្រៀមប្រឡងTOEFL ។ គ្រូបង្រៀនជាជនជាតិដើមរបស់សាលាមកពីបណ្តាប្រទេសផ្សេងៗគ្នាដូចជា អង់គ្លេស កាណាដា អាមេរិក និងអូស្រ្តាលី។ ម៉្យាងវិញទៀត សាលាមានគ្រូមួយចំនួនដែលនិយាយភាសាអង់គ្លេសជាភាសាទី២ ដែលពួកគាត់មកពីប្រទេសហ្វីលីពីន នីហ្សេរីយ៉ា និងឥណ្ឌា។ លើសពីនេះទៅទៀតសាលាមានគ្រូជនជាតិខ្មែរដែលមានចំណេះដឹងភាសាអង់គ្លេសជ្រៅជ្រះ។ លោកគ្រូ អ្នកគ្រូដែលប្រកបដោយសមត្ថភាពខ្ពស់ និងមានបទពិសោធន៍ក្នុងការបង្រៀនជាច្រើនឆ្នាំទាំងនេះដែលជាឆ្អឹងខ្នងនិងបេះដូងនៃសាលា។

ថ្នាក់រៀន និងបរិវេណសាលាត្រូវបានរចនាឡើងប្រកបដោយផាសុកភាព និងសុវត្ថិភាពសម្រាប់សិស្សានុសិស្សគ្រប់ៗរូប។ គោលបំណងរបស់សាលា គឺផ្តល់នូវបរិយាកាសរីករាយ និងបើកចំហជាមួយនឹងទី

កន្លែងធំទូលាយដែលអាចឱ្យសិស្សសិក្សារៀនសូត្រ និងផ្លាស់ប្តូរយោបល់តាមវិធីជាច្រើន។ ថ្នាក់រៀនមានពន្លឺគ្រប់គ្រាន់ បំពាក់ដោយគ្រឿងសង្ហារឹម និងបរិក្ខារស្តង់ដាទំនើប ហើយត្រូវបានសម្អាត និងថែរក្សាយ៉ាងល្អពីសំណាក់ក្រុមការងារអ្នកថែទាំអគារសិក្សារបស់សាលា។

ការសិក្សារបស់សិស្សានុសិស្សត្រូវបានផ្សារភ្ជាប់ជាមួយនឹងវិធីសាស្ត្របង្រៀនល្អៗនិងភាពច្នៃប្រឌិតខ្ពស់ជាមួយនឹងសៀវភៅសិក្សាថ្មីៗ ហើយក៏បានផ្សារភ្ជាប់ជាមួយនឹងសកម្មភាពសិក្សាក្នុងថ្នាក់និងក្រៅថ្នាក់ និងកម្មវិធីបន្ថែមជាច្រើនទៀតដូចជា៖

- កម្មវិធីប្រកួតប្រជែងប្រកបពាក្យ
- កម្មវិធីប្រកួតប្រជែងបញ្ចេញសំឡេង
- កម្មវីធីប្រកួតប្រជែង ប្រណាំងពាក្យ
- កម្មវិធីប្រកួតប្រជែងវោហាសព្ទសាធារណៈ និងតស៊ូមតិ
- កម្មវិធីប្រកួតប្រជែងតែងសេចក្តី
- ការប្រកួតប្រជែងកីឡាផ្សេងៗ
- ដំណើរទស្សនកិច្ចសិក្សាជាច្រើនទៀត។

### ២.៦.៣. សេវាកម្មផ្សេងៗទៀតរបស់សាលា

❖ **សេវាកម្មដឹកជញ្ជូន អន្តរទ្វីប**

សេវាកម្មដឹកជញ្ជូន អន្តរទ្វីប (Intercon Transportation Services ឬ ITS) បង្កើតឡើងស្របពេលដែល AIS ត្រូវបានបង្កើត ពោលគឺបង្កើតឡើងតាំងពីដើមឆ្នាំ២០០៥ មកម្លេះ។ ITS បង្កើតដំបូងដោយមានរថយន្តចំនួន៣ គ្រឿងប៉ុណ្ណោះ។ ក្នុងចន្លោះឆ្នាំ ២០០៥~២០០៧ ចំពោះសិស្សនៅតំបន់ជិតៗដែលចុះឈ្មោះរៀនចាប់ពី ២ នាក់ឡើងទៅ គឺទទួលបានសេវាដឹកជញ្ជូនពីសាលាដោយឥតបង់ថ្លៃ។ លុះដល់ឆ្នាំ២០០៨ កំណើនសិស្សដែលទទួលសេវាដឹកជញ្ជូនរបស់សាលាមានចំនួនកើនឡើងច្រើនរហូតដល់កើនរថយន្តដឹកជញ្ជូនដល់ទៅ ៣០ គ្រឿងបន្ថែមទៀត។

ITS ប្តេជ្ញាចិត្តផ្តល់នូវសេវាកម្មដឹកជញ្ជូនលក្ខណៈស្តង់ដាមួយទៅដល់សិស្សានុសិស្សរបស់សាលា។ សាលាក៏ជឿជាក់ថា សេវាកម្មរបស់សាលានឹងធានាបាននូវការដឹកជញ្ជូនមួយប្រកបដោយគុណភាព និងសុវត្ថិភាពយ៉ាងពិតប្រាកដ។

បច្ចុប្បន្ននេះ ITS មានរថយន្តចំនួន ៦២ គ្រឿងដែល ៥២ គ្រឿង គឺជារថយន្តរបស់សាលាដើម្បីធានាសុវត្ថិភាពក្នុងការធ្វើដំណើរជូនសិស្សានុសិស្សរបស់សាលាផ្ទាល់ និងដើម្បីផ្តល់ភាពងាយស្រួលជូនលោកអ្នកអាណាព្យាបាលដែលមានការងាររមមាញឹកច្រើន។ សាលាក៏មានយានដ្ឋានជួសជុលរថយន្តផ្ទាល់ខ្លួនផងដែរ

ដែលមានឈ្មោះថាយានដ្ឋាន អាឡិច គួច ដែលមានទីតាំងស្ថិតនៅសាខាម៉ៅសេទុងក្នុងឃ្លាំងរបស់ក្រុមហ៊ុន។ យានដ្ឋានរបស់សាលាមានជាងដែលមានជំនាញច្បាស់លាស់ដើម្បីផ្តល់ជូននូវការថែទាំជាប្រចាំសម្រាប់យានយន្ត។ ការថែទាំទាំងនោះរួមមាន ជួសជុលរថយន្ត បាញ់ថ្នាំរថយន្ត រួមទាំងការកាត់ស្ទិកគ័រ បិទស្ទិកគ័រ ឌេគ័រ តាមការិយាល័យ ថ្នាក់រៀន និងតាមអគារ។ លើសពីនេះ សាលាក៏មានកន្លែងលាងរថយន្ត ឈ្មោះ ផល គួច សម្រាប់ធានាឱ្យបាននូវការប្រព្រឹត្តិទៅយ៉ាងរលូន នៃសេវាកម្មដឹកជញ្ជូនរបស់សាលា។

ទស្សនវិស័យរបស់សាលាគឺ ការផ្តល់ជូននូវសេវាដឹកជញ្ជូនប្រកបដោយសុវត្ថិភាពខ្ពស់ ជូនដល់សិស្សានុសិស្សរបស់ Aii និង AIS។ សុវត្ថិភាពធ្វើដំណើររបស់សិស្សានុសិស្សគឺជាការយកចិត្តទុកដាក់ដ៏សំខាន់បំផុតរបស់សាលា។ ជាមួយគ្នានេះសាលាជឿជាក់ថាសេវាកម្មរថយន្តរបស់សាលានឹងបង្កភាពងាយស្រួលដល់សិស្សានុសិស្ស និងអ្នកអាណាព្យាបាលសិស្សជាមួយការចំណេញពេលវេលា និងសន្សំសំចៃថវិការ។

បេសកកម្មរបស់សាលាគឺ ជ្រើសរើសអ្នកបើកបរដែលមានជំនាញវិជ្ជាជីវៈ និងទទួលបាននូវការបណ្តុះបណ្តាលជាប្រចាំ។ រថយន្តសាលាមាន សេវាធានារ៉ាប់រង និងសេវាកម្មត្រួតពិនិត្យថែទាំតាមស្តង់ដារបច្ចេកទេសយ៉ាងត្រឹមត្រូវ។ សាលាបានខិតខំអស់ពីសមត្ថភាពដើម្បីបែងចែកការគ្រប់គ្រងតំបន់នីមួយៗប្រកបដោយប្រសិទ្ធិភាព និងចំណេញពេលវេលា។ សាលាក៏មានផ្តល់ជូននូវយានដ្ឋានជួសជុល និងកន្លែងលាងរថយន្តផ្ទាល់ខ្លួនដូចបានរៀបរាប់ខាងលើ ដើម្បីធានាឱ្យបាននូវសុខសុវត្ថិភាព និងផាសុកភាពជូនដល់អ្នកដំណើរនិងសិស្សានុសិស្សរបស់សាលាគ្រប់ពេលវេលា។

- **បណ្ណាគារ អន្តរទ្វីប**

បណ្ណាគារ អន្តរទ្វីប បានបើកដំណើរការ និងចាប់ផ្តើមបម្រើសេវាកម្មសម្រាប់ ក្រុមហ៊ុនម៉េលី ជេ. គួច អេឌ្យូខេសិន ម.ក នៅឆ្នាំ២០០៥។ បណ្ណាគារ អន្តរទ្វីប ត្រូវបានបង្កើតឡើងដើម្បីផ្គត់ផ្គង់សម្ភារៈសិក្សាដែលមានសារប្រយោជន៍ជាច្រើនសម្រាប់សិស្សានុសិស្ស ដើម្បីឱ្យពួកគេមានភាពងាយស្រួលក្នុងការទទួលបានធនធានសិក្សាផ្សេងៗជាច្រើន ដែលចាំបាច់សម្រាប់ការសិក្សារបស់ពួកគេ។ ទាំងនោះមានដូចជាសៀវភៅសិក្សា ថ្នាក់ភាសាខ្មែរ ថ្នាក់ភាសាចិន ថៃនិងថ្នាក់ភាសាអង់គ្លេស ទស្សនាវដ្តី សម្លៀកបំពាក់សម្រាប់សិស្ស Aii និងឯកណ្ឋានសម្រាប់សិស្ស AIS សម្លៀកបំពាក់ទទួលវិញ្ញាបនប័ត្រ សម្ភារៈការិយាល័យ ដបដាក់ទឹក និងសម្ភារៈជាច្រើនទៀត។ ជាមួយនឹងបុគ្គលិកដែលទទួយបានការបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បណ្ណាគារអន្តរទ្វីប (ត្រូវបានគេទទួលស្គាល់ថាជាកន្លែងដែលសិស្ស លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាលអាចស្វែងរកនូវសម្ភារៈសិក្សារបស់ពួកគេដោយងាយស្រួល។

បណ្ណាគារ អន្តរទ្វីប ត្រូវបានបង្កើតឡើងដើម្បីផ្តល់ជូនអតិថិជននូវស្តង់ដារខ្ពស់បំផុតសម្រាប់សិស្សានុសិស្ស សាស្ត្រាចារ្យ បុគ្គលិក និងសាធារណជនទូទៅដោយផ្តល់ជូននូវគុណភាព ទំនិញទាន់សម័យ

និងតម្លៃសមរម្យ។ ផលិតផលដែលសាលាជ្រើសរើសមានគោលបំណងលើកស្ទួយបទពិសោធន៍នៃការរស់នៅប្រចាំថ្ងៃរបស់សិស្ស និងផ្គត់ផ្គង់សម្ភារៈសិក្សា សម្ភារៈប្រើប្រាស់ដែលចាំបាច់ដើម្បីឱ្យសិស្សានុសិស្សទទួលបានភាពជោគជ័យក្នុងថ្នាក់រៀន។ សាលាខិតខំបង្កើតបរិយាកាសផ្តោតលើឧត្តមភាពសេវាកម្ម ហើយក្នុងការធ្វើដូច្នេះសាលាធានាថារាល់បទពិសោធន៍របស់អតិថិជនឆ្លុះបញ្ចាំងពីការលះបង់របស់សាលាចំពោះសិស្សរបស់សាលា។

- **អាហារដ្ឋាន អាឡិច**

សាលាជឿជាក់ថារបបអាហារមានគុណភាព គឺជាគន្លឹះនៃទម្លាប់ក្នុងការញ៉ាំដែលនាំមកនូវសុខភាពល្អ ព្រោះអាហារផ្តល់ឱ្យកុមារនូវសារធាតុចិញ្ចឹមដែលពួកគេត្រូវការដើម្បីលូតលាស់។ អាហារដ្ឋាន អាឡិច ដែលជាផ្នែកមួយនៃសេវាកម្មម្ហូបអាហារ និងភេសជ្ជៈរបស់សាលាបានបង្កើតឡើងនៅចុងខែមករា ឆ្នាំ២០០៥។ អាហារ និងភេសជ្ជៈដែលផ្តល់នៅអាហារដ្ឋាន អាឡិច មានអត្ថប្រយោជន៍លើការអភិវឌ្ឍទម្លាប់នៃការញ៉ាំរយៈពេលវែងរបស់សិស្សានុសិស្ស ចំណង់ចំណូលចិត្ត និងអាកប្បកិរិយាចំពោះអាហារ។

អាហារដ្ឋានរបស់សាលា ដើរតួយ៉ាងសំខាន់ក្នុងការលើកម្ពស់អាហារដែលមានគុណភាព និងបង្កើតវប្បធម៌នៃការបរិភោគអាហារដែលមានសុខភាពល្អ។ ចំណង់ចំណូលចិត្តផ្នែកម្ហូបអាហារ និងភេសជ្ជៈកើតមាននៅក្នុងវ័យកុមារភាព ហើយសាលាជឿជាក់យ៉ាងមុតមាំថាការញ៉ាំអាហារដែលមានសុខភាពល្អ គឺជាផ្នែកសំខាន់មួយនៃការធ្វើឱ្យមានគុណភាព។ គោលបំណងរបស់សាលា គឺផ្តល់ជូនសហគមន៍របស់សាលានូវជម្រើសសម្រាប់អាហារ និងភេសជ្ជៈដែលមានជីវជាតិ និងឆ្ងាញ់ ហើយមានកាកសំណល់ និងផលប៉ះពាល់តិចតួចបំផុត។ អាហារ និងភេសជ្ជៈដែលមានជាតិស្ករ ជាតិប្រៃ និងខ្លាញ់គឺត្រូវបានកម្រិតនៅឯអាហារដ្ឋានអាឡិច។ បន្ថែមពីនេះ ភេសជ្ជៈប៉ូវកម្លាំងគ្រប់ប្រភេទមិនត្រូវបានអនុញ្ញាតឱ្យលក់ឡើយ។ ប្រូតេអ៊ីន ជាច្រើនមុខដូចជាសាច់ ត្រី ស៊ុត ឬសណ្តែក គឺមាននៅអាហារដ្ឋានរាល់ថ្ងៃ។

- **ស្មាតម៉ាត**

ស្មាតម៉ាត គឺជាកន្លែងដែលមានលក់សម្ភារៈជាច្រើនប្រភេទដែលផ្តល់ងាយស្រួល។ ស្មាតម៉ាតជាផ្នែកមួយនៃសេវាកម្មរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឡុខេសិន ដែលបម្រើសេចក្តីត្រូវការរបស់សិស្ស។ បច្ចុប្បន្នក្រុមហ៊ុនមានហាងជាច្រើនកន្លែងដែលកំពុងដំណើរការក្នុងបរិវេណសាលា។ ស្មាតម៉ាត គឺជាកន្លែងដែលសិស្សអាចទិញនូវសម្ភារៈសិក្សាសម្រាប់ការសិក្សារបស់ពួកគេក្នុងតម្លៃសមរម្យ។

ស្មាតម៉ាត មានលក់របស់របរមួយចំនួនដូចជាសម្ភារៈការិយាល័យ ប្រដាប់ប្រដាក្មេងលេង អាហារសម្រន់ ភេសជ្ជៈ និងផលិតផលនំដូចជា ខុកឃី និងនំស្រួយ។ ល។ ស្មាតម៉ាតក៏មានលក់របស់របរប្លែកៗថ្មីៗប្រកបដោយភាពរីករាយ និងទាន់សម័យដែលត្រូវបានជ្រើសរើសដោយគណៈកម្មាធិការសាលាផ្ទាល់។ ម៉ាតក៏

មានក្រុមការងារដើម្បីត្រួតពិនិត្យគុណភាពផលិតផល និងធ្វើការស្ទាបស្ទង់តម្លៃយ៉ាងទៀងទាត់ដើម្បីប្រាកដថាសិស្សទទួលបានផលិតផលដែលមានគុណភាពល្អបំផុតជាមួយនឹងតម្លៃទាប។ ស្មាតម៉ាតធានាថាអាហារ និងភេសជ្ជៈគ្រប់ប្រភេទដែលលក់នៅស្មាតម៉ាត គឺផ្តល់នូវសុខភាពល្អ និងស្អាត ដើម្បីបំពេញតាមស្តង់ដារជាមូលដ្ឋាននៃអនាម័យ។ ក្រុមហ៊ុនតែងតែយកចិត្តទុកដាក់ ចំពោះសុខុមាលភាពរបស់សិស្ស។

- ❖ **មូលនិធិ ម៉េងលី ជេ. គួច**

មូលនិធិ ម៉េងលី ជេ. គួច មានតួនាទីបម្រើការងារសហគមន៍របស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឡូខេសិន ម.ក។ មូលនិធិ ម៉េងលី ជេ. គួចប្តេជ្ញាក្នុងការចូលរួមធ្វើឱ្យជីវិត និងសុខុមាលភាពរបស់ប្រជាជនដែលងាយរងគ្រោះកាន់តែប្រសើរតាមរយៈការផ្តល់សម្ភារៈចាំបាច់ជាមូលដ្ឋាន។ មូលនិធិបាននឹងកំពុងពង្រីកសក្តានុពលរបស់ខ្លួននិងផ្តោតអារម្មណ៍ការងាររបស់ខ្លួនដោយការលើកទឹកចិត្តក្នុងការបំផុសគំនិតយុវជនរបស់យើងនូវទេពកោសល្យ ការច្នៃប្រឌិតថ្មីៗ ការពឹងផ្អែកលើខ្លួនឯង និងការអនុវត្តជាក់ស្តែងតាមវិធីជាច្រើនដែលអាចធ្វើទៅបាន។ មូលនិធិ ម៉េងលី ជេ. គួច គឺជាផ្នែកមួយនៃអង្គការរបស់សាលាដែលផ្តល់ឱកាសដល់សិស្សដើម្បីចូលរួមក្នុងការចូលរួមសេវាកម្មសហគមន៍។

ដោយមានការគាំទ្រប្រចាំឆ្នាំពី ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មូលនិធិអាចអនុវត្តកម្មវិធីដែលមានដូចជា៖ ធនាគារអាហារ គ្លីនិកព្យាបាលចល័តរបស់វេជ្ជបណ្ឌិត ម៉េងលី ជេ. គួច បណ្ណាល័យចល័ត សាលារៀនចល័ត ការសាងសង់សាលាសាធារណៈ កម្មវិធី សង្គ្រោះគ្រោះធម្មជាតិ អាហារូបករណ៍របស់អ្នកឧកញ៉ា ម៉េងលី ជេ. គួច គម្រោងសេវាកម្មសហគមន៍ និងគម្រោងសេវាកម្មលើកកម្ពស់សុខភាព និងក្រុមហ៊ុន ម៉េងលី ជេ. គួច សម្រាប់ការអប់រំ ដើម្បីការអភិវឌ្ឍសហគមន៍ សុខភាព និងការអប់រំ បុគ្គលិក និងសិស្សរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឡូខេសិន ម.ក ជួយផ្តួចផ្តើមសកម្មភាព និងព្រឹត្តិការណ៍នានា ដើម្បីបង្កើន និងគាំទ្រដល់មូលនិធិ ដើម្បីជួយរៃអង្គាសថវិកា និង អំណោយសប្បុរសធម៌ផ្សេងទៀត សម្រាប់ការអនុវត្តគម្រោងធំៗទាំង ១១ ។ សកម្មភាពទំនួលខុសត្រូវសង្គមសាជីវកម្ម (CSR) របស់មូលនិធិធ្វើឡើងស្របតាមអង្គការក្រៅរដ្ឋាភិបាលដែលគ្រប់គ្រងដោយក្រសួងមហាផ្ទៃ។

- ❖ **មជ្ឈមណ្ឌលសុខភាពសិស្ស ម៉េងលី ជេ. គួច**

ក្រុមហ៊ុនមានមណ្ឌលសុខភាពចំនួន ៩ នៅទូទាំងបរិវេណសាលារបស់ខ្លួន។ មណ្ឌលសុខភាពសិស្ស ម៉េងលី ជេ. គួច បង្កើតឡើងក្នុងគោលបំណងផ្តល់សេវាថែទាំសុខភាពដែលប្រកបដោយគុណភាព និងឥតគិតថ្លៃដល់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ បុគ្គលិក និងតម្លៃសមរម្យសម្រាប់សាធារណៈជនទូទៅ។ បេសកកម្មរបស់មណ្ឌលសុខភាពសិស្ស ម៉េងលី ជេ. គួច គឺធានាឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងលើសុវត្ថិភាពអ្នកជម្ងឺ និងលទ្ធផលព្យាបាលដ៏ល្អបំផុតដែលផ្តល់ភាពកក់ក្តៅ និងទំនុកចិត្តដល់អ្នកគ្រប់គ្នាដែលស្វែងរកការប្រឹក្សា

និងការព្យាបាលនៅក្នុងមណ្ឌលសុខភាពដែលបំពាក់ដោយឧបករណ៍ទំនើបៗរបស់ក្រុមហ៊ុន។ ក្នុងនាមជាមណ្ឌលសុខភាព ក្រុមហ៊ុនជឿជាក់លើការអប់រំសហគមន៍អំពីការអនុវត្ត សុខភាពល្អ និងចែករំលែកចំណេះដឹងដល់សិស្ស និងលោកគ្រូអ្នកគ្រូអំពីសារៈសំខាន់ ដែលថា ការការពារប្រសើរជាងព្យាបាល។

❖ **បណ្ណាល័យ ម៉េងលី ជេ. គួច**

អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ជឿជាក់ថាបណ្ណាល័យ គឺជាបេះដូងនៃគ្រប់ស្ថាប័នអប់រំទាំងអស់។ បណ្ណាល័យ គឺជាកន្លែងសំខាន់សម្រាប់ស្ថាប័នអប់រំដែលអនុញ្ញាតឱ្យសិស្សស្រាវជ្រាវ ស្វែងរក និងអភិវឌ្ឍជំនាញក្នុងការត្រិះរិះពិចារណារបស់ពួកគេ។ ក្រុមហ៊ុនមានបណ្ណាល័យចំនួន ១៥ នៅតាមអគារសិក្សា នៃសាខានីមួយៗ។

សៀវភៅដែលមាននៅបណ្ណាល័យ ម៉េងលី ជេ. គួច គឺជាអាហារូបត្ថម្ភសម្រាប់សិស្សគ្រប់រូប ហើយបណ្ណាល័យរបស់ក្រុមហ៊ុនផ្តល់ជូននូវៈ

- សៀវភៅយ៉ាងសម្បូរបែបទៅតាមអាយុ និងតម្រូវការរបស់សិស្ស
- វិសាលភាពនៃចំណេះដឹងពីសៀវភៅដែលសិស្សទទួលបានក្នុងការសិក្សារបស់ពួកគេ
- សេវាកម្មគុណភាពខ្ពស់ដែលបំពេញតម្រូវការដល់សិស្សានុសិស្សយ៉ាងទូលាយ
- បណ្ណាល័យ ម៉េងលី ជេ. គួច លើកកម្ពស់ និងគាំទ្របេសកកម្មរបស់ស្ថាប័នអប់រំរបស់ពួកគេក្នុងការស្វែងរកថែរក្សា និងលើកកម្ពស់ចំណេះដឹងដោយភាពច្នៃប្រឌិតរបស់អ្នកគ្រប់គ្នាក្នុងស្ថាប័នអប់រំរបស់ក្រុមហ៊ុន។

បណ្ណាល័យ ម៉េងលី ជេ. គួច ចូលរួមក្នុងការផ្លាស់ប្តូរស្ថាប័នអប់រំក្នុងការផ្តល់សេវាកម្មលំដាប់ថ្នាក់ពិភពលោកដែលមានសារៈសំខាន់ចំពោះការស្រាវជ្រាវ និងការអប់រំនាពេល បច្ចុប្បន្ន និងនាពេលអនាគត។

❖ **អតីតសិស្ស**

ស្ថាប័នរបស់ក្រុមហ៊ុនជឿជាក់ថា នៅពេលដែលអ្នកក្លាយជាគ្រួសាររបស់ស្ថាប័ននេះ អ្នកនឹងនៅតែជាគ្រួសាររបស់ស្ថាប័ននេះជានិច្ច។ នៅពេលដែលអ្នកជាផ្នែកមួយនៃស្ថាប័នអប់រំរបស់ក្រុមហ៊ុន ក្រុមហ៊ុននឹងមិនភ្លេចអ្នកឡើយ។ សិស្សានុសិស្សម្នាក់ៗមានចំណុចសំខាន់ក្នុងភាពជោគជ័យទាំងអស់ដែលស្ថាប័នអប់រំរបស់ក្រុមហ៊ុនសម្រេចបាន ហើយក្រុមហ៊ុនក៏សូមអរគុណចំពោះ ការខិតខំប្រឹងប្រែង និងការយកចិត្តក្នុងការសិក្សារបស់អ្នកកន្លងមក។ រាល់សិស្សានុសិស្ស ដែលបានបញ្ចប់ការសិក្សា ឬវគ្គសិក្សាពីសាលានឹងក្លាយជាសមាជិកនៃសមាគមអតីតសិស្សដោយស្វ័យប្រវត្តិ។ បច្ចុប្បន្ននេះ ក្រុមហ៊ុននេះមានអតីតសិស្សចំនួន ៥០.០០០ នាក់នៅក្នុងសមាគមអតីតសិស្ស។ សមាជិកនីមួយៗមានសិទ្ធិដាក់ពាក្យសុំធ្វើជាប្រធានសមាគមអតីតសិស្សក្នុងអាណត្តិមួយឆ្នាំ។

សមាគមអតីតសិស្សនឹងចូលរួមជាមួយក្រុមហ៊ុន ម៉េងលី ជេ. គួច អេឡូខេសិន តាមរយៈវេទិកាផ្សេងៗ ដើម្បីជួយឱ្យអតីតសិស្សនីមួយៗលូតលាស់ និងរីកចម្រើនកាន់តែខ្លាំង។ អតីតសិស្សរបស់យើងនឹងមានជំនាញសង្គម និងជំនាញសំខាន់ៗជាច្រើនទៀតតាមរយៈវេទិកាដ៏សម្បូរបែបដែលរួមមាន៖

- ពិធីជប់លៀងប្រចាំឆ្នាំរបស់អតីតសិស្ស
- ព្រឹត្តិការណ៍ទាំងឡាយរបស់អតីតសិស្ស
- ព្រឹត្តិការណ៍ផ្តល់រង្វាន់
- ការងារស្ម័គ្រចិត្តនៅក្នុងសហគមន៍
- សកម្មភាពក្រៅកម្មវិធីសិក្សា
- ចូលរួមក្នុងសេវាកម្មសហគមន៍ជាមួយសិស្សបច្ចុប្បន្ន
- ជាផ្នែកមួយនៃមូលនិធិ ម៉េងលី ជេ. គួច

### ❖ ក្រុមប្រឹក្សាសិស្ស

ក្រុមប្រឹក្សាសិស្សផ្តល់ឱកាសដល់សិស្សក្នុងការអភិវឌ្ឍ និងណែនាំសិស្សក្នុងការរៀបចំកម្មវិធី ឬព្រឹត្តិការណ៍នានាដែលរួមចំណែកដល់ស្មារតីសាលា និងសុខុមាលភាពរបស់សហគមន៍។

ក្រុមប្រឹក្សាសិស្សក៏ផ្តល់ឱកាសដល់សិស្សក្នុងការចែករំលែកបទពិសោធន៍ គំនិត ចំណាប់អារម្មណ៍ និងជួយសហគមន៍ក្រីក្រដទៃទៀត ព័ត៌មានអាហារូបករណ៍ និងសេវាកម្មផ្សេងទៀតនៅក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក។

### ❖ ការិយាល័យកិច្ចការសិស្ស

ការិយាល័យកិច្ចការសិស្ស ផ្តល់សេវាកម្ម និងការគាំទ្រដល់មាតាបិតា និងសិស្ស និងលើកកម្ពស់ការលូតលាស់ និងការអភិវឌ្ឍរបស់សិស្ស។ ការិយាល័យកិច្ចការសិស្សគាំទ្រដល់បេសកកម្មសិក្សារបស់ Aii និង AIS ហើយស្វែងរកនិងចូលរួមយ៉ាងសកម្មក្នុងការផ្តល់ជូនសេវាកម្មដល់សិស្ស និងក្នុងការផ្តល់ឱកាសសិក្សាប្រកបដោយគុណភាពយ៉ាងទូលំទូលាយនៅក្នុងសាលារៀនឱ្យបានពេញលេញ និងរស់រវើក។ ការបង្កើតការិយាល័យកិច្ចការសិស្សមានគោលបំណង៖

- ផ្តល់នូវបរិយាកាសដែលមានគុណភាពខ្ពស់ និងស្វាគមន៍យ៉ាងកក់ក្តៅដើម្បីបំពេញតម្រូវការរបស់សិស្ស និងអ្នកអាណាព្យាបាល។
- គាំពារ និងថែរក្សាច្បាប់ និងបទប្បញ្ញត្តិរបស់សាលា ដើម្បីធានាសុវត្ថិភាពសិស្ស និងការគោរពគ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់បរិយាកាសសិក្សាឱ្យកាន់តែល្អ។

- ផ្តល់ជំនួយជាលក្ខណៈបុគ្គលរួមទាំងធនធាន និងការប្រឹក្សាដល់សិស្ស ដើម្បីបង្កើនទេពកោសល្យរបស់ពួកគេឱ្យក្លាយទៅជាបុគ្គលដែលមានភាពខ្លាំងដើម្បីអភិវឌ្ឍសក្តានុពលពេញលេញរបស់ខ្លួនក្នុងការសិក្សាគោលដៅនៃអាជីព និងភាពជាអ្នកដឹកនាំរបស់ពួកគេ។

❖ **អត្តពលកម្ម**

កម្មវិធីកីឡា និងអត្តពលកម្ម របស់ស្ថាប័នអប់រំ ម៉េងលី ជេ. គួច អេឡូខេសិន មានគោល បំណងបណ្តុះបំណិនជីវិតតាមរយៈកីឡា។ កម្មវិធីកីឡារបស់យើងផ្តល់ឱ្យសិស្សនូវគោលការណ៍រឹងមាំ ការប្រកួតដោយយុត្តិធម៌ ការគោរពគ្នាទៅវិញទៅមក អាកប្បកិរិយាល្អ ស្មារតីជាក្រុម និងអត្តពលិកល្អ។ សិស្សឆ្លងកាត់ការអភិវឌ្ឍផ្លូវចិត្ត និងរាងកាយជាបន្តបន្ទាប់ ដើម្បីទទួលយករបៀបរស់នៅដែលមានសុខភាពល្អ ដែលជួយអភិវឌ្ឍសហគមន៍ និងទំនួលខុសត្រូវសង្គម។[24]

## ២.៧. បណ្តាញនៃសាខាសាលារៀនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

### ២.៧.១. សាខាម៉ៅសេទុង (ការិយាល័យកណ្តាល)

#### ក. អគារ លឹម គីមណយ

អគារ លឹម គីមណយ នៃសាខាម៉ៅសេទុង (ការិយាល័យកណ្តាល) មានទីតាំងនៅទល់មុខ សាលាបឋមសិក្សាភូមិ៧ អគារលេខ១៥៤ ផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកងរាជធានីភ្នំពេញ។ អគារ លឹម គីមណយ មានកម្ពស់ ១៧ ជាន់ មានផ្ទៃអគារសរុប ៦.៩២២ ម៉ែត្រការ៉េ និងផ្ទៃដីសរុប ៤០០ ម៉ែត្រការ៉េ។ ការសាងសង់អគារនេះត្រូវបានបញ្ចប់នៅដើមឆ្នាំ ២០១៥ ជាមួយនឹងស្តង់ដារទំនើប គុណភាពខ្ពស់ សុវត្ថិភាពជាសុកភាព ជណ្តើរយន្តចំនួន ៣ ជណ្តើរជើងចំនួន ១ និងច្រកចេញអាសន្នចំនួន ១។ គ្រប់ថ្នាក់រៀនទាំងអស់ត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ និងឧបករណ៍ដើម្បីបំពេញតម្រូវការសិក្សារបស់សិស្ស។ ជាន់នីមួយៗត្រូវបានតុបតែងយ៉ាងល្អជាមួយនឹងសាឡុង និងតុសម្រាប់បម្រើគោលបំណងអំណានរបស់សិស្ស។

អគារ លឹម គីមណយ ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥។ អគារនេះគឺសម្រាប់សិស្សានុសិស្សចំណេះទូទៅខ្មែរចាប់ពីថ្នាក់ទី៧ ដល់ទី១២ ហើយ ត្រូវបានបើកដំណើរការជាផ្លូវការសម្រាប់ដំណើរការសិក្សាតាំងពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។

#### ខ. អគារ គួច លៀងហួរ

អគារ គួច លៀងហួរ នៃសាខាម៉ៅសេទុង មានទីតាំងនៅផ្ទះលេខ១១A ផ្លូវ៤០២ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ អគារ គួច លៀងហួរ មានកម្ពស់ ១៥ ជាន់ មានផ្ទៃ

[24] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី៥៖ ព័ត៌មានក្រុមហ៊ុន ទំព័រទី៨២ ដល់១០៥

អគារសរុប ៥.៣៦៣,៥៧ ម៉ែត្រការ៉េ និងផ្ទៃដី ៣៦៤ ម៉ែត្រការ៉េ។ ការសាងសង់អគារនេះត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០១០ ជាមួយនឹងស្តង់ដារទំនើប គុណភាពខ្ពស់ សុវត្ថិភាព ផាសុកភាព មានជណ្តើរយន្តចំនួន ២ មានជណ្តើរជើងចំនួន ១ និងច្រកចេញអាសន្នចំនួន ១ ។

គ្រប់ថ្នាក់រៀនទាំងអស់ត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ និង ឧបករណ៍ដើម្បីបំពេញតម្រូវការសិក្សារបស់សិស្ស។ ជាន់នីមួយៗត្រូវបានតុបតែងយ៉ាងល្អជាមួយនឹងសាឡុង និងតុសម្រាប់បម្រើគោលបំណងអំណានរបស់សិស្ស។

អគារ គួច លៀងហួរ ត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១០។ អគារនេះប្រើប្រាស់សម្រាប់ថ្នាក់កុមារ និងមនុស្សពេញវ័យ។

### គ. អគារ ងិន ហួយ និងអគារ ងិន ហួយ ខននំរ (Ngin Huy Corner Building)

អគារ ងិន ហួយ នៃសាខាម៉ៅសេទុង មានទីតាំងនៅអគារលេខ២៩ ផ្លូវ១៨៧ ភូមិ១៩ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ អគារនេះមាន ៣ ជាន់ និងមានផ្ទៃអគារសរុប ២.៩២៩,៩ម៉ែត្រការ៉េ និងផ្ទៃដីសរុប ១.៩៤៦,៨៦ម៉ែត្រការ៉េ។ ការសាងសង់បានចាប់ផ្តើមនៅ ឆ្នាំ២០០៧ ហើយត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៧។

អគារ ងិន ហួយ ខននំរ (Ngin Huy Corner Building) មានទីតាំងនៅអគារលេខ២៩ ផ្លូវ១៨៧ ភូមិ ១៩ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ សំណង់អគារនេះត្រូវបានបញ្ចប់ជាផ្លូវការនៅឆ្នាំ ២០១៧។ អគារនេះមានកម្ពស់ ៦ ជាន់ ហើយត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ អគារនេះមានឈ្មោះថា Ngin Huy Corner Building ដោយសារសាងសង់នៅជិតជ្រុងអគារ ងិន ហួយ។

ឈ្មោះ ងិន ហួយ ត្រូវបានយកតាមការគោរពរបស់ អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ចំពោះជីដូនរបស់លោក។ អគារ ងិន ហួយ ត្រូវបានគេរចនាឡើងវិញ ជួសជុល និងតុបតែងបន្ទប់រៀនថ្មី កែលម្អរបង កម្រាលឥដ្ឋ ខ្លោងទ្វារ ការិយាល័យសិក្សា និងសួនកុមារសម្រាប់សិស្សរៀនក្នុងបរិយាកាសសិក្សាដ៏សប្បាយ និងស្រស់ស្រាយ។

អគារ ងិន ហួយ ត្រូវបានប្រើប្រាស់សម្រាប់ការអប់រំចំណេះទូទៅខ្មែរចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សាដល់ថ្នាក់ទី៦ ខណៈអគារ ងិន ហួយ ខននំរ (Ngin Huy Corner Building) បានរួមបញ្ចូលទាំងការិយាល័យកិច្ចការសិស្ស និងបន្ទប់ប្រឹក្សាយោបល់។

**ឃ. អគារ វីឡា ៤**

អគារ វីឡា ៤ នៃសាខាម៉ៅសេទុងមានទីតាំងនៅអគារលេខ ៥-៧ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ អគារវីឡា ៤ មានកម្ពស់ ៤ ជាន់ មានផ្ទៃអគារសរុប ៣.០៩១,០០៦ ម៉ែត្រការ៉េ និងផ្ទៃដី ១.៥៦៧,១៦៥ ម៉ែត្រការ៉េ។ ការសាងសង់អគារនេះត្រូវបានបញ្ចប់នៅឆ្នាំ២០០៧ ជាមួយនឹងស្តង់ដារទំនើប គុណភាពខ្ពស់ សុវត្ថិភាពខ្ពស់ ផាសុកភាព និងមានជណ្តើរចំនួន ២។ គ្រប់ថ្នាក់រៀនទាំងអស់ត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ និងឧបករណ៍ទំនើបៗដើម្បីបំពេញតម្រូវការរបស់សិស្ស។ ជាន់នីមួយៗត្រូវបានតុបតែងយ៉ាងស្អាត ដោយការរៀបចំសាឡុង និងតុសម្រាប់បម្រើគោលបំណងអំណានរបស់សិស្ស។ អគារនេះត្រូវបានប្រើសម្រាប់សិស្សថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់កុមារ។

**ង. អគារ MJQE Tower**

អគារ MJQE សាខាម៉ៅសេទុង (ការិយាល័យកណ្តាល) មានទីតាំងនៅផ្ទះលេខ ២២៣ & ២២៧ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ អគារ MJQE មានកម្ពស់ ១៥ ជាន់ មានផ្ទៃអគារសរុប ៤.៩៨៣,០៧ ម៉ែត្រការ៉េ និងផ្ទៃដីសរុប ៤៣៤ ម៉ែត្រការ៉េ។ ការសាងសង់អគារនេះត្រូវបានបញ្ចប់នៅឆ្នាំ២០២១ ជាមួយនឹងស្តង់ដាទំនើប គុណភាពខ្ពស់ សុវត្ថិភាពខ្ពស់ ផាសុកភាព ជណ្តើរយន្តចំនួន ២ និង ជណ្តើរជើង ១ ។

គ្រប់ថ្នាក់រៀនទាំងអស់ត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ និងឧបករណ៍ទំនើបៗដើម្បីបំពេញតម្រូវការការសិក្សារបស់សិស្ស។ ជាន់នីមួយៗត្រូវបានតុបតែងយ៉ាងស្អាត ដោយការរៀបចំសាឡុង និងតុសម្រាប់បម្រើគោលបំណងអំណានរបស់សិស្ស។

អគារMJQE ត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០២១។ អគារនេះត្រូវបានប្រើប្រាស់សម្រាប់សិស្សពេញវ័យ និងថ្នាក់កុមារ។

**២.៧.២. សាខាទួលគោក**

**ក. អគារ Aii សាខាទួលគោក**

អគារ Aii សាខាទួលគោក មានទីតាំងនៅផ្ទះលេខ២៦ ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ អគារ Aii សាខាទួលគោក មានកម្ពស់ ៨ ជាន់មានផ្ទៃអគារសរុប ៥.៩១៣,២៧ ម៉ែត្រការ៉េ និងផ្ទៃដី ៦៨៥ ម៉ែត្រការ៉េ។ ការសាងសង់អគារនេះត្រូវបានបញ្ចប់ក្នុងឆ្នាំ២០១៤ ជាមួយនឹងស្តង់ដាទំនើប គុណភាពខ្ពស់ សុវត្ថិភាពខ្ពស់ ផាសុកភាព ជណ្តើរយន្តចំនួន២ និងជណ្តើរជើង១។ គ្រប់ថ្នាក់រៀនទាំងអស់ត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ និងឧបករណ៍ទំនើបៗដើម្បីបំពេញតម្រូវការការ

សិក្សារបស់សិស្ស។ ជាន់នីមួយៗត្រូវបានតុបតែងយ៉ាងស្អាត ដោយការរៀបចំសាឡុង និងតុសម្រាប់បម្រើគោលបំណងអំណានរបស់សិស្ស។

អគារ Aii សាខាទួលគោក ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០១៤។ អគារនេះប្រើប្រាស់សម្រាប់សិស្សថ្នាក់ក្រោមមត្តេយ្យ ថ្នាក់កុមារ និងថ្នាក់មនុស្សពេញវ័យ។

### ខ. អគារ AIS សាខាទួលគោក

អគារ AIS សាខាទួលគោក (ដែលពីមុខ គឺជាមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា) មានទីតាំងនៅអគារលេខ៤៣ ផ្លូវ៥២៨ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ អគារ AIS សាខាទួលគោក មានកម្ពស់ ៦ ជាន់ដែលមានទំហំអគារសរុប ៥.២៧៨,៦៧ ម៉ែត្រការ៉េ និងទំហំដី ២.៤១០,៤២ ម៉ែត្រការ៉េ។ អគារ AIS សាខាទួលគោកចែកចេញជាពីរអគារផ្សេងគ្នា អគារទីមួយសម្រាប់ថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់សិស្សបឋមសិក្សា និងអគារទីពីរសម្រាប់សិស្សពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។

អគារនេះត្រូវបានស្ថាបនាឡើងវិញយ៉ាងយកចិត្តទុកដាក់ ដោយគ្រប់ជាន់ទាំងអស់ត្រូវបានតុបតែងលំអរដោយគ្រឿងសង្ហារឹមទំនើបៗដូចជា កៅអីឈើ និងតុ សម្រាប់សិស្សជួបជុំសិក្សារួមគ្នា។ អគារ AIS សាខាទួលគោកត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃ ទី៣០ ខែមីនា ឆ្នាំ២០១៥ សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦។

អគារក្រោមមត្តេយ្យសិក្សា សាខាទួលគោក មានទីតាំងនៅអគារលេខ៤៤ ផ្លូវ៦០៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បានចាប់ផ្តើមជាផ្លូវការឆ្នាំសិក្សា ២០១៨-២០១៩។ អគារនេះមាន ២ ជាន់ និងមានផ្ទៃអគារសរុប ៥៥៧,៥ ម៉ែត្រការ៉េ និងផ្ទៃដី ៧៨៧,៥ម៉ែត្រការ៉េ។ អគារនេះប្រើប្រាស់សម្រាប់ការអប់រំទូទៅចាប់ពីក្រោមមត្តេយ្យ និងមត្តេយ្យសិក្សា។

### ២.៧.៣. សាខាចាក់អង្រែ

អគារ Aii និង AIS សាខាចាក់អង្រែមានទីតាំងនៅអគារលេខ៨២៤ ផ្លូវជាតិលេខ២ ភូមិព្រៃតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ អគារនេះ មានកម្ពស់ ៥ ជាន់ ដែលមានទំហំផ្ទៃអគារសរុប ៨.១៨៣,០៤ ម៉ែត្រការ៉េ និងទំហំដីសរុប ៥.៤៩១,៧៨ ម៉ែត្រការ៉េ។

បន្ទាប់ពីទទួលបានសិទ្ធិកាន់កាប់ពេញលេញ អគារនេះត្រូវបានធ្វើការជួសជុលយ៉ាងឆាប់រហ័ស ដោយកែលម្អគុណភាព រចនាសម្ព័ន្ធ និងសម្ភារៈទំនើបៗ ដើម្បីផ្តល់នូវបរិយាកាសសិក្សាដ៏អំណោយផល។ អគារនេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥។

ថ្នាក់រៀននីមួយៗនៃអគារនេះ មានបំពាក់កាមេរ៉ាសុវត្ថិភាព ម៉ាស៊ីនត្រជាក់ សួនកុមារ និងបណ្ណាល័យ សម្រាប់សិស្សានុសិស្សដើម្បីបង្កើនការសិក្សារបស់ពួកគេ។ នៅឆ្នាំ២០២១ សាលាបានសាងសង់ទីលានបាល់ទាត់ បាល់បោះ និងបាល់ទះដើម្បីឱ្យសិស្សានុសិស្សទទួលបានបទពិសោធន៍សិស្សគ្រប់ជ្រុងជ្រោយ។

### ២.៧.៤. សាខាចោមចៅ

អគារ Aii និង AIS សាខាចោមចៅមានទីតាំងនៅផ្ទះលេខ២២២ ផ្លូវវេងស្រេង ភូមិជ្រៃកោង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ អគារនេះមានកម្ពស់ ៧ ជាន់ មានផ្ទៃដីសរុប៦៥៦.៥ ម៉ែត្រការ៉េ និងផ្ទៃអគារសរុប ២.៨៧0 ម៉ែត្រការ៉េ។អគារនេះត្រូវបានបំពាក់ដោយកាមេរ៉ាសុវត្ថិភាពនៅគ្រប់ថ្នាក់រៀន និងនៅតាមបរិវេណសាលា ដើម្បីធានាសុវត្ថិភាពសិស្ស និងបុគ្គលិកទាំងអស់។ ជាន់ផ្ទាល់ដីនិងថ្នាក់រៀនត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ កង្ហារ និងអំពូលLED ដែលផ្តល់នូវផាសុកភាពសម្រាប់សិស្សានុសិស្សក្នុងការសិក្សា។

អគារសាខាចោមចៅនេះត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩។ អគារនេះត្រូវបានបើកឱ្យសិស្សសិក្សាភាសាអង់គ្លេស និងភាសាចិនចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់មនុស្សពេញវ័យ និងចំណេះដឹងទូទៅភាសាខ្មែរ ចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ ខណៈដែល Aii បានផ្តល់ជូននូវថ្នាក់ភាសាអង់គ្លេស និង ភាសាចិនក្នុងកម្មវិធីសិក្សារបស់ខ្លួន។

### ២.៧.៥. សាខាផ្សារថ្មី

អគារ Aii និង AIS សាខាផ្សារថ្មីមានទីតាំងនៅផ្ទះលេខ១C និង១៣D កែងផ្លូវ៥៣ និង១៥៤ ភូមិ៥ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ អគារនេះមានកម្ពស់ ៨ ជាន់ដែលមានផ្ទៃអគារសរុប ៤២៥.០១ ម៉ែត្រការ៉េ និងទំហំដី ១៥១.៣៩ ម៉ែត្រការ៉េជាមួយនឹងស្តង់ដាទំនើប គុណភាពខ្ពស់ សុវត្ថិភាពខ្ពស់ និងផាសុកភាព។ អគារនេះមានជណ្តើរយន្ត ១ និង ជណ្តើរជើងចំនួន ២ ផងដែរ។

នៅក្នុងអគារសិក្សា ថ្នាក់រៀននីមួយៗត្រូវបានបំពាក់ដោយទូរទស្សន៍ឆ្លាតវៃ និងម៉ាស៊ីនត្រជាក់ ដើម្បីបំពេញតម្រូវការសិក្សារបស់សិស្ស។ នៅជាន់នីមួយៗត្រូវបានដាក់តាំងលម្អដោយផ្កា និងគ្រឿងសង្ហារឹមដូចជាសាឡុង និងតុ ដើម្បីធ្វើឱ្យបរិយាកាសអគារកាន់តែមានភាពទាក់ទាញសម្រាប់សិស្សានុសិស្សអង្គុយអានសៀវភៅ។

អគារនេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩។ អគារនេះត្រូវបានបើកសម្រាប់សិស្សានុសិស្សរៀនភាសារអង់គ្លេស និងភាសាចិន ចាប់ពីថ្នាក់ក្រោមមត្តេយ្យ ដល់សិស្សពេញវ័យ និងចំណេះដឹងទូទៅភាសាខ្មែរ ចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សាដល់ថ្នាក់ទី១២។ អគារសិក្សានេះបានទទួល

សិស្សានុសិស្សចូលរៀនចាប់ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ រួមទាំងថ្នាក់ភាសាចិន និងភាសាអង់គ្លេសនៅពេលល្ងាចផងដែរ។

### ២.៧.៦. សាខាជ្រោយចង្វារ

#### ក. អគារ Aii សាខាជ្រោយចង្វារ

អគារ Aii សាខាជ្រោយចង្វារមានទីតាំងនៅផ្ទះលេខ១៥៨JLKM ផ្លូវជាតិលេខ៦A សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា។ អគារនេះមានកម្ពស់ ៨ ជាន់មានផ្ទៃអគារសរុប ២.៥៥៣,២៨ ម៉ែត្រការ៉េ និងផ្ទៃដី ១០៦,៦ម៉ែត្រការ៉េ។ ការសាងសង់អគារនេះត្រូវបានបញ្ចប់នៅឆ្នាំ២០១៩ ជាមួយនឹងស្តង់ដាទំនើប គុណភាព សុវត្ថិភាពខ្ពស់ ផាសុកភាពខ្ពស់ ជណ្តើរយន្តចំនួន ២ និងជណ្តើរជើងចំនួន ២ ។ អគារនេះ គឺជាអគារដែលជាកម្មសិទ្ធិរបស់ អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី។

គ្រប់ថ្នាក់រៀនទាំងអស់ត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ និងឧបករណ៍ដើម្បីបំពេញតម្រូវការការសិក្សារបស់សិស្ស។ ជាន់នីមួយៗត្រូវបានតុបតែងយ៉ាងស្អាត ដែលបំពាក់ដោយសាឡុង និងតុទំនើបៗសម្រាប់បម្រើគោលបំណងអំណានរបស់សិស្ស។

អគារនេះ ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩។ អគារនេះប្រើប្រាស់សម្រាប់សិស្សថ្នាក់ក្រោមមត្តេយ្យ ថ្នាក់កុមារ និងសិស្សពេញវ័យ។

#### ខ. អគារ AIS សាខាជ្រោយចង្វារ

អគារ AIS សាខាជ្រោយចង្វារ មានពណ៌ស ទំហំធំ និងកម្ពស់ខ្ពស់ ដែលមានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ៦A ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ អគារនេះមានទីតាំងតាមបណ្តោយទន្លេសាប និងទន្លេមេគង្គ។ អគារនេះមានកម្ពស់ ៨ ជាន់ មានទំហំអគារសរុប ៧.៥២១,៦២ ម៉ែត្រការ៉េ និងផ្ទៃដី ២.៦១២,៨១ ម៉ែត្រការ៉េ។ ការជួសជុលអគារនេះត្រូវបានបញ្ចប់នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០២១ ជាមួយនឹងស្តង់ដារទំនើប គុណភាពខ្ពស់ សុវត្ថិភាពខ្ពស់ និងផាសុកភាព។ លើសពីនេះ មានជណ្តើរយន្តចំនួន ២ ជណ្តើរជើងចំនួន ១ និងជណ្តើរអាសន្នចំនួន ១ នៅក្នុងអគារនេះ។

នៅក្នុងថ្នាក់នីមួយៗរបស់ អគារ AIS សាខាជ្រោយចង្វារ មានទំហំធំ និងបំពាក់ដោយម៉ាស៊ីនត្រជាក់ កង្ហារ និងសម្ភារៈទំនើបៗជាច្រើនដើម្បីបំពេញតម្រូវការការសិក្សារបស់សិស្សក្នុងបរិបទនៃបច្ចេកវិទ្យាថ្មី។ នៅជាន់នីមួយៗមានសម្ភារៈតុបតែងដូចជា ចូ និងផ្ទាំងគំនូរស្រស់ស្អាត។ ជាងនេះទៅទៀត ក៏មានគ្រឿងសង្ហារឹមរួមទាំងសាឡុង និងតុទំនើបៗ សម្រាប់សិស្សសម្រាក និងអានសៀវភៅផងដែរ។ អគារនេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ហើយវាត្រូវបានបើកសម្រាប់ចំណេះដឹងទូទៅភាសាខ្មែរចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ ចាប់តាំងពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១។

### ២.៧.៧. សាខាសៀមរាប

#### ក. អគារ Aii សាខាសៀមរាប

អគារ Aii សាខាសៀមរាបមានអាស័យដ្ឋាននៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា។ អគារនេះមានកម្ពស់ ៥ ជាន់ មានផ្ទៃអគារសរុប ៣.៥៧៧ ម៉ែត្រការ៉េ និងផ្ទៃដី ១.០៩៩,០៥ ម៉ែត្រការ៉េ។ ការសាងសង់អគារនេះត្រូវបានបញ្ចប់នៅឆ្នាំ២០២២ជាមួយនឹងស្តង់ដារទំនើប គុណភាពខ្ពស់ សុវត្ថិភាពខ្ពស់ ផាសុកភាព មានជណ្តើរយន្តចំនួន ២ និងជណ្តើរជើងចំនួន ២។

គ្រប់ថ្នាក់រៀនទាំងអស់ត្រូវបានបំពាក់ដោយម៉ាស៊ីនត្រជាក់ និងឧបករណ៍ទំនើបៗដើម្បីបំពេញតម្រូវការការសិក្សារបស់សិស្ស។ ជាន់នីមួយៗត្រូវបានតែងយ៉ាងស្អាត បំពាក់ដោយសាឡុងទំនើបៗ និងតុសម្រាប់បម្រើគោលបំណងអំណានរបស់សិស្ស។

អគារនេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២។ អគារនេះប្រើប្រាស់សម្រាប់សិស្សថ្នាក់ក្រោមមត្តេយ្យសិក្សា ថ្នាក់កុមារ និងសិស្សពេញវ័យ។

#### ខ. អគារ AIS សាខាសៀមរាប

អគារ AIS សាខាសៀមរាប មានទីតាំងនៅភូមិសាលាកន្សែង ផ្លូវជាតិលេខ៦A សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។ អគារនេះមានកម្ពស់ ៤ ជាន់ និងត្រូវបានសាងសង់នៅលើផ្ទៃដីសរុប ៩.៣៥៥ ម៉ែត្រការ៉េ។ អគារនេះបានបើកដំណើរការសម្រាប់សិស្សានុសិស្សទាំងអស់ចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សាដល់ថ្នាក់ទី១២។

អគារនេះត្រូវបានកែលម្អឱ្យមានភាពប្រណីត រឹងមាំ និងបំពាក់ដោយគ្រឿងបរិក្ខារទំនើបៗ។ ថ្នាក់រៀនត្រូវបានរចនាឡើងយ៉ាងពិសេសដើម្បីបង្កើតបរិយាកាសសិក្សាប្រកបដោយផាសុកភាពសម្រាប់សិស្សានុសិស្ស និងគ្រូបង្រៀន។ នៅច្រកចូលក្នុងអគារមានកៅអីឈើសម្រាប់សិស្សានុសិស្សអង្គុយអានសៀវភៅ ឬការធ្វើស្វ័យសិក្សា។ អគារសិក្សានេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២។ បច្ចុប្បន្ននេះ AIS សាខាសៀមរាបត្រូវបានបើកឱ្យសិស្សានុសិស្សទាំងអស់ចូលសិក្សាកម្មវិធីចំណេះដឹងទូទៅខ្មែរចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ សម្រាប់ឆ្នាំសិក្សាថ្មី ២០២២-២០២៣ ចាប់ផ្តើមពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២។

### ២.៧.៨. សាខាតាកែវ

អគារ Aii និង AIS សាខាតាកែវមានទីតាំងនៅភូមិតាគរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ អគារ Aii (អគារពណ៌ស) មានកម្ពស់ ៧ ជាន់ និងសាងសង់លើផ្ទៃដីសរុប ៥៣៧ ម៉ែត្រការ៉េ។ អគារទាំងពីរនៅជិតគ្នានៅលើផ្លូវតែមួយរចនាយ៉ាងធំទូលាយប្រកបដោយស្តង់ដារខ្ពស់គុណភាព និងសុវត្ថិភាព ហើយថ្នាក់រៀនទាំង

អស់ត្រូវបានបំពាក់ដោយសម្ភារៈទំនើបៗដែលធ្វើឱ្យបរិយាកាសសិក្សាស្រស់ស្រាយ និងផាសុកភាពសម្រាប់សិស្សានុសិស្សទាំងអស់។

AIS សាខាតាកែវ ត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២។ អគារនេះបានបើកដំណើរការទាន់ពេលវេលាសម្រាប់កម្មវិធីរៀនត្រៀមសម្រាប់ឆ្នាំសិក្សាថ្មី ២០២២-២០២៣។ អគារនេះកំពុងបើកសម្រាប់សិស្សចាប់ពីថ្នាក់ក្រោមមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ ដោយមានវេនសិក្សាពីរពេលគឺ ពេលព្រឹក និងពេលរសៀល។[25]

## ២.៨. កត្តាហានិភ័យ

មានកត្តាមួយចំនួនជាហានិភ័យជាក់លាក់ចំពោះក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក និងជាហានិភ័យទាក់ទងនឹងបរិយាកាសអាជីវកម្មទូទៅ ដែលកត្តាទាំងអស់នេះអាចជះឥទ្ធិពលដល់ដំណើរការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននេះ និងផ្តល់ផលប៉ះពាល់ដល់លទ្ធផលហិរញ្ញវត្ថុនាអនាគតផងដែរ។ មុននឹងសម្រេចចិត្តវិនិយោគ វិនិយោគិនគួរតែពិចារណាដោយប្រុងប្រយ័ត្នជាមួយនឹងកត្តាហានិភ័យផ្សេងៗ កត្តាមួយចំនួន ព្រមទាំងបញ្ហាផ្សេងៗទៀតដែលបានរៀបរាប់ដូចខាងក្រោម៖

(i) បម្រែបម្រួលនៃអត្រាការប្រាក់
(ii) បម្រែបម្រួលនៃអត្រាប្តូរប្រាក់
(iii) ហានិភ័យលើឧស្សាហកម្ម ហានិភ័យពាក់ព័ន្ធនឹងការកែប្រែបរិបទជាតិ និងអន្តរជាតិ និងការកែប្រែច្បាប់ និងបទប្បញ្ញត្តិនានា
(iv) ការពឹងផ្អែកលើអចលនទ្រព្យដែលបានជួលសម្រាប់ប្រតិបត្តិការ
(v) ការពឹងផ្អែកលើការផ្តល់សេវាអប់រំពីបុគ្គលិកសិក្សា
(vi) ការបរាជ័យក្នុងការកែលម្អកម្មវិធីសិក្សាដើម្បីឱ្យដើរទាន់តម្រូវការទីផ្សារ
(vii) ការប្រកួតប្រជែងពីស្ថាប័នសិក្សាឯកជន និងស្ថាប័នសិក្សាសាធារណៈ
(viii) ការធ្លាក់ចុះនៃចំនួនសិស្សចុះឈ្មោះចូលរៀនដែលធ្វើឱ្យជះឥទ្ធិពលដល់ចរន្តប្រាក់ចំណូលរបស់ក្រុមហ៊ុន
(ix) ភាពបរាជ័យក្នុងការគ្រប់គ្រងការពង្រីកសាខាសាលារៀន
(x) ការពឹងផ្អែកលើ និងអសមត្ថភាពក្នុងការរក្សាអភិបាលប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់

[25] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី៤៖ ព័ត៌មានក្រុមហ៊ុន ទំព័រទី១១២ ដល់១២៤

(xi) ហានិភ័យនៃប្រតិបត្តិការប្រចាំថ្ងៃ និងការធានារ៉ាប់រង

(xii) វិវាទការងារអាចបណ្តាលឱ្យមានការរំខានដល់អាជីវកម្ម ការបាត់បង់ និង ការខូចខាតកេរ្តិ៍ឈ្មោះ

(xiii) ភាពជាម្ចាស់ និងការគ្រប់គ្រងដោយម្ចាស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

(xiv) ការពឹងផ្អែកទៅលើ អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ដែលជាស្ថាបនិកប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ

(xv) ការពឹងផ្អែកលើការធានាលក្ខណៈបុគ្គល និងទ្រព្យសម្បត្តិរបស់ម្ចាស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ដើម្បីទទួលបានប្រាក់កម្ចីពីធនាគារ

(xvi) ហានិភ័យសន្ទនីយភាព

(xvii) ហានិភ័យឥណទាន

(xviii) ហានិភ័យលើបណ្តឹងសំខាន់ៗ

(xix) ហានិភ័យពាក់ព័ន្ធនឹងការវិនិយោគលើមូលបត្រ

(xx) ការបង្ហាញព័ត៌មានពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍អនាគត។[26]

## ២.៩. ការគ្រប់គ្រងហានិភ័យ

មានកត្តាមួយចំនួនជាហានិភ័យជាក់លាក់ចំពោះក្រុមហ៊ុន និងជាហានិភ័យទាក់ទងនឹងបរិយាកាសអាជីវកម្មទូទៅដែលកត្តាទាំងអស់នេះអាចជះឥទ្ធិពលដល់ដំណើរការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននិងផ្តល់ផលប៉ះពាល់ដល់លទ្ធផលហិរញ្ញវត្ថុនាអនាគតផងដែរ។

- ការវាយតម្លៃហានិភ័យជាប្រចាំ ធ្វើឱ្យក្រុមហ៊ុនអាចកំណត់ និងវាយតម្លៃទាំងកត្តាខាងក្នុង និងខាងក្រៅដែលអាចអនុវត្តយ៉ាងសកម្មនូវវិធានការសមស្របដើម្បីដោះស្រាយទាន់ពេល។
- ការបង្កើតផែនការបន្ទាន់ ធានាឱ្យក្រុមហ៊ុនអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការរំខាន ឬព្រឹត្តិការណ៍មិនល្អដែលអាចកើតឡើង កាត់បន្ថយផលប៉ះពាល់លើប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។
- ការពង្រឹងការគ្រប់គ្រងផ្ទៃក្នុង ដើម្បីធានាបាននូវការត្រួតពិនិត្យ និងតម្លាភាព ការកែលម្អ

[26] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី១៖ សេចក្តីសង្ខេបនៃឯកសារផ្តល់ព័ត៌មាន ទំព័រទី១៣

ដំណើរការសម្រាប់ការត្រួតពិនិត្យ និងការគ្រប់គ្រងហានីភ័យ

- ការវិនិយោគលើបច្ចេកវិទ្យា និងការធ្វើឱ្យក្រុមហ៊ុនបន្តដំណើរទៅមុខនៃវឌ្ឍនភាពបច្ចេកវិទ្យា និង និន្នាការទីផ្សារ ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុនការបំពេញតម្រូវការអតិថិជន និងកាត់បន្ថយហានិភ័យដែលអាចកើតមាន។

សរុបមក ក្រុមហ៊ុនប្តេជ្ញាក្នុងការគ្រប់គ្រងហានិភ័យដើម្បីគាំទ្រដល់បេសកកម្មក្នុងការការពារនិរន្តរភាពហិរញ្ញវត្ថុ និងឱកាសសម្រាប់កំណើនជានានូវការបង្កើនតម្លៃរយៈពេលវែងសម្រាប់ភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។

# ជំពូកទី៣

# ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

# ជំពូកទី៣
# ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

## ៣.១. ព័ត៌មានក្រុមហ៊ុននៃក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង

ដើម្បីអាចមានសិទ្ធិក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ត្រូវអនុវត្តតាមការណែនាំរបស់ ន.ម.ក. និង ផ.ម.ក. ដែលក្នុងនោះត្រូវមានក្រុមហ៊ុនពាក់ព័ន្ធមួយចំនួនសម្រាប់ដំណើរការបោះផ្សាយនេះ។ ក្រុមហ៊ុនទាំងនោះមានដូចជា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ និងក្រុមហ៊ុនផ្តល់សេវាសវនកម្ម។[27]

### ៣.១.១. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រមានដូចខាងក្រោម៖

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | : ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក |
| អាសយដ្ឋាន | : អគារលេខ ១១អេ ផ្លូវលេខ ៤០២ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| គេហទំព័រ | : https://www.mjqeducation.edu.kh |
| អ៊ីម៉ែល | : info@mjqeducation.edu.kh |
| លេខទូរស័ព្ទ | : +៨៥៥ ២៣ ២២៣ ២៩៥ |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : ០០០០៤៧៨៧ កាលបរិច្ឆេទចុះបញ្ជី ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ |

### ៣.១.២. ក្រុមហ៊ុនធានាទិញមូលបត្រ

ព័ត៌មានរបស់ក្រុមហ៊ុនធានាទិញមូលបត្រមានដូចខាងក្រោម៖

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | : អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក |
| អាសយដ្ឋាន | : ជាន់M, អគារ OHK, កែងផ្លូវ១១០ និងផ្លូវ៩៣ ភូមិលេខ៣ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| គេហទំព័រ | : https://www.rhbgroup.com.kh |
| អ៊ីម៉ែល | : rhbsc.info@rhbgroup.com.kh |

[27] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី២៖ ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត) ទំព័រទី១៥ ដល់ ២១

លេខទូរស័ព្ទ : +៨៥៥ ២៣ ៩៦៩ ១៦១

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : ០០០០៣២៩៥ កាលបរិច្ឆេទចុះបញ្ជី ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០

លេខអាជ្ញាប័ណ្ណទទួលស្គាល់ : ០០៩ ន. ម. ក/ ក.ធ កាលបរិច្ឆេទចុះបញ្ជី ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ដោយ ន.ម.ក.

❖ **លក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានាទិញមូលបត្រ**

ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងធានាទិញមូលបត្រជាមួយនឹងក្រុមហ៊ុនធានាទិញមូលបត្រនៅ ឆ្នាំ ២០២៣ ដើម្បីធានាទិញមូលបត្ររហូតដល់ ១៩.៦០៦.៦០០ភាគហ៊ុនក្នុងតម្លៃបោះផ្សាយលក់ ដោយឈរលើមូលដ្ឋាននៃការខិតខំប្រឹងប្រែងដ៏ល្អបំផុត។

កាតព្វកិច្ចនៃការធានាទិញមូលបត្ររបស់ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដ៏ជាក់លាក់សមស្របជាមួយនឹងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននេះជាមួយនឹង ន.ម.ក.។

លក្ខខណ្ឌខាងក្រោមត្រូវបានស្រង់ចេញពីកិច្ចព្រមព្រៀងធានាទិញមូលបត្រ ក្រុមហ៊ុនធានាទិញ មូលបត្រអាចជូនដំណឹងទៅក្រុមហ៊ុនគ្រប់ពេលមុនកាលបរិច្ឆេទនៃការចុះបញ្ជី ការបញ្ចប់ ការ លុបចោល និងដកការប្តេជ្ញាចិត្តក្នុងការធានាទិញមូលបត្រ ប្រសិនបើ៖

ក. មានការរំលោភបំពាន ដោយក្រុមហ៊ុនបោះផ្សាយនៅចំណុចណាមួយនៃការធានា កាតព្វកិច្ច ឬការទទួលខុសត្រូវដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង។

ខ. ព័ត៌មានសំខាន់ដែលត្រូវបានដកយកដោយក្រុមហ៊ុនបោះផ្សាយ ឬភាគហ៊ុនិក ពីក្រុមហ៊ុន ធានាទិញមូលបត្រ ដែលតម្រូវឱ្យបង្ហាញស្របតាមកិច្ចព្រមព្រៀងតាមទស្សនៈរបស់ក្រុម ហ៊ុនធានាទិញមូលបត្រ ដែលមានផលប៉ះពាល់ទៅនឹងព័ត៌មានសំខាន់ ឬប៉ះពាល់ដល់ភាព ជោគជ័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ឬការចែកចាយ ឬការ លក់ភាគហ៊ុនរបស់ក្រុមហ៊ុនដែលស្របទៅតាមការបោះផ្សាយលក់មូលបត្រជាសាធារណៈ លើកដំបូង។

គ. មានការលេចឡើង កើតឡើង ឬចូលជាធរមាននូវព្រឹត្តិការណ៍ ឬព្រឹត្តិការណ៍បន្តបន្ទាប់ ដែលហួសពីការគ្រប់គ្រងដែលសមហេតុផលរបស់ក្រុមហ៊ុនធានាទិញមូលបត្រ និងដោយ ប្រធានសក្តិ (ដូចដែលបានកំណត់នៅខាងក្រោម) ដែលអាចមាន ឬអាចត្រូវបានរំពឹងថា មានផលប៉ះពាល់អវិជ្ជមានដល់ព័ត៌មាន ឬទំនងជាមានផលប៉ះពាល់ដែលធ្វើឱ្យកាតព្វកិច្ច ណាមួយដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ មិនអាចអនុវត្តបានសមស្របទៅតាមលក្ខខណ្ឌ។ "ប្រធានសក្តិ" មានន័យថាបុព្វហេតុដែលមិនអាចប៉ាន់ស្មានបាន និង លើសពីការ គ្រប់គ្រងដែលភាគីបានប្រកាសថាជាប្រធានសក្តិដែលមិនអាចជៀសបាន ឬមិនអាចរារាំង បានដោយការមើលឃើញជាមុន ការរៀបចំគម្រោងផែនការ និងការអនុវត្តដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹម៖

(i) សង្គ្រាម សកម្មភាពនៃសង្គ្រាម ការបំផ្លិចបំផ្លាញ អរិភាព ការឈ្លានពាន ការលុក លុយដោយកម្លាំងប្រដាប់អាវុធ សកម្មភាពអរិភាពនៃកងទ័ព ប្រទេសជាតិ ឬសត្រូវ សង្គ្រាម ស៊ីវិល ឬភាពចលាចល ប្លន់ ភេរវកម្ម

(ii) កុប្បកម្ម ការងើបឡើងប្រឆាំងនឹងរដ្ឋអំណាច ភាពចលាចល ភាពច្របូកច្របល់ ឧទ្ទាម ការរៀបចំប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាល ការបះបោរ បដិវត្តន៍ យោធា ឬ ដណ្តើមអំណាច ឬ

(ii) គ្រោះមហន្តរាយធម្មជាតិ រួមមាន ការរញ្ជួយដី ទឹកជំនន់ អគ្គីភ័យ ព្យុះ រន្ទះ ព្យុះ សង្ឃរា ការផ្ទុះ គ្រោះថ្នាក់ ជំងឺរាតត្បាត ឬប្រធានសក្តិផ្សេងៗទៀត

ឃ. រាល់ការទាមទាររបស់រដ្ឋាភិបាល ឬការកើតឡើងផ្សេងៗនៃធម្មជាតិណាមួយដែលអាចមាន ឬទំនងជាមានការប៉ះពាល់អវិជ្ជមានដល់ព័ត៌មាន

ង. រាល់ការផ្លាស់ប្តូរអវិជ្ជមាននៃព័ត៌មានសំខាន់ក្នុងទីផ្សាររូបិយវត្ថុហិរញ្ញវត្ថុជាតិ ឬអន្តរជាតិ (រួមទាំងលក្ខខណ្ឌទីផ្សារភាគហ៊ុន និងអត្រាការប្រាក់) លក្ខខណ្ឌនយោបាយ ឬសេដ្ឋកិច្ច ការត្រួតពិនិត្យលើការដោះដូររូបិយវត្ថុ ឬ អត្រាប្តូរប្រាក់ដែលតាមទស្សនៈរបស់ក្រុមហ៊ុន ធានាទិញមូលបត្រអាចមាន ឬទំនងអាចជាមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ឬផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ (មិនថានៅក្នុងទីផ្សារដំបូង ឬទាក់ទងនឹងការជួញដូរនៅទីផ្សារបន្ទាប់) លើតម្លៃ ឬតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន។

ច. ការជួញដូររបស់ក្រុមហ៊ុនមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជាត្រូវបានពន្យារ ឬ ត្រូវ បានដាក់កំហិតក្នុងការជួញដូរជាទូទៅ

ឆ. រាល់ច្បាប់ ឬបញ្ញត្តិថ្មីណាមួយ ឬមានវិសោធនកម្មទៅលើច្បាប់ បទប្បញ្ញត្តិ គោលការណ៍ ណែនាំ គោលនយោបាយ ឬសេចក្តីសម្រេចនៅក្នុងដែនសមត្ថកិច្ចណាមួយដែលនៅក្នុង ទស្សនៈរបស់ក្រុមហ៊ុនធានាទិញមូលបត្រអាចធ្វើបុរេវិនិច្ឆ័យចំពោះការចុះបញ្ជី ឬ ដែលអាចមាន ឬ ទំនងជាមានឥទ្ធិពលធ្វើឱ្យមិនអាចអនុវត្តបានដើម្បីអនុវត្តកិច្ចសន្យាទៅជា ចំណែក និង/ឬផ្ទេរភាគហ៊ុន ឬអនុវត្តកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងដែលមិនអាចអនុវត្ត បានស្របទៅតាមលក្ខខណ្ឌ

ជ. ការដាក់ និង/ឬ សំណើបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវបានបញ្ឈប់ ឬពន្យារ ពេលដោយក្រុមហ៊ុន ភាគហ៊ុនិក ឬអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ហេតុផលណាមួយ (លើកលែងតែការពន្យារពេលបែបនេះត្រូវបានយល់ព្រមដោយក្រុមហ៊ុនធានាទិញមូលបត្រ

ឈ. ការចុះបញ្ជីមិនត្រូវធ្វើឡើងក្រោយ [ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៣] ឡើយ ប្រសិនបើមានការស្នើសុំពន្យារកាលបរិច្ឆេទបន្ថែមផ្សេងទៀតលុះត្រាណាតែមានការយល់ស្របដោយក្រុមហ៊ុនធានាទិញមូលបត្រ។

ញ. រាល់ការចាប់ផ្តើមនៃនីតិវិធីច្បាប់ ឬសកម្មភាពណាមួយប្រឆាំងនឹងសមាជិកនៃសម្ព័ន្ធក្រុមហ៊ុន ឬភាគហ៊ុនិក ឬអភិបាលណាមួយ ដែលមាននៅក្នុងទស្សនៈរបស់ក្រុមហ៊ុនធានាទិញមូលបត្រ អាចមាន ឬសមហេតុផលដែលប៉ះពាល់ធ្ងន់ធ្ងរ ឬនាំឱ្យមិនអាចអនុវត្តកិច្ចសន្យា ដើម្បីបែងចែក និង/ឬការផ្ទេរភាគហ៊ុន និង

ដ. កិច្ចព្រមព្រៀងធានាទិញមូលបត្រត្រូវបញ្ចប់ ឬលុបចោលស្របទៅតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង

### ៣.១.៣. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ

ព័ត៌មានរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យមានដូចខាងក្រោមៈ

#### ៣.១.៣.១. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | : ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត |
| អាសយដ្ឋាន | : Suite ២៨ សណ្ឋាគារ កាំបូឌីយ៉ាណា ផ្លូវព្រះស៊ីសុវត្ថិ ៣១៣ ភូមិ ១ ចតុមុខ ដូនពេញ រាជធានីភ្នំពេញ ២២០៧ ព្រះរាជាណាចក្រកម្ពុជា |
| គេហទំព័រ | : https://www.bdo.com.kh |
| អ៊ីម៉ែល | : info@bdo.com.kh |
| លេខទូរស័ព្ទ | : +៨៥៥ ២៣ ២១៨ ១២៨ |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | : Co 5751E/2009 |
| កាលបរិច្ឆេទចុះបញ្ជី | : ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ |
| អត្តលេខទទួលស្គាល់បន្តពីន.ម.ក. | : ០០៣ គ.ម.ក./កស |
| កាលបរិច្ឆេទទទួលបានការទទួលស្គាល់ពី ន. ម.ក. | : ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ |

#### ៣.១.៣.២. សវនករឯករាជ្យ

| | |
|---|---|
| ឈ្មោះសវនករឯករាជ្យ | : Lee Ken Wai |
| អាសយដ្ឋាន | : Suite 28 សណ្ឋាគារ កាំបូឌីយ៉ាណា ផ្លូវព្រះស៊ីសុវត្ថិ ៣១៣ ភូមិ ១ ចតុមុខ ដូនពេញ រាជធានីភ្នំពេញ ១២២០៧ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | : +៨៥៥ ២៣ ២១៨ ១២៨ |
| អ៊ីម៉ែល | : ken@bdo.com.kh |
| លេខសមាជិក KICPAA | : I-0037 ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ |
| អត្តលេខទទួលទទួលបានការស្គាល់ពីន.ម.ក. | : ០៤៤ គ.ម.ក. /ស.ឯ |
| កាលបរិច្ឆេទទទួលបានការទទួលស្គាល់ពី ន. ម.ក. | : ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ |

### ៣.១.៤. ក្រុមហ៊ុនសេវាកម្មផ្នែកច្បាប់

ព័ត៌មានរបស់ក្រុមហ៊ុនសេវាកម្មផ្នែកច្បាប់មានដូចខាងក្រោម៖

| | |
|---|---|
| ឈ្មោះ | : ការិយាល័យមេធាវី អ អេន ជី សុខ អេន ហេង |
| អាសយដ្ឋាន | : ការិយាល័យអគារវឌ្ឍនៈជាន់ទី១៧ លេខ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ១២២០២ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| អ៊ីម៉ែល | : info.kh@rajahtann.com |
| លេខទូរស័ព្ទ | : +៨៥៥ ២៣ ៩៦៣ ១១២ |
| លេខលិខិតបញ្ជាក់វិជ្ជាជីវៈដែលចេញដោយ គណៈមេធាវីកម្ពុជា | : 128/BACK-KV/19 |
| កាលបរិច្ឆេទចុះបញ្ជីវិញ្ញាបនបត្រ | : ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ |
| លេខចុះបញ្ជីទទួលស្គាល់ដោយន.ម.ក. | : ០០១ ន.ម.ក. |
| កាលបរិច្ឆេទចុះបញ្ជីដោយន.ម.ក. | : ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ |

### ៣.១.៥. ភាគរយនៃផាប់ម្ចិកហ្លួត និងឡុកអាប់

អនុលោមតាមប្រការ ១៧ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិភាគហ៊ុនដែលបានកាន់កាប់ដោយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិកយុទ្ធសាស្ត្រ ជាកម្មវត្ថុនៃការឡុកអាប់រយៈពេល ១ ឆ្នាំទៅតាមទម្រង់ដូចខាងក្រោម៖

- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនរបស់ខ្លួនក្នុងរយៈពេលប្រាំមួយ (០៦) ខែដំបូងបន្ទាប់ពីការចុះបញ្ជីលក់មូលបត្រ
- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់អាចលក់ ឬផ្ទេរភាគហ៊ុនរហូតដល់ ៥០% នៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួនបន្ទាប់ពីប្រាំមួយ (០៦) ខែ បន្ទាប់ពីការចុះបញ្ជីលក់មូលបត្រ
- ភាគហ៊ុនិកយុទ្ធសាស្ត្រមិនត្រូវលក់ ឬផ្ទេរភាគហ៊ុនរបស់ពួកគេសម្រាប់រយៈពេលយ៉ាងហោចណាស់ប្រាំមួយ (០៦) ខែ បន្ទាប់ពីការចុះបញ្ជីលក់មូលបត្រ។

បន្ថែមពីការលើកឡើងខាងលើភាគហ៊ុនចំនួន ១.៩៦១.០០០ ហ៊ុនដែលត្រូវបានផ្តល់ជូនដល់និយោជិតដែលត្រូវបានជ្រើសរើសត្រូវស្ថិតក្រោមការឡុកអាប់ដោយស្ម័គ្រចិត្តសម្រាប់រយៈពេលពីរ (០២) ឆ្នាំ។ តារាងខាងក្រោមបង្ហាញអំពីព័ត៌មានឡុកអាប់ និងភាគហ៊ុនហ្លួតសេរីរបស់ក្រុមហ៊ុនបន្ទាប់ពីចុះបញ្ជីលក់មូលបត្រ៖

**តារាងទី ៣.១៖** តារាងបង្ហាញពីព័ត៌មានឡុកអាប់ និងភាគហ៊ុនហ្លួតសេរីរបស់ក្រុមហ៊ុនបន្ទាប់ពីចុះបញ្ជីលក់មូលបត្រ

| | ភាគហ៊ុនិក | មុនពេលបោះផ្សាយ | | ក្រោយពេលបោះផ្សាយ | | សម្គាល់ |
|---|---|---|---|---|---|---|
| | | ចំនួនភាគហ៊ុន | ភាគរយ | ចំនួនភាគហ៊ុន | ភាគរយ | |
| ឡុកអាប់ (Lock-up) | អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ២២៤.០៧០.០០០ | ៧០ | ២១៩.៨៦៥.៣៨០ | ៦៥,៩ | ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ |
| | លោក គួច អាឡិច | ៤៨.០១៥.០០០ | ១៥ | ៤៧.១១៤.០១០ | ១៤,១ | |
| | លោក គួច ផល | ៤៨.០១៥.០០០ | ១៥ | ៤៧.១១៤.០១០ | ១៤,១ | |
| | បុគ្គលិកជាន់ខ្ពស់ | - | - | [៣០០.០០០] | [០,១] | ភាគហ៊ុនិកយុទ្ធសាស្ត្រ |
| | បុគ្គលិកដែលត្រូវបានជ្រើសរើស | - | - | ១.៩៦១.០០០ | ០,៦ | ឡុកអាប់ដោយស្ម័គ្រចិត្ត |
| | **សរុបបឋម** | **៣២០.១០០.០០០** | **១០០** | **[៣១៦.៣៥៤.៤០០]** | **[៩៤,៨]** | - |
| ភាគហ៊ុនហ្លូតសេរី (Free Floats share) | វិនិយោគិនសក្តានុពល | - | - | ៤.០៤៥.៦០០ | ១,២ | - |
| | បុគ្គលិកទូទៅ | - | - | [១.៥០០.០០០] | [០,៥] | - |
| | វិនិយោគិនសាធារណៈ និងវិនិយោគិនផ្សេងៗទៀត | - | - | ១១.៨០០.០០០ | ៣,៥ | - |
| | **សរុបបឋម** | - | - | **[១៧.៣៤៥.៦០០]** | **[៥,២]** | - |
| | **សរុប** | **៣២០.១០០.០០០** | **១០០** | **៣៣៣.៧០០.០០០** | **១០០** | - |

ប្រភព៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់MJQE ផ្នែកទី២៖ ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត) ទំព័រទី១៩

## ៣.២. ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រត្រូវបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនទៅកាន់ ន.ម.ក. ដើម្បីបំពេញលក្ខខណ្ឌផ្សេងៗ។ ក្នុងនោះ ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ក៏បានដាក់ជូននូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនទៅដល់ ន.ម.ក. ផងដែរដើម្បីទទួលបានការអនុញ្ញាតបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

### ៣.២.១. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក បង្ហាញពីស្ថានភាពទ្រព្យសម្បត្តិ បំណុល និងមូលធនរបស់ក្រុមហ៊ុន ឬត្រូវបានស្គាល់ថាជាតារាងតុល្យការ។ តារាងខាងក្រោមបង្ហាញពីសមាសធាតុលម្អិតនៃទ្រព្យសម្បត្តិ បំណុល និងមូលធនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក សម្រាប់ឆ្នាំ ២០២០ ២០២១ និង ២០២២ ដែលជាទិន្នន័យចាំបាច់សម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ស្របតាមតម្រូវការរបស់ ន.ម.ក.។

**តារាងទី៣.២៖** តារាងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| ឯកតាគិតជាដុល្លារអាមេរិក | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ២៧.៤៣២.៥៤០ | ២៦.៦៨៦.៨៨០ | ២៧.៧៦៦.៣៤១ |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ១៨.៨២៤.៧៧០ | ១៧.៨៨៣.៤០៨ | ២៩.៥១៣.០៥៦ |
| ទ្រព្យសកម្មអរូបី | ៤៥.៩៥១ | ៣៣.១២៦ | ៥០.៨៧០ |
| **សរុប** | **៤៦.៣០៣.២៦១** | **៤៤.៦០៣.៤១៤** | **៥៧.៣៣០.២៦៧** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ១.០២៥.៧៨៦ | ១.៣៥២.៩៤២ | ១.៥២១.៣៥៩ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ២.៧៤២.២៦០ | ៣.៤៨៧.៧៩៦ | ៥.៩៧៤.៣០៦ |

| | | | |
|---|---|---|---|
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | ៦.៨៥៤.៣១១ | ៦.៨៤២.៧៣២ | ៨.៥៧៦.៤៣៣ |
| **សរុប** | **១០.៦៣២.៣៥៧** | **១១.៧២៣.៤៧០** | **១៦.០៧២.០៩៨** |
| **ទ្រព្យសកម្មសរុប** | **៥៦.៩៣៥.៦១៨** | **៥៦.៣២៦.៨៨៤** | **៧៣.៤០២.៣៦៥** |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន | ៥.០០៥.០០០ | ៥.០០៥.០០០ | ៥.០០៥.០០០ |
| ចំណេញរក្សាទុក | ១៣.០៨២.៩៩០ | ១២.០៩៧.៣១៤ | ១១.៦៤២.៤២២ |
| **មូលធនសរុប** | **១៨.០៨៧.៩៩០** | **១៧.១០២.៣១៤** | **១៦.៦៤៧.៤២២** |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១១.៣១៧.៥២៥ | ១០.៤៧៤.០៦៩ | ៩.០០៦.៦៧៤ |
| បំណុលភតិសន្យា | ២០.៣៨១.៦០៤ | ២០.៤៣២.២៥៦ | ៣២.៧៨៧.៤៤៣ |
| **សរុប** | **៣១.៦៩៩.១២៩** | **៣០.៩០៦.៣២៥** | **៤១.៧៩៤.១១៧** |
| **បំណុលរយៈពេលខ្លី** | | | |
| ប្រាក់កម្ចី | ១.៣២៧.១៦១ | ១.៧៧១.៦៧៦ | ២.២០៥.៧២២ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ៨៨១.៧០៦ | ៨២៩.៨៤៩ | ១.២៤៦.៦៣៦ |
| បំណុលភតិសន្យា | ៦៩.០០៤ | ៥៤.៤៨៦ | ៧៤.២៥១ |
| កិច្ចសន្យាបំណុល | ៤.៨៧០.៦២៨ | ៥.៦៦២.២៣៤ | ១១.៤៣៤.២១៧ |
| **សរុប** | **៧.១៤៨.៤៩៩** | **៨.៣១៨.២៤៥** | **១៤.៩៦០.៨២៦** |
| **បំណុលសរុប** | **៣៨.៨៤៧.៦២៨** | **៣៩.២២៤.៥៧០** | **៥៦.៧៥៤.៩៤៣** |
| **មូលធន និងបំណុលសរុប** | **៥៦.៩៣៥.៦១៨** | **៥៦.៣២៦.៨៨៤** | **៧៣.៤០២.៣៦៥** |

ប្រភព៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី៧៖ ព័ត៌មានហិរញ្ញវត្ថុ (ត) ទំព័រទី១៧៨ ដល់ ១៨០

### ៣.២.២. របាយការណ៍ប្រាក់ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ

ខាងក្រោមនេះគឺជាតារាងសង្ខេបនៃរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗដែលបាន

ធ្វើសវនកម្មរួចរាល់របស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន សម្រាប់ឆ្នាំ២០២០, ២០២១ និង ២០២២៖

**តារាងទី៣.៣.៖** តារាងសង្ខេបនៃរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ

| ឯកតាគិតជាដុល្លារអាមេរិក | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| ចំណូល | ១៥.៥៨៣.៣៥៧ | ១៦.៣៤២.៧៤៦ | ១៩.២៦០.៥៤២ |
| ថ្លៃដើមនៃការលក់ និងសេវាកម្ម | (៤.៩៤៨.៨០៤) | (៦.២០៥.៤០៤) | (៧.៣៥២.៨៥៦) |
| **ប្រាក់ចំណេញដុល** | **១០.៦៣៤.៥៥៣** | **១០.១៣៧.៣៤២** | **១១.៩០៧.៦៨៦** |
| ចំណូលផ្សេងៗ | ១២០.៧២៥ | ២០៤.១១៤ | ១៦២.៧៣៣ |
| ចំណាយរដ្ឋបាល | (៦.៨៥៧.១៧៧) | (៧.៣៩៣.៥១៤) | (៨.៤១៣.២៨៣) |
| **ចំណេញពីប្រតិបត្តិការ** | **៣.៨៩៨.១០១** | **២.៩៤៧.៩៤២** | **៣.៦៥៧.១៣៦** |
| ចំណូលហិរញ្ញវត្ថុ | ១១៦.៦៤៣ | ១៧៩.៩៥៨ | ១៤៨.៤២១ |
| ចំណាយហិរញ្ញវត្ថុ | (២.៨៧៧.៧០៦) | (៣.០៨១.៥៥២) | (២.៨២៨.៤២៥) |
| **ចំណេញ/(ខាត)មុនបង់ពន្ធ** | **១.១៣៧.០៣៨** | **៤៦.៣៤៨** | **៩៧៧.១៣២** |
| ចំណាយពន្ធ | – | – | – |
| **ប្រាក់ចំណេញ/ខាត ក្នុងគ្រា/ឆ្នាំ** | **១.១៣៧.០៣៨** | **៤៦.៣៤៨** | **៩៧៧.១៣២** |
| សរុបចំណូលលម្អិតផ្សេងៗ សុទ្ធនៃពន្ធ | – | – | – |
| **ចំណូល/(ខាត)លម្អិតសរុប ក្នុងគ្រា/ឆ្នាំ** | **១.១៣៧.០៣៨** | **៤៦.៣៤៨** | **៩៧៧.១៣២** |

ប្រភព៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី៧៖ ព័ត៌មានហិរញ្ញវត្ថុ (ត) ទំព័រទី១៧៧ ដល់១៧៨

## ៣.៣. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាសាធារណៈលើកដំបូង

### ៣.៣.១. ព័ត៌មានអំពីការដាក់សំណើការផ្សាយលក់មូលបត្រកម្មសិទ្ធិ

ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់មានដូចខាងក្រោម ៖

ឈ្មោះមូលបត្រកម្មសិទ្ធិ : ភាគហ៊ុនធម្មតា

ប្រភេទមូលបត្រកម្មសិទ្ធិ : ភាគហ៊ុនធម្មតា

តម្លៃចារឹក : ២០០ រៀល (០,០៥ ដុល្លារអាម៉េរិក)

ថ្លៃលក់ : ២.០៨០ រៀល (០,៥១ ដុល្លារអាម៉េរិក)

បរិមាណបោះផ្សាយលក់សរុប : សំណើបោះផ្សាយសរុប ១៩.៦០៦.៦០០ ភាគហ៊ុនរួមមាន៖

- សំណើបោះផ្សាយជាសាធារណៈចំនួនរហូតដល់ ១៣.៦០០.០០០ ភាគហ៊ុនថ្មី
- សំណើលក់ចំនួនរហូតដល់ ៦.០០៦.៦០០ ភាគហ៊ុនមានស្រាប់

តម្លៃបោះផ្សាយលក់សរុប :

- សំណើបោះផ្សាយជាសាធារណៈចំនួន ២៨.២៨៨ លានរៀល (៦.៩៤ លាន ដុល្លារអាម៉េរិក)
- សំណើលក់ចំនួន ១២.៤៩៤លានរៀល (៣,០៦ លានដុល្លារ អាម៉េរិក)

កាលបរិច្ឆេទចាប់ផ្តើមបរិវិសកម្ម : ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣

កាលបរិច្ឆេទបញ្ចប់បរិវិសកម្ម : ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣

ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិ: ក្រុមហ៊ុនមានប្រភេទភាគហ៊ុនតែមួយ (១) ប្រភេទ ប៉ុណ្ណោះដែលមានឈ្មោះថា ភាគហ៊ុនធម្មតា ក្នុងតម្លៃចារឹក 0,0៥ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុនដែលម្ចាស់ភាគហ៊ុននីមួយៗមានសិទ្ធិ និងកាតព្វកិច្ចដូចៗគ្នាហើយមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ ត្រូវបានចាត់ថ្នាក់ស្មើនឹងភាគហ៊ុនបានបោះដែលមានស្រាប់របស់ក្រុមហ៊ុន ដោយភាគហ៊ុនិកនីមួយៗត្រូវមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬ តាមរយៈអាណត្តិគាហក។

### ៣.៣.២. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ

IPO ដែលមានចំនួនសរុបរហូតដល់ ១៩.៦០៦.៦០០ ភាគហ៊ុនដែលតំណាងឱ្យ ៥,៨៨% នៃមូលធនភាគហ៊ុនដែលបានបោះផ្សាយក្នុងតម្លៃ IPO ២.០៨០ រៀល (0,៥១ ដុល្លារអាម៉េរិក) ក្នុងមួយភាគហ៊ុនចេញផ្សាយនឹងត្រូវបែងចែកតាមរបៀបកំណត់ដូចខាងក្រោម៖

**តារាងទី ៣.៤៖** តារាងផែនការបែងចែកមូលបត្រកម្មសិទ្ធិ

| **ក្រុមវិនិយោគិន** | **ចំនួនភាគហ៊ុន** | **ភាគរយ%** |
|---|---|---|
| លែបម្រុងទុកសម្រាប់វិនិយោគិនសក្តានុពល | ៤.០៤៥.៦០០ | ២០,៦ |
| លែបម្រុងទុកសម្រាប់ឪពុកម្តាយសិស្ស | ៤.០០០.០០០ | ២០,៤ |
| លែបម្រុងទុកសម្រាប់គណៈគ្រប់គ្រង និងបុគ្គលិក | ៣.៧៦១.០០០ | ១៩,២ |
| វិនិយោគិនសាធារណៈ | ៧.៨០០.០០០ | ៣៩,៨ |
| **សរុប** | ១៩.៦០៦.០០០ | ១០០ |

ប្រភព៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី២៖ ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត) ទំព័រទី២៩ ដល់៣០

គួរបញ្ជាក់ផងដែលថា ការបែងចែកភាគហ៊ុនចុងក្រោយសម្រាប់អ្នកវិនិយោគិនសាធារណៈ និយោជិត/អភិបាល/បុគ្គលិកជាន់ខ្ពស់ និងឪពុកម្តាយរបស់សិស្សអាចមានភាពខុសពីអ្វីដែលបានបង្ហាញខាងលើ ហើយនឹងត្រូវធ្វើឡើងតាមលទ្ធផលនៃការស្នើទិញ និងការអនុម័តពី SERC ។ ប្រសិនបើមានការស្នើទិញលើសពីនេះ ភាគហ៊ុនដែលត្រូវបានបែងចែកសម្រាប់អ្នកវិនិយោគសាធារណៈ/បុគ្គលិក/អភិបាល/ បុគ្គលិកជាន់ខ្ពស់ និងឪពុកម្តាយរបស់សិស្សនឹងត្រូវបានបែងចែកតាមមូលដ្ឋានសមាមាត្រ។ ក្នុងករណីដែលចំនួននៃការស្នើទិញសរុបទាបជាងចំនួនភាគហ៊ុនដែលបាន ផ្តល់ជូន ភាគហ៊ុននឹងមិនត្រូវបានចេញលក់ពីក្រុមហ៊ុននោះទេ។

### ៣.៣.៣. តម្លៃមួយឯកតានៃមូលបត្រកម្មសិទ្ធិ

មុនពេលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈភាគហ៊ុនរបស់ក្រុមហ៊ុនមិនមាននៅលើទីផ្សារសាធារណៈឡើយ។ តម្លៃនៃមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈគឺ ២.០៨០ រៀល (0,៥១ ដុល្លារអាម៉េរិក) ក្នុងមួយភាគហ៊ុនដែលត្រូវបានកំណត់ និងព្រមព្រៀងដោយក្រុមប្រឹក្សាភិបាល និងក្រុមហ៊ុនធានាទិញមូលបត្រ បន្ទាប់ពីបានពិចារណាទៅលើកត្តានានាដូចខាងក្រោម៖

#### ក. លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអំឡុងឆ្នាំហិរញ្ញវត្ថុក្រោមការត្រួតពិនិត្យឡើងវិញ

ប្រាក់ចំណូលសម្រាប់ FPE ២០២២ ត្រូវបានកត់ត្រាមានតម្លៃ ១៩,៣ លានដុល្លារអាម៉េរិក ដែលបានកើនឡើងចំនួន ៦,២ លានដុល្លារអាម៉េរិក ឬស្មើនឹង ៤៧,៨១% ធៀបនឹង FPE ២០២១។ ដោយមានការបន្ធូរបន្ថយរបស់រាជរដ្ឋាភិបាលក្នុងការរិតត្បិតនៃជំងឺកូវីដ-១៩ ក្នុងខែវិច្ឆិកា ឆ្នាំ២០២១ បានធ្វើឱ្យចំនួនសិស្សតាមសាខានីមួយៗមានការកើនឡើង ដូច្នេះហើយទើបបានជា ធ្វើឱ្យប្រាក់ចំណូលមានការកើនឡើងផងដែរ។ លើសពីនេះទៅទៀត យើងបានកត់ត្រាចំណេញមុនបង់ពន្ធ ចំនួន 0,៩៨ លានដុល្លារអាម៉េរិកនៅក្នុង FPE ឆ្នាំ

២០២២ ដែលមានការកើនឡើង ១,៣៧ លានដុល្លារអាម៉េរិកធៀបនឹង FPE ២០២១។ ការកើនឡើងនៃចំណេញមុនបង់ពន្ធសម្រាប់កំឡុងពេលនេះ ត្រូវបានជម្រុញតាមរយៈកំណើននៃប្រាក់ចំណូលដែលបានពីថ្លៃសិក្សា និងចំណូលពាក់ព័ន្ធផ្សេងទៀត។

ដោយផ្អែកលើមូលធនភាគហ៊ុនដែលបានបោះផ្សាយ និងភាគហ៊ុនដែលបានទូទាត់នៅពេលចុះបញ្ជីលក់មូលបត្រចំនួន ៣៣៣.៧០០.០០០ ភាគហ៊ុនចំណេញសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនមានចំនួន ០,០០៣៩១ ដុល្លារអាម៉េរិកសម្រាប់ឆ្នាំសារពើពន្ធ FYE ២០២០ និង ០,០០០១៤ ដុល្លារអាម៉េរិកសម្រាប់ឆ្នាំសារពើពន្ធ FYE ២០២១ និង ០,០០២៩៣ ដុល្លារអាម៉េរិក សម្រាប់ FPE ២០២២ ។

### ខ. ទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុន

បន្ទាប់ពីការកែតម្រូវលើការប្រើប្រាស់ប្រាក់ដែលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ និងការប៉ាន់ស្មានការចំណាយលើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនក្នុងមួយភាគហ៊ុនគិតត្រឹម FPE ២០២២ (ផ្អែកលើមូលធនភាគហ៊ុនដែលបានបោះផ្សាយ និងភាគហ៊ុនដែលបានទូទាត់នៅពេលចុះបញ្ជីលក់មូលបត្រចំនួន ៣៣៣.៧០០.០០០ ភាគហ៊ុន) អាចនឹងស្មើចំនួនទឹកប្រាក់ ០,០៦៩៣ ដុល្លារអាម៉េរិក។

### គ. ប្រវត្តិប្រតិបត្តិការរបស់ក្រុមហ៊ុន

ប្រវត្តិប្រតិបត្តិការរបស់ក្រុមហ៊ុន និងដំណើរការរបស់ក្រុមហ៊ុនមានពិពណ៌នាក្នុងចំណុច ២.១ នៃជំពូកទី២។

### ឃ. ទស្សនៈ និងផែនការអនាគតរបស់ក្រុមហ៊ុន

ការរំពឹងទុកពីអនាគតក្នុងឧស្សាហកម្មដែលក្រុមហ៊ុនកំពុងដំណើរការផែនការអនាគត យុទ្ធសាស្ត្រ និងការរំពឹងទុកនានា នឹងមានពិពណ៌នានៅក្នុងចំណុច ២.៤.២ នៃជំពូកទី២ ។

### ង. លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន

លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ដែលរួមមាននិន្នាការទីផ្សារបច្ចុប្បន្ន និងចំណាប់អារម្មណ៍របស់វិនិយោគិន។ គួរកត់សម្គាល់ថាតម្លៃទីផ្សារភាគហ៊ុនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ពីមុននិងបន្តបន្ទាប់នៃការចុះបញ្ជីនៅលើក្រុមប្រឹក្សាភិបាលនៃ CSX គឺអាស្រ័យទៅលើកំណើនទីផ្សារ និងភាពមិនជាក់លាក់ផ្សេងទៀតដែលអាចប៉ះពាល់ដល់តម្លៃភាគហ៊ុនដែលកំពុងត្រូវបានជួញដូរ។ មុនពេលធ្វើការសម្រេចចិត្ត វិនិយោគិនគួរតែពិចារណារួមជាមួយនឹងកត្តាផ្សេងទៀតនៅកត្តាហានិភ័យដែលមានចែងក្នុងចំណុច ២.៨ នៃជំពូកទី២។

កំណត់ចំណាំ៖ ការបែងចែកភាគហ៊ុនចុងក្រោយសម្រាប់អ្នកវិនិយោគសាធារណៈ និយោជិត/អភិបាល/បុគ្គលិកជាន់ខ្ពស់ និងឪពុកម្តាយរបស់សិស្សអាចមានភាពខុសពីអ្វីដែលបានបង្ហាញខាងលើ ហើយនឹងត្រូវធ្វើ

ឡើងតាមលទ្ធផលនៃការស្នើទិញ និងការអនុម័តពី SERC ។ ប្រសិនបើមានការស្នើទិញលើសពីនេះ ភាគហ៊ុនដែលត្រូវបានបែងចែកសម្រាប់អ្នកវិនិយោគសាធារណៈ/បុគ្គលិក/អភិបាល/បុគ្គលិកជាន់ខ្ពស់ និងឪពុកម្តាយរបស់សិស្សនឹងត្រូវបានបែងចែកតាមមូលដ្ឋានសមមាត្រ។ ក្នុងករណីដែលចំនួននៃការស្នើទិញសរុបទាបជាងចំនួនភាគហ៊ុនដែលបានផ្តល់ជូន ភាគហ៊ុននឹងមិនត្រូវបានចេញលក់ពីក្រុមហ៊ុននោះទេ។

**៣.៣.៤. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ**

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក រំពឹងថា សាច់ប្រាក់ដុលដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងមានទំហំសរុបប្រមាណ ៦,៩៤ លានដុល្លារអាម៉េរិក ឬ ២៨.២៨៨ លានរៀលដោយផ្អែកលើតម្លៃ IPO ឬ ២.០៨០ រៀល(0,៥១ ដុល្លារអាម៉េរិក)ក្នុងមួយហ៊ុន។ ក្រុមហ៊ុននឹងត្រូវទទួលបានសាច់ប្រាក់នោះ ហើយត្រូវទទួលរ៉ាប់រងលើការចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិសម្រាប់ដើមទុនដែលបានបោះផ្សាយ និងបង់រួចរាល់ទាំងអស់នៅ ផ.ម.ក.។

ក្រុមហ៊ុនមានបំណងប្រើប្រាស់សាច់ប្រាក់តាមការបែងចែងដូចខាងក្រោម៖

**តារាងទី ៣.៥៖** តារាងគោលបំណងនៃការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីIPO

| ព័ត៌មានលម្អិតអំពីការប្រើប្រាស់ | រយៈពេលរំពឹងទុកសម្រាប់ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយ | ចំនួនទឹកប្រាក់ (ដុល្លារអាមេរិក) | ភាគរយនៃសាច់ប្រាក់ដុល(%) |
|---|---|---|---|
| **ហិរញ្ញប្បទានសម្រាប់គម្រោងសាងសង់ ឬកែលម្អសាខាថ្មី** | រយៈពេល២៤ខែ | ៦.000.000 | ៨៦,៥ |
| **ទុនបង្វិល** | រយៈពេល១២ខែ | ៣៧៤.២00 | ៥,៤ |
| **ការប៉ាន់ប្រមាណចំណាយលើការបោះផ្សាយ** | រយៈពេល0៣ខែ | ៥៦១.៨00 | ៨,១ |
| សាច់ប្រាក់ដុលសរុប | | ៦.៩៣៦.000 | ១00 |

ប្រភព៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី២៖ ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត) ទំព័រទី៣0

**ក. ហិរញ្ញប្បទានសម្រាប់គម្រោងសាងសង់ ឬកែលម្អសាខាថ្មី**

ក្រុមហ៊ុនមានបំណងបែងចែកសាច់ប្រាក់ប្រមាណ ៦,០ លានដុល្លារអាម៉េរិក ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ចំណាយបដិភាគទៅលើថ្លៃសាងសង់ សាខាថ្មីចំនួនប្រាំមួយ (០៦) រួមមាន Aii និង AIS សាខាច្បារអំពៅ Aii និង AIS សាខាកំពង់ចាម និង Aii និង AIS សាខាបាត់ដំបង។

រាល់មូលនិធិ ដែលនៅសល់ពីការប្រើប្រាស់សម្រាប់ហិរញ្ញប្បទានសម្រាប់សាខានាពេលអនាគតនឹងត្រូវយកទៅប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនបង្វិលរបស់ក្រុមហ៊ុន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើការបែងចែកសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រជាសាធារណៈមិនគ្រប់គ្រាន់សម្រាប់ហិរញ្ញប្បទានលើសាខានាពេលអនាគតទេ ការខ្វះខាតនោះនឹងត្រូវបង្គ្រប់ដោយមូលនិធិផ្ទៃក្នុង ទុនបង្វិល ឥណទានពីអ្នកផ្គត់ផ្គង់ និង/ឬ កម្ចី/ហិរញ្ញប្បទាន។ ខណៈពេលដែលក្រុមហ៊ុនបន្តវិនិយោគទៅលើសាខារបស់ពួកគេបន្ថែមទៀត ក្រុមហ៊ុក៏នឹងស្វែងរកធនធានមូលនិធិពីស្ថាប័នហិរញ្ញវត្ថុផងដែរដើម្បីគាំទ្រដល់ការរីកចម្រើនរបស់ពួកគេ។

**ខ. ទុនបង្វិល**

ក្រុមហ៊ុនបានកំណត់ទុកសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រជាសាធារណៈប្រមាណ ០,៣៧ លានដុល្លារអាម៉េរិក ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានលើប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ដែលរួមមាន ការចំណាយលើកម្លាំងពលកម្ម សម្ភារការិយាល័យ និងបរិក្ខារប្រព័ន្ធព័ត៌មានវិទ្យា និងចំណាយទូទៅផ្សេងទៀត។

**គ. ការប៉ាន់ប្រមាណចំណាយក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង**

ការប៉ាន់ប្រមាណលើចំណាយក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ប្រមាណ ០,៥៦ លានដុល្លារអាម៉េរិក។ ប្រសិនបើការចំណាយជាក់ស្តែងខ្ពស់ជាងការប៉ាន់ស្មាន ចំនួនដែលខ្វះនឹងត្រូវទូទាត់តាមរយៈទុនបង្វិល។ ផ្ទុយមកវិញ ប្រសិនបើការចំណាយជាក់ស្តែងទាបជាងការប៉ាន់ស្មានចំនួនដែលលើសនឹងត្រូវយកមកប្រើប្រាស់សម្រាប់តម្រូវការទុនបង្វិលរបស់ក្រុមហ៊ុនវិញ។ ក្រុមហ៊ុនគ្រោងនឹងយកសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (រួមមានការប្រាក់បង្គរប្រសិនមាន) ឬសមតុល្យទឹកប្រាក់របស់ក្រុមហ៊ុន ដែលមានក្នុងនោះដាក់បញ្ញើនៅធនាគារ ឬស្ថាប័នហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ក្នុងទម្រង់ជាមូលនិធិ/ឧបករណ៍ហិរញ្ញវត្ថុដែលអាចជួញដូរបាន ដែលមានការប្រាក់មុនពេលយកមកប្រើប្រាស់សម្រាប់គោលបំណងក្រុមហ៊ុន។

### ៣.៣.៥. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង

សេចក្តីសង្ខេបអំពីការចំណាយ និងសោហ៊ុយទាំងអស់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិមានដូចខាងក្រោម៖

**តារាងទី ៣.៦៖** តារាងសង្ខេបអំពីការចំណាយ និងសោហ៊ុយទាំងអស់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

| **ការប៉ាន់ប្រមាណលើការចំណាយ** | **ដុល្លារអាមេរិក** | **លានរៀល** |
|---|---|---|
| ចំណាយលើក្រុមហ៊ុនធានាទិញមូលបត្រ និងកម្រៃជើងសារ | ៣១៨.៧២០ | ១.២៧៤,៩ |
| ចំណាយលើការដាក់ជូន និងចុះបញ្ជីនៃឯកសារផ្តល់ព័ត៌មាន(ន.ម.ក.) | ៣.០០០ | ១២ |
| ចំណាយលើការចុះបញ្ជី(ផ.ម.ក.) | ៣០.១១៩ | ១២០,៥ |
| ចំណាយលើការផ្សព្វផ្សាយ ការធ្វើដំណើរ ការធ្វើរ៉ូដសូ និងការបោះពុម្ព | ៣០.០០០ | ១២០ |
| ចំណាយផ្នែកវិជ្ជាជីវៈ | ៦៧.០០០ | ២៦៨ |
| ចំណាយលើសេវាភ្នាក់ងារបញ្ជិកាមូលបត្រ | ២.០០០ | ៨ |
| ចំណាយផ្សេងៗ | ១៩.១៦១ | ៧៦,៦ |
| ចំណាយលើការបញ្ចុះតម្លៃ IPO សម្រាប់បុគ្គលិក | ៩១.៨០០ | ៣៦៧,២ |
| **សរុប** | ៥៦១.៨០០ | ២.២៤៧,២ |

ប្រភព៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE ផ្នែកទី២៖ ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត) ទំព័រទី២២

#### ៣.៣.៥.១. ការចំណាយក្រុមហ៊ុនធានាទិញមូលបត្រ និងកម្រៃជើងសារ

ក្រុមហ៊ុនប៉ាន់ប្រមាណថា សោហ៊ុយ និងកម្រៃជើងសារដែលចំណាយលើក្រុមហ៊ុនធានាទិញមូលបត្រមានប្រមាណ ៣១៨.៧២០ ដុល្លារអាម៉េរិក (១.២៧៤,៩ លានរៀល)។ សោហ៊ុយសរុបនឹងត្រូវកំណត់ដោយផ្អែកលើតម្លៃបោះផ្សាយមូលបត្រជាសាធារណៈ និងតម្លៃមូលបត្រកម្មសិទ្ធិចុងក្រោយបន្ទាប់ពីទទួលបានសេចក្តីសម្រេចពី ន.ម.ក. ទៅលើលក្ខខណ្ឌនៃសំណើលក់របស់ក្រុមហ៊ុន។

#### ៣.៣.៥.២. ការចំណាយលើការដាក់ជូន និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

ក្រុមហ៊ុននឹងទូទាត់ការចំណាយចំនួន ១២ លានរៀល (៣.០០០ ដុល្លារអាម៉េរិក) សម្រាប់ការ ដាក់ជូន និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក. ។

#### ៣.៣.៥.៣. ការចំណាយលើការចុះបញ្ជី

ក្រុមហ៊ុននឹងទូទាត់ជូន ផ.ម.ក. នូវចំនួនទឹកប្រាក់ដែលមានដូចខាងក្រោម៖

- ៤លានរៀល (១.០០០ ដុល្លារអាម៉េរិក) សម្រាប់ការពិនិត្យមើលលើលទ្ធភាពអាចចុះបញ្ជី និង
- ប្រមាណ ១១៦,៥ លានរៀល (២៩.១១៩ ដុល្លារអាម៉េរិក) សម្រាប់ការចំណាយលើការចុះ បញ្ជីលើកដំបូង។ ចំនួនទឹកប្រាក់ជាក់ស្តែងនឹងត្រូវកំណត់បន្ទាប់ពីតម្លៃនៃការបោះផ្សាយលក់មូលបត្រត្រូវកំណត់រួចរាល់។

#### ៣.៣.៥.៤. ការចំណាយលើការផ្សព្វផ្សាយ ការធ្វើដំណើរ ការធ្វើរ៉ូដសូ និងការបោះពុម្ព

ក្រុមហ៊ុនប៉ាន់ប្រមាណថា ចំណាយលើការផ្សព្វផ្សាយការធ្វើដំណើរ ការធ្វើរ៉ូដសូ និងការបោះពុម្ពមានចំនួនប្រមាណ ៣០.០០០ ដុល្លារអាម៉េរិក (១២០ លានរៀល)។

#### ៣.៣.៥.៥. ការចំណាយផ្នែកវិជ្ជាជីវៈ

ការចំណាយផ្នែកវិជ្ជាជីវៈរួមមាន ការចំណាយលើសេវាប្រឹក្សាផ្នែកច្បាប់ និងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ។

#### ៣.៣.៥.៦. ការចំណាយលើសេវាភ្នាក់ងារបញ្ជីកាមូលបត្រ

ការចំណាយទៅលើសេវាភ្នាក់ងារបញ្ជីកាមូលបត្រប្រមាណជាង ២.០០០ ដុល្លារអាម៉េរិក(៨ លានរៀល)។

#### ៣.៣.៥.៧. ការចំណាយលើការបញ្ចុះតម្លៃលើថ្លៃបោះផ្សាយលក់ភាគហ៊ុនលើកដំបូងសម្រាប់បុគ្គលិក និងចំណាយផ្សេងៗ

ក្រុមហ៊ុនប៉ាន់ប្រមាណថា ការចំណាយលើការបញ្ចុះតម្លៃ IPO សម្រាប់បុគ្គលិកមានចំនួនប្រមាណ ៩១.៨០០ ដុល្លារអាមេរិក (៣៦៧,២លានរៀល)។

ក្រុមហ៊ុនប៉ាន់ប្រមាណថា ការចំណាយផ្សេងៗមានប្រមាណ ១៩.១៦១ ដុល្លារអាមេរិក(៧៦,៦លានរៀល)។

## ៣.៤. ភាគព្វកិច្ចភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

### ៣.៤.១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិកនីមួយៗមានសិទ្ធិ៖

- ទទួលបានភាគលាភដែលប្រកាសដោយក្រុមហ៊ុន
- ទទួលបានទ្រព្យសម្បត្តិដែលនៅសេសសល់របស់ក្រុមហ៊ុនពេលមានការរំលាយ

- បោះឆ្នោតនៅក្នុងកិច្ចប្រជុំជាមួយភាគហ៊ុនិកនៃក្រុមហ៊ុន និង
- សិទ្ធិដទៃផ្សេងទៀត (រួមបញ្ចូលសិទ្ធិទទួលព័ត៌មាន) ដូចដែលបានផ្តល់ឱ្យក្រោមបទប្បញ្ញត្តិនៃមូលបត្រ

**៣.៤.២. ការការពារសិទ្ធិភាគហ៊ុនិក និងការអនុវត្ត**

សិទ្ធិរបស់ភាគហ៊ុនិកត្រូវបានការពារដោយលក្ខន្តិកៈក្រុមហ៊ុន។ យោងតាមលក្ខន្តិកៈក្រុមហ៊ុន អ្នកកាន់កាប់ភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនត្រូវបានទទួលបានសំឡេងបោះឆ្នោតមួយនៅក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

**៣.៤.៣. ការការពារសិទ្ធិភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនតិច និងការអនុវត្ត**

ភាគហ៊ុនិករបស់ក្រុមហ៊ុនទទួលបានការការពារសិទ្ធិដូចៗគ្នា ហើយត្រូវបានការពារដោយលក្ខន្តិកៈក្រុមហ៊ុន។ មួយភាគហ៊ុនស្មើនឹងសម្លេងបោះឆ្នោតមួយ។

នៅក្នុងឆ្នាំ២០២៣ ក្រុមហ៊ុនបានធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួនលើកដំបូង ហើយក្រុមហ៊ុន បានតែងតាំងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងគេហទំព័រទំនាក់ទំនងវិនិយោគិន ដើម្បីគាំពារដល់ភាគហ៊ុនិក ក៏ដូចជាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនភាគតិចរបស់ក្រុមហ៊ុនផងដែរ។

**៣.៤.៤. មហាសន្និបាតភាគហ៊ុនិក**

**៣.៤.៤.១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក**

ក្រុមហ៊ុនបានអនុម័តនូវគោលការណ៍ស្តីពីការបោះឆ្នោតនៅក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកដែលផ្តល់នូវវិធានការ និងការណែនាំច្បាស់លាស់ដល់ភាគហ៊ុនិកអំពីដំណើរការបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។

**ក. កូរ៉ុម**

កូរ៉ុម[28]នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក គឺជាចំនួនភាគហ៊ុនិកដែលចូលរួមជាយផ្ទាល់ និងតាមរយៈការប្រគល់សិទ្ធិ (តំណាងដោយអាណត្តិគាហកៈ) ដែលកាន់កាប់ភាគហ៊ុនចំនួនយ៉ាងតិច ៥១% នៃចំនួនភាគហ៊ុនសរុបរបស់ក្រុមហ៊ុន។

**ខ. ការជូនដំណឹងអំពីកិច្ចប្រជុំ**

លិខិតជូនដំណឹងអំពីកិច្ចប្រជុំនឹងផ្ញើជូនភាគហ៊ុនិកតាមមធ្យោបាយផ្សេងៗ ដូចជាៈ ឯកសាររឹង និង/ឬ តាមរយៈ ប្រព័ន្ធអេឡិចត្រូនិក ក្នុងកំឡុងពេលចាប់ពី ២០ ទៅ ៥០ ថ្ងៃ មុនកាលបរិច្ឆេទប្រជុំ។ លិខិតជូនដំណឹងអំពីកិច្ចប្រជុំមាន បញ្ជាក់ច្បាស់អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលនឹងត្រូវប្រារព្ធកិច្ចប្រជុំ។

[28] កូរ៉ុម គឺជាចំនួនអ្នកចូលរួមជាចាំបាច់អប្បបរមា( តិច បំផុត )ដើម្បីធ្វើឱ្យការបោះឆ្នោតឬសកម្មភាពផ្សេងៗទៀតរបស់ស្ថាប័នឬអង្គការមួយមានសុពលភាព។

### គ. កំឡុងពេលកិច្ចប្រជុំ និងដំណើរការបោះឆ្នោត

ប្រធានក្រុមប្រឹក្សាភិបាលនឹងចាប់ផ្តើមកិច្ចប្រជុំ ដោយផ្តល់នូវមតិស្វាគមន៍ និងកំណត់បង្ហាញនូវកូរ៉ុម ដែលបានចូលរួម និងប្រកាសអំពីរបៀបវារៈនៃកិច្ចប្រជុំ។ ប្រធានក្រុមប្រឹក្សាភិបាលបញ្ជាក់អំពីនីតិវិធីនៃការបោះឆ្នោតជូនដល់ភាគហ៊ុនិកដែលបានចូលរួមមុននឹងប្រកាសចាប់ផ្តើមដំណើរការបោះឆ្នោតលើសេចក្តីសម្រេចណាមួយ។ ក្រុមហ៊ុននឹងចាត់តាំងជាមុននូវបុគ្គលិកសម្រាប់ជួយសម្របសម្រួលដល់ដំណើរការនៃការបោះឆ្នោត។ លទ្ធផលនៃការបោះឆ្នោតនឹងត្រូវប្រកាសក្រោយពេលដែលការរាប់សន្លឹកឆ្នោត និងសន្លឹកឆ្នោតរបស់តំណាងដោយអាណត្តិគាហកៈដោយផ្ទាល់ដៃ ឬតាមរយៈប្រព័ន្ធ។

### ឃ. ក្រោយកិច្ចប្រជុំ

ក្រុមហ៊ុនត្រូវធ្វើការបង្ហាញព័ត៌មាន និងរាយការណ៍ស្របតាមប្រកាសលេខ៖ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ដែលចេញដោយ ន.ម.ក. និងស្របតាមគោលការណ៍បង្ហាញ ព័ត៌មានរបស់ក្រុមហ៊ុន។

## ៣.៥. គោលនយោបាយភាគលាភ

យោងតាមការរឹតបន្តឹងលើការប្រកាសភាគលាភក្រោមច្បាប់ជាធរមាន ភាគហ៊ុនិកទាំងអស់របស់ក្រុមហ៊ុនមានសិទ្ធិទទួលបានភាគលាភដែលបានត្រូវប្រកាស និងទូទាត់ដោយក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានបំណងផ្តល់អនុសាសន៍ទៅលើភាគលាភ ដើម្បីអនុញ្ញាតឱ្យភាគហ៊ុនិកទាំងអស់ចូលរួមក្នុងការទទួលបានប្រាក់ចំណេញរបស់ក្រុមហ៊ុន ក៏ដូចជារក្សាបាននូវទុនបម្រុងគ្រប់គ្រាន់ សម្រាប់ការលូតលាស់របស់ក្រុមហ៊ុននាពេលអនាគត។ ភាគលាភដែលក្រុមប្រឹក្សាភិបាលនឹងផ្តល់អនុសាសន៍ ឬប្រកាសនៅឆ្នាំហិរញ្ញវត្ថុជាក់លាក់ណាមួយ ឬអំឡុងពេលណាមួយ គឺពឹងផ្អែកលើកកត្តាផ្សេងៗដែលរៀបរាប់ខាងក្រោម ក៏ដូចជាកត្តាផ្សេងទៀតពាក់ព័ន្ធនឹងក្រុមប្រឹក្សាភិបាល។ ក្រុមហ៊ុននឹងពិចារណាលើកត្តាផ្សេងៗដូចដែលបានកំណត់ខាងក្រោម ដើម្បីកំណត់កម្រិតនៃការទូទាត់ភាគលាភ៖

(i) កម្រិតនៃសាច់ប្រាក់ និងប្រាក់ចំណេញរក្សាទុករបស់ក្រុមហ៊ុន

(ii) លទ្ធផលហិរញ្ញវត្ថុ ប្រវត្តិសាស្ត្រ និងរំពឹងទុករបស់ក្រុមហ៊ុន

(iii) កម្រិតនៃការព្យាករណ៍នៃចំណាយមូលធន និងផែនការវិនិយោគផ្សេងៗរបស់ក្រុមហ៊ុន

(iv) លក្ខខណ្ឌតម្រូវនៃទុនបង្វិលរបស់ក្រុមហ៊ុន និង

(v) ការរឹតត្បិតតាមរយៈកិច្ចសន្យា និង/ឬបំណុលដែលអាចកើតមានណាមួយ

សម្រាប់ភាគលាភក្នុង FYE ២០២៣ និង FYE ២០២៤ តែប៉ុណ្ណោះ (រយៈពេលធានាភាគលាភ) ក្រុមហ៊ុនធានាក្នុងការប្រកាស និងចែកចាយភាគលាភចំនួន ០,០៣០៦ ដុល្លារអាមេរិក ក្នុងមួយហ៊ុនក្នុងតម្លៃ IPO ("ភាគលាភត្រូវបានធានា")។ ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលប់ បានយល់ព្រមជាលក្ខណៈបុគ្គល និងបានអនុវត្តចំពោះក្រុមហ៊ុនដើម្បីលះបង់ និងបោះបង់សិទ្ធិលើភាគលាភត្រូវបានធានា ហើយយល់ព្រមទទួលភាគលាភដែលត្រូវបានស្នើឡើងដោយក្រុមប្រឹក្សាភិបាល និង អនុម័តដោយម្ចាស់ភាគហ៊ុន។

## ៣.៦. ដំណើរការបរិវិសកម្ម

### ៣.៦.១. ព័ត៌មានលម្អិតនៃកម្មវិធីរ៉ូដស្ហូជាសាធារណៈ

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ដែលជាស្ថាប័នអប់រំឯកជនឈានមុខគេក្នុងប្រទេសកម្ពុជាបានរៀបចំកម្មវិធីរ៉ូដស្ហូក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈលើកដំបូង (IPO) នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា កាលពីថ្ងៃទី១៩ មេសា ឆ្នាំ២០២៣។

### ៣.៦.២. ការធ្វើបរិវិសកម្មជាសាធារណៈ និងគម្រោងពេលវេលាកំណត់នៃការបោះផ្សាយ

**សម្រាប់វិនិយោគិនដែលបានធ្វើការស្នើសុំបម្រុងទុក៖**

- កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម៖ ម៉ោង០៨:០០ព្រឹក ថ្ងៃទី១០ ខែមេសា ២០២៣
- កាលបរិច្ឆេទបញ្ចប់ការទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម៖ ម៉ោង០៤:៣០រសៀល ថ្ងៃទី២៨ ខែមេសា ២០២៣

**សម្រាប់វិនិយោគិនសាធារណៈទូទៅ៖**

- កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម៖ ម៉ោង០៨:០០ព្រឹក ថ្ងៃទី១០ ខែមេសា ២០២៣
- កាលបរិច្ឆេទបញ្ចប់ការទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម៖ ម៉ោង០៤:៣០រសៀល ថ្ងៃទី០៩ ខែមិថុនា ២០២៣
- ការបញ្ជូនសេចក្តីជូនដំណឹងដល់វិនិយោគិនដែលជោគជ័យ៖ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣
- ការបែងចែកមូលបត្រកម្មសិទ្ធិសម្រាប់វិនិយោគិនដែលជាគជ័យ៖ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣
- កាលបរិច្ឆេទចុះបញ្ជីមូលបត្រ៖ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣[29]

[29] https://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=97 (ចូលទស្សនាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤)

| | |
|---|---|
| ឈ្មោះធនាគារ | ACLEDA Bank Plc. |
| ឈ្មោះគណនី | MENGLY J. QUACH EDUCATION. -Subscription account |
| លេខគណនី(ដុល្លារ) | 00010482225555 |
| លេខគណនី(រៀល) | 00010482225565 |
| Swift code | ACLBKHPP[30] |

### ៣.៦.៣. លទ្ធផលនៃការធ្វើបរិវិសកម្ម

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក និងក្រុមហ៊ុន អ អេច បី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក បាន បង្ហាញលទ្ធផលនៃការធ្វើបរិវិសកម្មសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង នៃ ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ដែលបានចាប់ផ្ដើមពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ និងត្រូវបាន បិទបញ្ចប់ដោយជោគជ័យនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣។ ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលត្រូវបានធ្វើ បរិវិសកម្មមានចំនួនសរុប ៩.៩៦៦.១២៧ ដោយមានវិនិយោគិនចូលរួមសរុបចំនួន ២.២៩៧ នាក់។

## ៣.៧. ស្ថានភាពភាគហ៊ុនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នៅទីផ្សារមូលបត្រ

### ៣.៧.១. ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិម៉េងលី ជេ. គួច អេឌ្យូខេសិន នៅផ.ម.ក.

**តារាងទី ៣.៧៖** តារាងព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិម៉េងលី ជេ. គួច អេឌ្យូខេសិន នៅ ផ.ម.ក.

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនធម្មតា |
| និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ | MJQE |
| ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ២០០ រៀល |
| ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ២.០៨០ រៀល |
| បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែល កំពុងចរាចរណ៍លើទីផ្សារ | ៣២៤.០៥៩.៥២៧ ភាគហ៊ុន |
| មូលធនទូបនីយកម្មទីផ្សារ | ៦៩០.០២៤ លានរៀល |
| ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា |
| កាលបរិច្ឆេទចុះបញ្ជីមូលបត្រ | ២៨ មិថុនា ២០២៣[31] |

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ក្រុមហ៊ុនម៉េលី ជេ. គួច អេឌ្យូខេសិន ម.ក ផ្នែកទី៤៖ ព័ត៌មានអំពី ការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់ MJQE ទំព័រទី២២

[30] https://www.acledasecurities.com.kh/as/khm/info-mjq (ចូលទស្សនាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤)

[31] https://www.mjqeducation.edu.kh/FrontEnd/files/disclosure- (បានចូលទស្សនាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤)

### ៣.៧.២. ការជួញដូរមូលបត្រកម្មសិទ្ធិ ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នៅ ផ.ម.ក. ក្នុងរយៈពេល ១ ខែដំបូង

ក្រោយពីទទួលបានភាពជោគជ័យក្នុងការចុះបញ្ជីជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ក្នុងផ្សារមូលបត្រកម្ពុជាមក យើងសង្កេតឃើញថាភាគហ៊ុនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានការប្រែប្រួលជាញឹកញាប់។ ខាងក្រោមនេះ ជាទិន្នន័យអំពីភាគហ៊ុន ក្នុងរយៈពេល១ខែ ធៀបនឹងតម្លៃជួញដូរសរុបនៅក្នុងទីផ្សារ។[32]

**តារាងទី ៣.៨៖** តារាងការជួញដូរមូលបត្រកម្មសិទ្ធិរបស់ MJQE នៅ ផ.ម.ក. ក្នុងរយៈពេល១ខែដំបូង

**សប្តាហ៍ទី១៖ តម្លៃភាគហ៊ុនរបស់ MJQE ក្នុងសប្តាហ៍ទី១**

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរ (ភាគហ៊ុន) | តម្លៃជួញដូរ (រៀល) | តម្លៃជួញដូរនៅ ផ.ម.ក. សរុប (រៀល) |
|---|---|---|---|---|
| ២៨/០៦/២០២៣ | ២.២០០ | ៤៥៧.៩៥៩ | ៩៩៨.៦៨៨.០៤០ | ៧១២.៩៣១.000.000 |
| ២៩/០៦/២០២៣ | ២.១៣០ | ៥១.៥៣០ | ១១០.០៦០.០២០ | ៦៩០.២៤៧.000.000 |
| ៣០/០៦/២០២៣ | ២.១៣០ | ៧៥.២៦៧ | ១៥៩.៦៨៧.១៣០ | ៦៩០.២៤៧.000.000 |
| ០៣/០៧/២០២៣ | ២.១១០ | ៦៤.៥២៥ | ១៣៥.៧៥៩.២៧០ | ៦៨៣.៧៦៦.000.000 |
| ០៤/០៧/២០២៣ | ២.១០០ | ៥៤.៥៣៣ | ១១៤.៨៨១.៤៧០ | ៦៨០.៥២៥.000.000 |

ប្រភព៖ គេហទំព័រផ្លូវការរបស់CSX

បន្ទាប់ពីប្រកាសលក់ភាគហ៊ុនរបស់ខ្លួន នៅថ្ងៃដំបូងភាគហ៊ុនរបស់ MJQE មានតម្លៃ ២.២០០ រៀលក្នុងមួយភាគហ៊ុន ដែលលើសពីតម្លៃ IPO ២.០៨០ រៀលក្នុងមួយភាគហ៊ុន ជាមួយនឹងទំហំជួញដូរ ៤៥៧.៩៥៩ ភាគហ៊ុននៅលើទីផ្សារ។ ក្នុងនោះតម្លៃជួញដូរសរុបរបស់ក្រុមហ៊ុនមានចំនួន ៩៩៨.៦៨៨.០៤០ រៀល ស្មើនឹងប្រមាណ ០,១៤% នៃតម្លៃជួញដូរសរុបក្នុងទីផ្សារមូលបត្រកម្ពុជា។ នៅថ្ងៃបន្តបន្ទាប់នៃសប្តាហ៍ទី១ តម្លៃភាគហ៊ុនមានការថយចុះ ដែលនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ តម្លៃភាគហ៊ុនធ្លាក់ចុះមកនៅត្រឹម ២.១០០ រៀលក្នុងមួយភាគហ៊ុនវិញ ជាមួយនឹងទំហំជួញដូរ ៥៤.៥៣៣ ភាគហ៊ុននៅលើទីផ្សារ ដែលធ្វើឱ្យតម្លៃជួញដូររបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក មានចំនួនត្រឹមតែ ១១៤.៨៨១.៤៧០ រៀល ដែលមានកម្រិតទាបធៀបទៅនឹងតម្លៃជួញដូរនៅ ផ.ម.ក. សរុប។

[32]https://csx.com.kh/data/stock/daily.do?lang=kh&MNCD=60202&board_type=M&issueCode=KH1000210000&forma=ALL&fromDate=20230628&toDate=20230728# (បានចូលទស្សនានៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤)

**សប្តាហ៍ទី២៖ តម្លៃភាគហ៊ុនរបស់ MJQE ក្នុងសប្តាហ៍ទី២**

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរ (ភាគហ៊ុន) | តម្លៃជួញដូរ (រៀល) | តម្លៃជួញដូរនៅ ផ.ម.ក. សរុប (រៀល) |
|---|---|---|---|---|
| ០៥/០៧/២០២៣ | ២.១២០ | ៣៩.១៩៧ | ៨៣.១៣៣.៨៤០ | ៦៨៧.០០៦.០០០.០០០ |
| ០៦/០៧/២០២៣ | ២.១០០ | ១០០.៤៩៤ | ២១១.៥៩៣.១២០ | ៦៨០.៥២៥.០០០.០០០ |
| ០៧/០៧/២០២៣ | ២.១០០ | ៩៥,៥២៩ | ២០០.៤៣៧.៦១០ | ៦៨០.៥២៥.០០០.០០០ |
| ១០/០៧/២០២៣ | ២.១១០ | ១១៣.០៦៤ | ២៣៧.០៧២.៨៩០ | ៦៨៣.៧៦៦.០០០.០០០ |
| ១១/០៧/២០២៣ | ២.៣២០ | ៣៨១.៣០៣ | ៨៦៧.៤៣៤.០៨០ | ៧៥១.៨១៨.០០០.០០០ |

ប្រភព៖ គេហទំព័រផ្លូវការរបស់CSX

នៅក្នុងសប្តាហ៍ទី២ គិតចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ តម្លៃភាគហ៊ុនមានការប្រែប្រួល ដោយនៅថ្ងៃទី០៥ ខែកក្កដា ភាគហ៊ុនមានតម្លៃ ២.១២០ រៀល និងធ្លាក់ចុះបន្តិចនៅក្នុងកំឡុង២ថ្ងៃបន្ទាប់ រហូតដល់ថ្ងៃទី១១ ខែកក្កដា តម្លៃភាគហ៊ុនបានកើនឡើងដល់ ២.៣២០ រៀល ក្នុងមួយភាគហ៊ុន។ យើងសង្កេតឃើញថា ទំហំជួញដូរមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងសប្តាហ៍ទី២នេះ ទោះបីជាមិនឡើងដល់ចំនួននៃទំហំជួញដូរដូចពេលបោះផ្សាយលក់មូលបត្រលើកដំបូងក៏ដោយ។ យ៉ាងណាមិញ តម្លៃជួញដូររបស់ក្រុមហ៊ុនមានចំនួន ៨៦៧.៤៣៤.០៨០ រៀល ប្រហែលនឹង ០,១២% នៃតម្លៃជួញដូរសរុបនៅក្នុងផ្សារមូលបត្រកម្ពុជា ដែលមានចំនួន ៧៥១.៨១៨.០០០.០០០ រៀល នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

**សប្តាហ៍ទី៣៖ តម្លៃភាគហ៊ុនរបស់ MJQE ក្នុងសប្តាហ៍ទី៣**

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរ (ភាគហ៊ុន) | តម្លៃជួញដូរ (រៀល) | តម្លៃជួញដូរនៅ ផ.ម.ក. សរុប (រៀល) |
|---|---|---|---|---|
| ១២/០៧/២០២៣ | ២.៣៤០ | ៨០៣.៣៦១ | ១.៩៨៤.៤៣៩.១១០ | ៧៥៨.២៩៩.០០០.០០០ |
| ១៣/០៧/២០២៣ | ២.៣៤០ | ១០៦.១៦៥ | ២៤៩.៦៥១.៦៨០ | ៧៥៨.២៩៩.០០០.០០០ |
| ១៤/០៧/២០២៣ | ២.៣៣០ | ៣៧.០៨១ | ៨៦.៤៣៩.៧៦០ | ៧៥៥.០៥៩.០០០.០០០ |
| ១៧/០៧/២០២៣ | ២.២៩០ | ៥៧.១៦៦ | ១៣១.៩៧១.៩២០ | ៧៤២.០៩៦.០០០.០០០ |
| ១៨/០៧/២០២៣ | ២.២៦០ | ៤៩.៩៩៨ | ១១៣.១៨២.៨៤០ | ៧៣២.៣៧៥.០០០.០០០ |

ប្រភព៖ គេហទំព័រផ្លូវការរបស់CSX

យើងសង្កេតឃើញថា នៅក្នុងសប្តាហ៍ទី៣ ថ្ងៃទី១២-១៣ ខែកក្កដា តម្លៃភាគហ៊ុនរបស់ MJQE បានកើនឡើងរហូតដល់ ២.៣៤០ រៀលក្នុងមួយភាគហ៊ុន ដែលជាតម្លៃអតិបរមារបស់ភាគហ៊ុនក្រុមហ៊ុន នៅក្នុងកំឡុងរយៈពេល១ខែដំបូង និងធ្លាក់ចុះនៅថ្ងៃបន្តបន្ទាប់រហូតដល់ភាគហ៊ុនមានតម្លៃ ២.២៦០ រៀលវិញនៅថ្ងៃទី១៨ ខែកក្កដា។ តែទោះជាយ៉ាងណាវានៅតែជាសញ្ញាណល្អ ព្រោះតម្លៃភាគហ៊ុនអមានៅសប្តាហ៍ទី៣ មានទំហំធំជាងចំនួន ១៦០រៀល បើធៀបនឹងតម្លៃភាគហ៊ុនអប្បបរមានៅសប្តាហ៍ទី២។ គួរបញ្ជាក់ផងដែរថា នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ ទំហំជួញដូរមានការកើនឡើងរហូតទៅដល់៨០៣.៣៦១ ភាគហ៊ុនដែលជាចំនួនច្រើនបំផុតមិនធ្លាប់មានពីមុនមក។ បន្ថែមពីនេះទំហំជួញដូរមានការថយចុះនៅថ្ងៃបន្តបន្ទាប់ ដែលទំហំជួញដូរនៅចុងសប្តាហ៍ទី៣ មានចំនួន ៤៩.៩៩៨ ភាគហ៊ុននៅលើទីផ្សារ ក្នុងតម្លៃជួញដូរសរុបចំនួន ១១៣.១៨២.៨៨០រៀល។

**សប្តាហ៍ទី៤៖ តម្លៃភាគហ៊ុនរបស់ MJQE ក្នុងសប្តាហ៍ទី៤**

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរ (ភាគហ៊ុន) | តម្លៃជួញដូរ (រៀល) | តម្លៃជួញដូរនៅ ផ.ម.ក. សរុប (រៀល) |
|---|---|---|---|---|
| ១៩/០៧/២០២៣ | ២.២៤០ | ១០៥.៧១១ | ២៣២.៧៨៦.៨៣០ | ៧២៥.៨៩៣.០០០.០០០ |
| ២០/០៧/២០២៣ | ២.២៥០ | ៦២.០២២ | ១៣៨.២៤៤.៩២០ | ៧២៩.១៣៤.០០០.០០០ |
| ២១/០៧/២០២៣ | ២.២៧០ | ៣១.១២១ | ៧០.៦៥៩.០២០ | ៧៣៥.៦១៥.០០០.០០០ |
| ២៥/០៧/២០២៣ | ២.២៥០ | ១៦.៦៧២ | ៣៧.៦៣២.២០០ | ៧២៩.១៣៤.០០០.០០០ |
| ២៦/០៧/២០២៣ | ២.២៣០ | ៣៨.១០០ | ៨៥.០៣០.២៨០ | ៧២២.៦៥៣.០០០.០០០ |

ប្រភព៖ គេហទំព័រផ្លូវការរបស់CSX

នៅសប្តាហ៍ទី៤ នេះឃើញថា តម្លៃនៃភាគហ៊ុនរបស់ក្រុមហ៊ុនមិនមានការប្រែប្រួលខ្លាំងនោះទេ។ ជាក់ស្តែង តម្លៃភាគហ៊ុនមានការកើនឡើងរហូតដល់ ២.២៧០ រៀលក្នុងមួយភាគហ៊ុន នៅពាក់កណ្តាលសប្តាហ៍ និងធ្លាក់ចុះមកនៅត្រឹម ២.២៣០រៀលវិញនៅចុងសប្តាហ៍ទី៤។ បើយើងក្រឡេកទៅមើលទំហំជួញដូរវិញ ជារួមឃើញថា ទំហំជួញដូរមានការថយចុះមកត្រឹមតែ ៣៨.១០០ភាគហ៊ុន ក្នុងតម្លៃជួញដូរ ៨៥.០៣០.២៨០រៀល ដែលជាកម្រិតទាបបើធៀបទៅនឹងតម្លៃជួញដូរនៅ ផ.ម.ក. សរុបចំនួន ៧២២.៦៥៣.០០០.០០០រៀល នៅចុងសប្តាហ៍ទី៤នេះ។

**ក្រាបទី ៣.១៖** ក្រាបបង្ហាញពីការប្រែប្រួលតម្លៃភាគហ៊ុន MJQE ក្នុង១ខែដំបូង



ប្រភព៖ https://pplinksecurities.com.kh/securities-broker/daily-price-csx-index/mjqe/ (ចូលទស្សនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤)

យោងតាមក្រាហ្វិកខាងលើ យើងអាចសង្កេតឃើញថា តម្លៃភាគហ៊ុនរបស់ក្រុមហ៊ុនមានការប្រែប្រួលកើនឡើងដល់តម្លៃអតិបរមាគឺតម្លៃ ២.៣៤០រៀល ក្នុងមួយភាគហ៊ុន នៅថ្ងៃទី១២ និងទី១៣ ខែកក្កដា។ ក្រោយមក តម្លៃភាគហ៊ុនមានការថយចុះមកវិញក្នុងចន្លោះតម្លៃ ២.២៥០ រៀល ក្នុងមួយភាគហ៊ុន និងខ្ពស់ជាងតម្លៃបោះផ្សាយដំបូងបន្តិច។

**ក្រាបទី ៣.២៖** ក្រាបបង្ហាញពីការប្រែប្រួលទំហំជួញដូររបស់ភាគហ៊ុន MJQE ក្នុង១ខែដំបូង




ប្រភព៖

https://csx.com.kh/data/stock/daily.do?lang=kh&MNCD=60202&board_type=M&issueCode=KH1000210000&forma=ALL&fromDate=20230628&toDate=20230728# (បានចូលទស្សនានៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤)

យោងតាមក្រាហ្វិកខាងលើ យើងអាចសង្កេតឃើញថា ទំហំជួញដូររបស់ក្រុមហ៊ុនមានការប្រែប្រួលកើនឡើងដល់ចំនួនអតិបរមាគឺ ៨០៣.៣៦១ភាគហ៊ុន នៅដើមសប្តាហ៍ទី៣ គឺថ្ងៃទី១២ ខែកក្កដា ក្នុងតម្លៃជួញដូរ ១.៩៨៤.៤៣៩.១១០រៀល។ យ៉ាងណាមិញ ទំហំជួញដូរមានការថយចុះជាបន្តបន្ទាប់រហូតដល់ចុងសប្តាហ៍ទី៤ ទំហំជួញដូរមានត្រឹម ៣៨.១០០ភាគហ៊ុន ក្នុងតម្លៃជួញដូរ ៨៥.០៣០.២៨០រៀលប៉ុណ្ណោះ។

### ៣.៧.៣. ការជួញដូរមូលបត្រកម្មសិទ្ធិ ម៉េខលី ជេ. គួច អេឌ្យូខេសិន ម.ក នៅ ផ.ម.ក. ក្នុងរយៈពេល ៦ ខែដំបូង

**តារាងទី ៣.៩៖** តារាងការជួញដូរមូលបត្រកម្មសិទ្ធិរបស់ MJQE នៅ ផ.ម.ក. ក្នុងរយៈពេល៦ខែដំបូង

| មូលបត្រកម្មសិទ្ធិ | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|
| ថ្លៃភាគហ៊ុន (រៀល) | អតិបរមា | ២.៥៥០ | ២.២៥០ | ២.១៦០ | ២.១៤០ | ២.១២០ | ២.១៣០ |
| | អប្បបរមា | ២.០៨០ | ២.២១០ | ២.០៨០ | ២.០៦០ | ២.០៦០ | ២.០៨០ |
| | មធ្យម | ២.២១៨ | ២.១៨៤ | ២.១១១ | ២.០៩៨ | ២.០៩៤ | ២.០៩៧ |
| បរិមាណជួញដូរ | អតិបរមា | ៨០៣.៣៦១ | ៥៨.៣៧៩ | ២៤.៧៥៧ | ៣០.២៩៥ | ២៨.៨៣៨ | ៤៧.៣៨៣ |
| | អប្បបរមា | ៨.៣២៩ | ៣.៣៣១ | ១.០៨២ | ៤៧១ | ១.៤៩៣ | ២.៧៧៥ |
| | មធ្យម | ១០៩.៤៣១ | ២២.៣០៥ | ៨.១២៤ | ១១.០២៤ | ១០.៣១៣ | ១៤.៣៨២ |

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ក្រុមហ៊ុនម៉េលី ជេ. គួច អេឌ្យូខេសិន ម.ក ផ្នែកទី៤៖ ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់ MJQE ទំព័រទី២៣

យោងតាមតារាងខាងលើ យើងសង្កេតឃើញថា នៅក្នុងខែដំបូងនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនម៉េងលី ជេ. គួចអេឌ្យូខេសិន ម.ក បានទទួលសន្ទុះគាំទ្រយ៉ាងពេញទំហឹងពីសំណាក់វិនិយោគិនគ្រប់មជ្ឈដ្ឋាន  ដោយបរិមាណជួញដូរអតិបរមាមានចំនួនរហូតទៅដល់ ៨០៣.៣៦១ ហ៊ុនដែលជាចំនួនដ៏ច្រើនបំផុតក្នុងរយៈពេល៦ខែដំបូង ហើយតម្លៃភាគហ៊ុនអតិបរមាកើនឡើងដល់ ២.៥៥០ រៀលក្នុងមួយហ៊ុនដែលជាតម្លៃខ្ពស់បំផុត បើធៀនឹងតម្លៃភាគហ៊ុនអតិបរមាក្នុងរយៈពេល៦ខែដំបូង។ ថ្វីត្បិតតែខែបន្តបន្ទាប់ តម្លៃភាគហ៊ុន និងការលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនមានការថយចុះក៏ពិតមែន តែវានៅតែជះសញ្ញាណវិជ្ជមានទៅដល់ដំណើរការបោះផ្សាយទាំងមូល ពោលគឺនៅក្នុងខែធ្នូ តម្លៃអតិបរមារបស់ភាគហ៊ុនមានចំនួន ២.១៣០ រៀលក្នុងមួយហ៊ុនដែលតម្លៃនេះបានកើនឡើងចំនួន ១០រៀលក្នុងមួយហ៊ុន បើធៀបនឹងតម្លៃអតិបរមារបស់ភាគហ៊ុនក្នុងខែវិច្ឆិកា។ម្យ៉ាងវិញទៀត បរិមាណនៃការជួញដូរក៏មានភាពប្រសើរឡើងផងដែល ដោយនៅខែធ្នូ បរិមាណជួញដូរអប្បបរមាមាន ចំនួន ២.៧៨៥ ហ៊ុន បើធៀបទៅនឹងបរិមាណជួញដូរអប្បបរមានៅក្នុងខែវិច្ឆិកា ដែលមានចំនួនត្រឹមតែ ១.៤៩៣ ប៉ុណ្ណោះ។

## ៣.៨. ទំនាក់ទំនងវិនិយោគិន

### ៣.៨.១. យន្តការ និងនីតិវិធីសម្រាប់ទំនាក់ទំនងជាមួយវិនិយោគិន

ក្រុមហ៊ុនទទួលស្គាល់អំពីសារៈសំខាន់នៃការរក្សាទំនាក់ទំនងជាមួយភាគហ៊ុនិក និងវិនិយោគិនរបស់ក្រុមហ៊ុនតាមរយៈបណ្តាញផ្សេងៗដូចជា ការបង្ហាញព័ត៌មានតាមគ្រា ដែលរួមបញ្ចូលរបាយការណ៍ប្រចាំឆ្នាំ និងប្រចាំត្រីមាស និងការបង្ហាញព័ត៌មានទាន់ពេលវេលា រួមទាំងសេចក្តីប្រកាសព័ត៌មាន និងការផ្សព្វផ្សាយផង

ដែរ។ ទាំងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់ក្រុមហ៊ុនត្រូវបានបង្ហាញយ៉ាងទូលំទូលាយអំពីព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងសកម្មភាពរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនលើកទឹកចិត្តឱ្យមានការសាកសួរអំពីសកម្មភាពរបស់ក្រុមហ៊ុន និងធានាឱ្យមានការដោះស្រាយភ្លាមៗនូវចម្ងល់ទាំងឡាយ។

### ៣.៨.២. ទំនាក់ទំនងជាមួយវិនិយោគិនក្នុង១ឆ្នាំចុងក្រោយ

ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក បានប្រើប្រាស់បណ្តាញដ៏ធំទូលាយមួយសម្រាប់ការទំនាក់ទំនងទាំងជាមួយអតិថិជន និងវិនិយោគិន។ បណ្តាញនេះរាប់បញ្ចូលទាំងគេហទំព័រដើម ទំនាក់ទំនងតាមសារអេឡិចត្រូនិក ការហៅតាមទូរសព្ទ ការប្រជុំដោយផ្ទាល់ និងការអញ្ជើញភាគហ៊ុនិកចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។ ដោយនៅក្នុងឆ្នាំ២០២៣ ក្រុមហ៊ុនត្រូវបានធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងរបស់យើងនៅលើ ផ.ម.ក. ដូច្នេះដំណើរការទាំងអស់ដើម្បីលើកកម្ពស់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពដល់វិនិយោគិនរបស់ក្រុមហ៊ុនត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ។

# សេចក្ដីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងបកស្រាយទៅលើប្រធានបទ "ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក" យ៉ាងក្បោះក្បាយរួចមក អាចឱ្យយើងមើលឃើញថា ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ក៏ដូចជាក្រុមហ៊ុនដទៃទៀតដែរ គឺធ្វើឡើងបានដោយឆ្លងកាត់ជាច្រើនដំណាក់កាលចំណាយទាំងពេលវេលា ថវិកា និងការរៀបចំជាច្រើនដើម្បីទទួលបានជោគជ័យ។ ដើម្បីអាចបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងបានក្រុមហ៊ុនត្រូវឆ្លងកាត់នូវនីតិវិធីច្រើន ប៉ុន្តែក្រុមហ៊ុននេះបានបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលក្នុងនោះមានដូចជា ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនមេធាវី ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម និងក្រុមហ៊ុនវាយតម្លៃជាដើម ដែលសមាជិកក្រុមការងារនេះគឺសុទ្ធតែជាអ្នកដែលមានជំនាញច្បាស់លាស់ អាចជួយសម្របសម្រួលនៅក្នុងដំណើរការបោះផ្សាយនេះបាន។ ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ត្រូវទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា ជាច្រើនដំណាក់កាលស្របទៅតាមយន្តការ និងនីតិវិធី ដែលបានចែងជាធរមាន។ ស្របពេលជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយនឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើន ដូចជាទទួលបានដើមទុនបន្ថែមសម្រាប់ពង្រីកអាជីវកម្ម ឬសម្រាប់ប្រតិបត្តិការអាជីវកម្ម ជួយបង្កើនតម្លាភាព និងសុក្រឹតភាពនៃឯកសារគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក៏ដូចជា ជួយឱ្យក្រុមហ៊ុនមានអភិបាលកិច្ចសាជីវកម្មល្អប្រសើរ ព្រមទាំងបង្កើនកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន និងទទួលបាននូវទំនុកចិត្តកាន់តែច្រើនពីសាធារណជនថែមទៀតផង។

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ យើងខ្ញុំទាំងពីរពិតជាទទួលបាននូវការស្វែងយល់ជាច្រើន បន្ថែមទៅលើទ្រឹស្ដីដែលបានសិក្សាកន្លងមក។ យើងបានស្វែងយល់យ៉ាងលម្អិតទៅលើវិស័យអប់រំរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ដោយបានស្គាល់ពីប្រវត្តិរបស់ក្រុមហ៊ុន ប្រវត្តិប្រតិបត្តិការរបស់ក្រុមហ៊ុន ចក្ខុវិស័យ បេសកកម្ម គុណតម្លៃ រួមជាមួយនឹងផលិតផល សេវាកម្ម គោលបំណងចម្បង រចនាសម្ព័ន្ធ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលអាចដឹកនាំក្រុមហ៊ុនមួយនេះអាចចូលទៅក្នុងទីផ្សារមូលបត្របាន។ បន្ថែមពីនេះ យើងបានស្វែងយល់កាន់តែច្បាស់ ពីដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន និងភាពជាផ្នែកមួយនៃការរីកចម្រើននៃវិស័យមូលបត្រ ដោយក្រុមហ៊ុននេះបានបង្កើនជម្រើសទៅដល់វិនិយោគិន ក្នុងការវិនិយោគទៅលើទីផ្សារមួយនេះ។

ជាចុងក្រោយ យើងអាចសន្និដ្ឋានបានថា ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក គឺជាក្រុមហ៊ុនមួយប្រកបដោយសក្តានុពល ដែលរួមចំណែកក្នុងការអភិវឌ្ឍវិស័យមូលបត្រកម្ពុជា ជាពិសេសវិស័យអប់រំឱ្យរីកចម្រើនទៅមុខ។ ក្រុមហ៊ុននេះបានចូលរួមនៅក្នុងទីផ្សារមូលបត្រ ក្នុងនាមជាក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ ដើម្បីគៀងគងមូលធនបន្ថែមទៀត ក្នុងការអភិវឌ្ឍនូវគម្រោងរបស់ខ្លួនដែលបានគ្រោងទុក និងពង្រីកកេរ្តិ៍ឈ្មោះឱ្យបានកាន់តែល្បីល្បាយថែមទៀត។

## ២. អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន ម៉េងលី ជេ គួច អេឌ្យូខេសិន ម.ក រួចមក យើងខ្ញុំទាំងពីរយល់ឃើញថាក្រុមហ៊ុនទទួលបាននូវភាពជោគជ័យស្របតាមការរំពឹងទុករបស់ខ្លួន ប៉ុន្តែទន្ទឹមនឹងនេះ យើងខ្ញុំសូមចូលរួមជាមតិយោបល់មួយចំនួនក្នុងការកែលំអ ដើម្បីឱ្យការបោះផ្សាយលក់របស់ក្រុមហ៊ុនកាន់តែមានប្រជាប្រិយភាព និងទទួលបានការគាំទ្រជាងនេះទៅទៀត។ យើងខ្ញុំទាំងពីរសូមអនុញ្ញាតិផ្តល់ជាគំនិត និងមតិយោបល់ដូចខាងក្រោមៈ

- ផ្សព្វផ្សាយនូវគុណភាពនៃកម្មវិធីសិក្សាយ៉ាងសម្បូរបែបរបស់ខ្លួនទៅដល់សាធារណៈជនទូទៅ ដើម្បីទាក់ទាញអតិថិជនគោលដៅដែលជាកត្តាមួយយ៉ាងសំខាន់ក្នុងការបង្កើនប្រាក់ចំណេញដល់ក្រុមហ៊ុន
- ក្រុមហ៊ុនគួរគប្បីបន្តប្រកាន់ខ្ជាប់នូវគោលជំហរក្នុងការផ្តល់នូវព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយសុក្រឹត្យភាព និងតម្លាភាពឱ្យបានទៀងទាត់ បង្កើនទំនុកចិត្តដល់វិនិយោគិនក្នុងការវិនិយោគលើមូលបត្ររបស់ក្រុមហ៊ុន
- ក្រុមហ៊ុនគួរបង្កើនសក្តានុពលក្នុងការផ្សព្វផ្សាយព័ត៌មានអំពីមូលបត្រកម្មសិទ្ធិរបស់ខ្លួនឱ្យបានកាន់តែទូលំទូលាយជូនដល់សាធារណៈជន ដើម្បីផ្តល់ជាភាពងាយស្រួលដល់វិនិយាគិនធ្វើកាស្វែងយល់ និងជាមូលដ្ឋានគ្រឹះក្នុងការសម្រេចចិត្តធ្វើការវិនិយោគទៅលើមូលបត្ររបស់ក្រុមហ៊ុន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ ប្រកាស និងសេចក្តីណែនាំ

- ប្រកាស លេខ ០០៥/១៥ គ.ម.ក./ប្រ.ក ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥
- គោលការណ៍ណែនាំ លេខ០០១ គ.ម.ក./គ.ណ.ន ស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូង ចុះថ្ងៃទី ០៨ ខែកញ្ញា ២០១១

## សៀវភៅ

- ហេង ច័ន្ទបូលីន ៖ ទីផ្សារមូលបត្រកម្ពុជា (២០២៣-២០២៤) សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## គេហទំព័រ

- ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ MJQE https://www.mjqeducation.edu.kh/FrontEnd/files/disclosure-document/Final-DD-of-MJQE-KH-Version.pdf
- របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ក្រុមហ៊ុនម៉េលី ជេ. គួច អេឌ្យូខេសិន ម.ក https://mjqeducation.edu.kh/storage/files/MJQE_Annual%20Report%202023_KH.pdf
- ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ https://www.acledasecurities.com.kh/as/assets/pdf_zip/My%20Learnings%20-%20Others%20-
- ទិន្នន័យអំពីទីផ្សារមូលបត្រ https://csx.com.kh/news/faq/listPosts.do?lang=kh&MNCD=7060&postId=6#sec1_1
- ទិន្នន័យអំពីប្រភេទមូលបត្រ https://whjww.linkedin.com/pulse/%E1%9Ekk%98%E1%9E%9B%E1%9E%94%E1%9E%8F%E1%9E%9Asecurities-sok-sotheara
- ទិន្នន័យអំពីមូលបត្រកម្មសិទ្ធិ https://www.facebook.com/100038469349584/posts/161192842325308/

- ទិន្នន័យអំពីមូលបត្របំណុល

  https://www.vietnam.vn/km/trai-phieu-la-gi-va-nhung-dieu-can-biet
- ទិន្នន័យអំពីទីផ្សារដំបូង

  https://bizkhmer.com/articles/58832
- ទិន្នន័យអំពីក្រុមហ៊ុនមូលបត្រ

  https://www.serc.gov.kh/khmer/m52.php?pn=6
- ទិន្នន័យអំពីក្រុមហ៊ុនធានាទិញមូលបត្រ

  https://bizkhmer.com/articles/59658
- ទិន្នន័យអំពីក្រុមហ៊ុនបោះផ្សាយមូលបត្រ

  https://csx.com.kh/data/lstcom/listPosts.do?MNCD=5010
- ទិន្នន័យអំពីក្រុមហ៊ុនផ្តល់សេវាសវនកម្ម ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធមូលបត្រ ភ្នាក់ងារបញ្ជីកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

  https://www.serc.gov.kh/khmer/m53.php?pn6
- ទិន្នន័យអំពីភ្នាក់ងារតំណាងម្ចាស់បំណុល

  https://www.serc.gov.kh/khmer/m53.php?pn=
- ទិន្នន័យអំពីលក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

  https://csx.com.kh/kh/product/growthboard.jsp?MNCD=30103
- ទិន្នន័យអំពីលក្ខខណ្ឌតម្រូវដើម្បីចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ

  https://csx.com.kh/
- ទិន្នន័យអំពីដំណើរការបរិវិសកម្ម

  https://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=97

  https://www.acledasecurities.com.kh/as/khm/info-mjq
- ទិន្នន័យអំពីការជួញដូរមូលបត្រកម្មសិទ្ធិ ម៉េងលី ជេ. គួច អេឌ្យូខេសិន នៅ ផ.ម.ក. ក្នុងរយៈពេល១ខែដំបូង

  https://csx.com.kh/data/stock/daily.do?lang=kh&MNCD=60202&board_type=M&issueCode=KH1000210000&forma=ALL&fromDate=20230628&toDate=20230728#
- ទិន្នន័យអំពីក្រាបបង្ហាញពីការប្រែប្រួលតម្លៃភាគហ៊ុន MJQE ក្នុង១ខែដំបូង

  https://pplinksecurities.com.kh/securities-broker/daily-price-csx-index/mjqe/

- ទិន្នន័យអំពីក្រាបបង្ហាញពីការប្រែប្រួលទំហំជួញដូររបស់ភាគហ៊ុន MJQE ក្នុង១ខែដំបូង
  https://csx.com.kh/data/stock/daily.do?lang=kh&MNCD=60202&board_type=M&issueCode=KH1000210000&forma=ALL&fromDate=20230628&toDate=20230728#
- ទិន្នន័យអំពីកូរ៉ុម
  https://km.m.wikipedia.org/wiki/%E1%9E%80%E1%9E%BC%E1%9E%9A%E1%9F%89%E1%9E%BB%E1%9E%98

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង របស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ឧបសម្ព័ន្ធទី២៖ គោលការណ៍ណែនាំស្តីពីការកំណត់ថ្លៃលក់មូលបត្រ និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

ឧបសម្ព័ន្ធទី៣៖ គំរូនៃសេចក្តីជូនដំណឹងពីការបែងចែកភាគលាភប្រចាំឆ្នាំរបស់ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ឧបសម្ព័ន្ធទី៤៖ របាយការណ៍ប្រចាំឆ្នាំ២០២៣របស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ឧបសម្ព័ន្ធទី៥៖ ពាក្យស្នើសុំធ្វើបរិវិសកម្ម

# ឧបសម្ព័ន្ធទី១
# ឯកសារផ្តល់ព័ត៌មានសម្រាប់ការ
# បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជា
# សាធារណៈលើកដំបូងរបស់ក្រុមហ៊ុន
# ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

# ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈលើកដំបូង

MENGLY J. QUACH EDUCATION

## ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

(លេខចុះបញ្ជីរបស់ក្រុមហ៊ុន÷ 00003787)

(បង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជាក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម)

សំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនូវ 19,606,600 ភាគហ៊ុនធម្មតារបស់ ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ជាមួយនឹងការចុះបញ្ជីលក់មូលបត្ររបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក លើទីផ្សារគោលនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយរួមមាន÷

1. ការបោះផ្សាយលក់ជាសាធារណៈនូវភាគហ៊ុនធម្មតាថ្មីចំនួន 13,600,000 ភាគហ៊ុន និង
2. ការបោះផ្សាយលក់នូវភាគហ៊ុនដែលមានស្រាប់ចំនួន 6,006,600 ភាគហ៊ុន

នៅក្នុងថ្លៃលក់ 2,080 រៀល (0.51 ដុល្លារ) ក្នុងមួយភាគហ៊ុន ដោយត្រូវបង់ថ្លៃពេញលេញនៅពេលដាក់ពាក្យស្នើសុំ។

**ទីប្រឹក្សាហិរញ្ញវត្ថុចម្បង និងក្រុមហ៊ុនធានាទិញមូលបត្រ**

RHB

**អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក**

**វិនិយោគិនត្រូវបានណែនាំឱ្យអាន និងយល់ពីខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាននេះ។ ក្នុងករណីមានចម្ងល់ សូមប្រឹក្សាយោបល់ជាមួយអ្នកប្រឹក្សាវិជ្ជាជីវៈ។**

**សម្រាប់ព័ត៌មានដែលពាក់ព័ន្ធនឹងកត្តាហានិភ័យដែលវិនិយោគិនត្រូវពិចារណា សូមមើលកត្តាហានិភ័យដែលមាននៅក្នុងផ្នែកទី3 នៃឯកសារផ្តល់ព័ត៌មាននេះ។**

*"ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ ត្រូវទទួលខុសត្រូវចំពោះព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាននេះ"*

**ក្រុមហ៊ុន** ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

| | | |
|---|---|---|
| **តំណាងក្រុមហ៊ុនបោះផ្សាយ** | ÷ | អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី |
| **អាសយដ្ឋាន** | ÷ | អគារលេខ 11A ផ្លូវ402 សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| **គេហទំព័រ** | ÷ | www.mjqeducation.edu.kh |
| **អ៊ីម៉ែល** | ÷ | info@mjqeducation.edu.kh |
| **ទូរស័ព្ទលេខ** | ÷ | +855 23 223 295 |
| **ទូរសារលេខ** | ÷ | +855 23 999 930 |
| **លេខចុះបញ្ជីពាណិជ្ជកម្ម** | ÷ | 00004787 **កាលបរិច្ឆេទ** ÷ 05 កញ្ញា 2012 |

**ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ**

| | | |
|---|---|---|
| **វិញ្ញាបនបត្រចុះបញ្ជីលេខ** | ÷ | ...................................... |
| **កាលបរិច្ឆេទចេញដោយ ន.ម.ក.** | ÷ | ...................................... |

## ទីប្រឹក្សាហិរញ្ញវត្ថុចម្បង និងក្រុមហ៊ុនធានាទិញមូលបត្រ
## អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក

ឯកសារផ្តល់ព័ត៌មាននេះ និងឯកសារបន្ថែមណាមួយអាចទទួលបាននៅ÷

- ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ÷អគារលេខ 11A ផ្លូវ402 សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក ÷ ជាន់ M អគារ OHK កែងផ្លូវលេខ 110 និង 93 ភូមិ 3 សង្កាត់ស្រះចក ខណ្ឌ ដូនពេញ រាជធានី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ ÷ 02 មីនា 2023....................

បុគ្គលដែលទទួលបន្ទុកផ្តល់ព័ត៌មាន÷

ឈ្មោះ ÷ អ៊ីវ រ៉ាណារិទ្ធ   តួនាទី ÷ នាយកប្រតិបត្តិ នៃ អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក

ទូរស័ព្ទលេខ ÷ +855 23 969 161   អ៊ីម៉ែល ÷ ranarith.iv@rhbgroup.com.kh

## កំណត់សម្គាល់ចំពោះវិនិយោគិន

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន **ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក** បានអនុម័ត ឯកសារផ្តល់ព័ត៌មាននេះសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ)។ ក្រុមប្រឹក្សាភិបាលរួមគ្នា និងដាច់ដោយឡែកពីគ្នា ទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវនៃព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាននេះ។ ដោយផ្អែកលើភាពសមហេតុសមផល និងចំណេះដឹង និងជំនឿ ក្រុមប្រឹក្សាភិបាល ធានាថា មិនមានសេចក្តីថ្លែងក្លែងក្លាយ ឬព័ត៌មានដែលនាំឱ្យយល់ខុស ឬបំភ្លើស ដែលអាចឱ្យសេចក្តីថ្លែងនានានៅក្នុងឯកសារផ្តល់ព័ត៌មាននេះមិនពិត ឬមានអត្ថន័យភ័ន្តច្រឡំឡើយ។

**ន.ម.ក.** បានអនុម័តលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុនយើង ហើយ ឯកសារផ្តល់ព័ត៌មានជាភាសាខ្មែរត្រូវបានចុះបញ្ជី និងតម្កល់ទុកនៅ **ន.ម.ក.** ផងដែរ។ ឯកសារផ្តល់ព័ត៌មានជាភាសាខ្មែរដែលទទួលបានការអនុម័ត និងចុះបញ្ជីនេះ មិនមែនជាការបញ្ជាក់ថា **ន.ម.ក.** ផ្តល់អនុសាសន៍ឱ្យធ្វើបរិវិសកម្មមូលបត្រដែលបោះផ្សាយនេះ ឬសន្មតពីការទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃព័ត៌មាន ទស្សនៈ ឬសេចក្តីថ្លែងដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាននេះទេ។

**ន.ម.ក.** មិនទទួលខុសត្រូវចំពោះការមិនបង្ហាញនូវព័ត៌មានណាមួយ និងខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាននេះ និងមិនបញ្ជាក់ពីភាពត្រឹមត្រូវ ឬភាពពេញលេញនោះទេ។ **ន.ម.ក.** មិនទទួលខុសត្រូវចំពោះការខាតបង់ណាមួយដែលវិនិយោគិនអាចទទួលរងពីខ្លឹមសារទាំងស្រុង ឬមួយផ្នែកនៃឯកសារផ្តល់ព័ត៌មាននេះទេ។

វិនិយោគិនត្រូវពឹងផ្អែកលើការវាយតម្លៃផ្ទាល់ខ្លួនដើម្បីទទួលបាននូវភាពត្រឹមត្រូវ និងហានិភ័យដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយពិចារណាលើកម្មវត្ថុនៃការវិនិយោគ ហានិភ័យ ស្ថានភាពហិរញ្ញវត្ថុផ្ទាល់ខ្លួន ។ល។ ប្រសិនបើវិនិយោគិនមានមន្ទិលសង្ស័យអំពីឯកសារផ្តល់ព័ត៌មាននេះ ឬអំពីការវិនិយោគ វិនិយោគិនគួរតែស្វែងរកការប្រឹក្សាយោបល់ពីក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនប្រឹក្សាវិនិយោគ ឬទីប្រឹក្សាវិជ្ជាជីវៈផ្សេងៗទៀត។

រាជធានីភ្នំពេញ ថ្ងៃទី 02 ខែមិនា ឆ្នាំ 2023

ហត្ថលេខា និងឈ្មោះប្រធានក្រុមប្រឹក្សាភិបាល

MENGLY J. QUACH EDUCATION PLC.
KINGDOM OF CAMBODIA

អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី

ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និង អគ្គនាយកប្រតិបត្តិ

## គម្រោងពេលវេលារំពឹងទុកសម្រាប់ការបោះផ្សាយលក់មូលបត្រជាសាធារណៈ:

ព្រឹត្តិការណ៍ដែលគ្រោងនឹងកើតឡើងជាមួយនឹងកាលបរិច្ឆេទរំពឹងទុកដូចខាងក្រោម÷

| **ព្រឹត្តិការណ៍** | **កាលបរិច្ឆេទ និងពេលវេលារំពឹងទុក** |
|---|---|
| ការចាប់ផ្ដើមការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម | ម៉ោង 8:00 នាទីព្រឹក ថ្ងៃទី 10 ខែមេសា ឆ្នាំ2023 |
| ការបញ្ចប់ការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម | ម៉ោង 4:30 នាទីរសៀល ថ្ងៃទី 09 ខែមិថុនា ឆ្នាំ2023 |
| ការបញ្ជូនសេចក្ដីជូនដំណឹងដល់វិនិយោគិនដែលជោគជ័យ | ថ្ងៃទី 19 ខែមិថុនា ឆ្នាំ2023 |
| ការបែងចែកមូលបត្រកម្មសិទ្ធិសម្រាប់វិនិយោគិនដែលជោគជ័យ | ថ្ងៃទី 23 ខែមិថុនា ឆ្នាំ2023 |
| កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រ | ថ្ងៃទី 28 ខែមិថុនា ឆ្នាំ2023 |

**កំណត់សម្គាល់÷**

ម៉ោងធ្វើការ គឺ 8:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ និងម៉ោង 1:00 រសៀល ដល់ម៉ោង 4: 00 រសៀល នៅថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាតិនៅព្រះរាជាណាចក្រកម្ពុជា។

គម្រោងពេលនេះគឺជាការរំពឹងទុក និងជាកម្មវត្ថុនៃការកែប្រែចាំបាច់ដើម្បីសម្រួលដល់ការអនុវត្តនីតិវិធី។ ការធ្វើបរិវិសកម្មនៅតែបើករហូតដល់ម៉ោង 4:30 រសៀល ថ្ងៃទី 09 ខែមិថុនា ឆ្នាំ2023។

នៅពេលបិទកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវបានពន្យារពេល និងការជូនដំណឹងត្រូវបានធ្វើឡើង កាលបរិច្ឆេទនៃការបែងចែកមូលបត្រកម្មសិទ្ធិ និងកាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រនឹងត្រូវបានពន្យារពេលដូចគ្នាផងដែរ។ ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក នឹងជូនដំណឹងជាសាធារណៈតាមរយៈកាសែតដែលទទួលស្គាល់ដោយ ន.ម.ក. ជាភាសាខ្មែរ និងអង់គ្លេស។

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

| ល.រ. | ឈ្មោះ | ចំនួនភាគហ៊ុន | ភាគរយ |
|---|---|---|---|
| 1 | អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | 70,070,000 | 70 |
| 2 | លោក គួច អាឡិច | 15,015,000 | 15 |
| 3 | លោក គួច ផល | 15,015,000 | 15 |
| | **សរុប** | **100,100,000** | **100** |

### 1.3.2. អភិបាល

| ល.រ. | ឈ្មោះ | មុខតំណែង |
|---|---|---|
| 1 | អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ |
| 2 | លោក គួច អាឡិច | អភិបាលប្រតិបត្តិ និងទីប្រឹក្សាជាន់ខ្ពស់ |
| 3 | លោក គួច ផល | អភិបាលប្រតិបត្តិ និងទីប្រឹក្សាជាន់ខ្ពស់ |
| 4 | លោកជំទាវ អ៊ឹង លីហុង | អភិបាលប្រតិបត្តិ |
| 5 | លោក គង់ វ៉ាវ៉ា | អភិបាលឯករាជ្យ |

### 1.3.3. បុគ្គលិកជាន់ខ្ពស់

| ល.រ. | ឈ្មោះ | មុខតំណែង |
|---|---|---|
| 1 | អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ |
| 2 | លោក គួច ផល | អភិបាលប្រតិបត្តិ និងទីប្រឹក្សាជាន់ខ្ពស់ |
| 3 | លោក គួច អាឡិច | អភិបាលប្រតិបត្តិ និងទីប្រឹក្សាជាន់ខ្ពស់ |
| 4 | លោកជំទាវ អ៊ឹង លីហុង | អភិបាលប្រតិបត្តិ |
| 5 | លោក សួង ចន្ថាត | នាយកប្រតិបត្តិការជាន់ខ្ពស់ នៃការិយាល័យប្រតិបត្តិការ |
| 6 | លោក ឡាយ សុភា | ប្រធាន នៃ Aii |
| 7 | អ្នកស្រី រស់ យាណា | ប្រធាន នៃ AIS |
| 8 | លោក វង្ស សុវណ្ណារ័ត្ន | នាយករដ្ឋបាល |
| 9 | លោក សារ៉េត ញាណបញ្ញា | នាយកហិរញ្ញវត្ថុជាន់ខ្ពស់ |
| 10 | លោក តាំង សំអៀង | នាយកផ្នែកព័ត៌មានវិទ្យា |
| 11 | អ្នកស្រី ញ៉ូវ សុខាវត្តី | នាយកផ្នែកធនធានមនុស្ស |
| 12 | កញ្ញា ស្រេង លាភា | ប្រធានបុគ្គលិក និងលេខាធិការក្រុមហ៊ុន |
| 13 | លោក សេង យូសាន | នាយកសវនកម្មផ្ទៃក្នុង |

ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងភាគហ៊ុនិក អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវបានបង្ហាញនៅក្នុងផ្នែកទី5 នៃឯកសារផ្តល់ព័ត៌មាននេះ។

## 1.4. ព័ត៌មានហិរញ្ញវត្ថុ

### 1.4.1 របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ

ខាងក្រោមនេះគឺជាតារាងសង្ខេបនៃរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗដែលបានធ្វើសវនកម្មរួចរាល់របស់ក្រុមហ៊ុនសម្រាប់ FYE 2020, FYE 2021, FPE 2021 និង FPE 2022។ របាយការណ៍ចំណូលលម្អិតនេះ គឺសម្រាប់តែគោលបំណងក្នុងការបង្ហាញតែប៉ុណ្ណោះ។ វិនិយោគិនត្រូវអានដោយលម្អិតជាមួយនឹងការកំណត់ចំណាំ និងការសន្និដ្ឋាន ព័ត៌មានភ្ជាប់នៅក្នុងរបាយការណ៍គណនេយ្យករ ដូចបង្ហាញនៅក្នុងផ្នែកទី 9 នៃឯកសារផ្តល់ព័ត៌មាននេះ។

| | | FYE 2020 | | FYE 2021 | | FPE 2021 | | FPE 2022 |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូល | 15,583,357 | 63,081,429 | 16,342,746 | 66,580,347 | 13,030,486 | 52,981,956 | 19,260,542 | 79,757,904 |
| ថ្លៃដើមនៃការលក់ និងសេវាកម្ម | (4,948,804) | (20,032,759) | (6,205,404) | (25,280,816) | (5,079,556) | (20,653,475) | (7,352,856) | (30,448,177) |
| **ប្រាក់ចំណេញដុល** | **10,634,553** | **43,048,670** | **10,137,342** | **41,299,531** | **7,950,930** | **32,328,481** | **11,907,686** | **49,309,727** |
| ចំណូលផ្សេងៗ | 120,725 | 488,695 | 204,114 | 831,560 | 126,298 | 513,528 | 162,733 | 673,877 |
| ចំណាយរដ្ឋបាល | (6,857,177) | (27,757,852) | (7,393,514) | (30,121,176) | (6,025,922) | (24,501,399) | (8,413,283) | (34,839,405) |
| **ចំណេញពីប្រតិបត្តិការ** | **3,898,101** | **15,779,153** | **2,947,942** | **12,009,915** | **2,051,306** | **8,340,610** | **3,657,136** | **15,144,199** |
| ចំណូលហិរញ្ញវត្ថុ | 116,643 | 472,171 | 179,958 | 733,149 | 132,699 | 539,544 | 148,421 | 614,611 |
| ចំណាយហិរញ្ញវត្ថុ | (2,877,706) | (11,648,954) | (3,081,552) | (12,554,243) | (2,572,820) | (10,461,086) | (2,828,425) | (11,712,508) |
| **ចំណេញ/(ខាត)មុនបង់ពន្ធ** | **1,137,038** | **4,602,730** | **46,348** | **188,821** | **(388,815)** | **(1,580,922)** | **977,132** | **4,046,302** |
| ចំណាយពន្ធ | - | - | - | - | - | - | - | - |
| **ប្រាក់ចំណេញ/(ខាត)ក្នុងគ្រា/ឆ្នាំ** | **1,137,038** | **4,602,730** | **46,348** | **188,821** | **(388,815)** | **(1,580,922)** | **977,132** | **4,046,302** |
| សរុបចំណូលលម្អិតផ្សេងៗសុទ្ធនៃពន្ធ | - | - | - | - | - | - | - | - |





| | | FYE 2020 | | FYE 2021 | | FPE 2021 | | FPE 2022 |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ចំណូល/(ខាត)លម្អិតសរុបក្នុងគ្រា/ឆ្នាំ** | **1,137,038** | **4,602,730** | **46,348** | **188,821** | **(388,815)** | **(1,580,922)** | **977,132** | **4,046,302** |

### 1.4.2. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

ខាងក្រោមនេះ ជាតារាងសង្ខេបនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរាល់របស់ក្រុមហ៊ុនយើង សម្រាប់ FYE 2020, FYE 2021 និង FPE 2022។ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនេះ គឺសម្រាប់តែគោលបំណងបង្ហាញតែប៉ុណ្ណោះ។ វិនិយោគិនត្រូវអានដោយលម្អិតជាមួយនឹងការកំណត់ចំណាំ និងការសន្និដ្ឋាន ដែលមានភ្ជាប់នៅក្នុងរបាយការណ៍គណនេយ្យករ ដូចមានបង្ហាញនៅក្នុងផ្នែកទី 9 នៃឯកសារផ្តល់ព័ត៌មាននេះ។

| | | FYE 2020 | | FYE 2021 | | FPE 2022 |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | 27,432,540 | 111,046,922 | 26,686,880 | 108,722,349 | 27,766,341 | 114,980,418 |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | 18,824,770 | 76,202,669 | 17,883,408 | 72,857,004 | 29,513,056 | 122,213,565 |
| ទ្រព្យសកម្មអរូបី | 45,951 | 186,010 | 33,126 | 134,955 | 50,870 | 210,653 |
| | **46,303,261** | **187,435,601** | **44,603,414** | **181,714,308** | **57,330,267** | **237,404,636** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | | |
| សន្និធិ | 1,025,786 | 4,152,382 | 1,352,942 | 5,511,886 | 1,521,359 | 6,299,948 |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | 2,742,260 | 11,100,668 | 3,487,796 | 14,209,281 | 5,974,306 | 24,739,601 |

| | | FYE 2020 | | FYE 2021 | | FPE 2022 |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | 6,854,311 | 27,786,731 | 6,882,732 | 28,040,250 | 8,576,433 | 35,515,009 |
| | **10,632,357** | **43,039,781** | **11,723,470** | **47,761,417** | **16,072,098** | **66,554,558** |
| **ទ្រព្យសកម្មសរុប** | **56,935,618** | **230,475,382** | **56,326,884** | **229,475,725** | **73,402,365** | **303,959,194** |
| **មូលធន និងបំណុល** | | | | | | |
| **មូលធន** | | | | | | |
| ដើមទុន | 5,005,000 | 20,260,240 | 5,005,000 | 20,390,370 | 5,005,000 | 20,725,705 |
| ចំណេញរក្សាទុក | 13,082,990 | 52,959,944 | 12,097,314 | 49,284,457 | 11,642,422 | 48,211,270 |
| **មូលធនសរុប** | **18,087,990** | **73,220,184** | **17,102,314** | **69,674,827** | **16,647,422** | **68,936,975** |
| **បំណុលរយៈពេលវែង** | | | | | | |
| ប្រាក់កម្ចី | 11,317,525 | 45,813,341 | 10,474,069 | 42,671,357 | 9,006,674 | 37,296,637 |
| បំណុលភតិសន្យា | 20,381,604 | 82,504,733 | 20,432,256 | 83,241,011 | 32,787,443 | 135,772,801 |
| | **31,699,129** | **128,318,074** | **30,906,325** | **125,912,368** | **41,794,117** | **173,069,438** |
| **បំណុលរយៈពេលខ្លី** | | | | | | |
| ប្រាក់កម្ចី | 1,327,161 | 5,372,348 | 1,771,676 | 7,217,808 | 2,205,722 | 9,133,895 |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីត្រូវបង់ផ្សេងៗ | 881,706 | 3,569,146 | 829,849 | 3,380,805 | 1,246,636 | 5,162,320 |
| បំណុលភតិសន្យា | 69,004 | 279,328 | 54,486 | 221,976 | 74,251 | 307,473 |
| កិច្ចសន្យាបំណុល | 4,870,628 | 19,716,302 | 5,662,234 | 23,067,941 | 11,434,217 | 47,349,093 |





| | | FYE 2020 | | FYE 2021 | | FPE 2022 |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| | **7,148,499** | **28,937,124** | **8,318,245** | **33,888,530** | **14,960,826** | **61,952,781** |
| **បំណុលសរុប** | **38,847,628** | **157,255,198** | **39,224,570** | **159,800,898** | **56,754,943** | **235,022,219** |
| **មូលធន និងបំណុលសរុប** | **56,935,618** | **230,475,382** | **56,326,884** | **229,475,725** | **73,402,365** | **303,959,194** |

ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនយើងត្រូវបានបង្ហាញនៅក្នុងផ្នែកទី7 នៃឯកសារផ្តល់ព័ត៌មាននេះ។

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

## 4.3. រចនាសម្ព័ន្ធក្រុមហ៊ុន

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។ ប្រធានក្រុមប្រឹក្សាភិបាល/អគ្គនាយកប្រតិបត្តិ គណៈគ្រប់គ្រងជាន់ខ្ពស់ និងប្រធានផ្នែកបានចូលរួមក្នុងតួនាទីជាអ្នកដឹកនាំ មើលការខុសត្រូវក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម÷



# ឧបសម្ព័ន្ធទី២
# គោលការណ៍ណែនាំស្តីពីការកំណត់ថ្លៃលក់មូលបត្រ និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០១០/១៩ គ.ម.ក./[illegible]

ថ្ងៃ[illegible] ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៩

# គោលការណ៍ណែនាំ
## ស្ដីពី
## ការកំណត់ថ្លៃលក់មូលបត្រ និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

អនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០៥/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យការអនុវត្តប្រកបដោយរលូន និងមានប្រសិទ្ធភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) សូមចេញគោលការណ៍ណែនាំស្ដីពីការកំណត់ថ្លៃលក់មូលបត្រ និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដូចខាងក្រោម៖

ក្រុមហ៊ុនបោះផ្សាយមូលបត្រអាចធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី៖

១-ដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រ និងឯកសារផ្ដល់ព័ត៌មាន តាមការកំណត់របស់ **គ.ម.ក**។

២-រៀបចំលក្ខខណ្ឌនៃសំណើលក់ រួមមានទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

៣-បានទទួលការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក** លើពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្ដល់ព័ត៌មាន ព្រមទាំងលក្ខខណ្ឌនៃសំណើលក់។

ករណីក្រុមហ៊ុនបោះផ្សាយមូលបត្របានដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រ និងឯកសារផ្ដល់ព័ត៌មាន ដែលបានបំពេញតាមលក្ខខណ្ឌតម្រូវ តែមិនទាន់បានបំពេញនូវលក្ខខណ្ឌនៃសំណើលក់ រួមមានទាំងការកំណត់ថ្លៃលក់មូលបត្រដែលទទួលបានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រនោះទេ អគ្គនាយកនៃ **គ.ម.ក** អាចពិនិត្យផ្ដល់ការអនុញ្ញាតជាគោលការណ៍ជូនក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ប៉ុន្តែករណីក្រុមហ៊ុន

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

បោះផ្សាយមូលបត្របានដាក់ពាក្យស្នើសុំ និងឯកសារផ្តល់ព័ត៌មាន ដែលបំពេញតាមលក្ខខណ្ឌតម្រូវ និងលក្ខខណ្ឌនៃសំណើលក់ រួមមានទាំងថ្លៃលក់មូលបត្រដែលទទួលបានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្ររួចហើយ អគ្គនាយកនៃ **គ.ម.ក.** អាចពិនិត្យសម្រេចផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដើម្បីឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រធ្វើសំណើលក់មូលបត្រជាសាធារណៈ។

ចំពោះការកំណត់ថ្លៃលក់មូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវកំណត់ថ្លៃលក់មូលបត្រ ដែលអាចធ្វើឡើងតាមរយៈប៊ុកបៀលឌីង ឬតាមការសម្រេចផ្សេងពីនេះ ដោយអគ្គនាយកនៃ **គ.ម.ក.** តាមសំណើសុំរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

## I- ការកំណត់ថ្លៃលក់មូលបត្រ និងការធ្វើបរិវិសកម្មមូលបត្រតាមយន្តការប៊ុកបៀលឌីង

### ក. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈការធ្វើប៊ុកបៀលឌីង

១.-បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីអគ្គនាយកនៃ **គ.ម.ក.** លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ការកំណត់ថ្លៃលក់មូលបត្រតាមរយៈការធ្វើប៊ុក-បៀលឌីងត្រូវប្រកាសផ្សព្វផ្សាយដើម្បីអញ្ជើញវិនិយោគិនឱ្យចូលរួមយ៉ាងសកម្ម។

២.-ដើម្បីជំរុញឱ្យវិនិយោគិនចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាថាថ្លៃមូលបត្រកម្មសិទ្ធិបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីងមានចំនួន ៧០(ចិតសិប) ភាគរយនៃមូលបត្រកម្មសិទ្ធិសរុបដែលនៅសល់បន្ទាប់ពីការលៃបម្រុងទុកសម្រាប់បុគ្គលិក ករណីក្រុមហ៊ុនបោះផ្សាយមូលបត្រមានគោលនយោបាយលើកទឹកចិត្តតាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ដោយឡែក មូលបត្រកម្មសិទ្ធិដែលនៅសល់ចំនួន ៣០ (សាមសិប) ភាគរយទៀត ត្រូវលៃបម្រុងទុកសម្រាប់ការធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។ ក្រុមហ៊ុនបោះផ្សាយមូលបត្រអាចស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីកំណត់ទំហំមូលបត្រកម្មសិទ្ធិផ្សេងពីការកំណត់ខាងលើ។

៣.-វិនិយោគិនដែលចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិក្នុងឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងចង់ធ្វើបរិវិសកម្ម។

៤.-វិនិយោគិនដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីងត្រូវតម្កល់ប្រាក់កក់យ៉ាងតិចស្មើនឹង ១០ (ដប់) ភាគរយនៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង ឬតាមការកំណត់ដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សា

ហិរញ្ញវត្ថុ និងមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។ ប្រាក់កក់នេះត្រូវរក្សាទុកក្នុងគណនីដាច់ដោយឡែករបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៥.-ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវកំណត់ថ្លៃលក់មូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដោយត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ ដើម្បីស្នើសុំការសម្រេចពីអគ្គនាយកនៃ **គ.ម.ក.** ដោយភ្ជាប់មកជាមួយបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀល-ឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ។ វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃស្មើ ឬខ្ពស់ជាងថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់។ ថ្លៃលក់មូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ត្រូវគណនាដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted-Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនគុណវុឌ្ឍិបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង។ ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនានេះអាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការ និងស្ថានភាពទីផ្សារ ដោយមានការសម្រេចពីអគ្គនាយកនៃ **គ.ម.ក.**។

៦.-ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ បន្ទាប់ពីអគ្គនាយកនៃ **គ.ម.ក.** បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុម-ហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវផ្ទេរប្រាក់កក់ទាំងអស់ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោគិនមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងមានបំណងបន្តធ្វើបរិវិសកម្ម។

**ខ. ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិតាមយន្តការកំណត់ថ្លៃលក់មូលបត្រតាមប៊ុកបៀលឌីង**

៧.-វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិលើសពីចំនួនដែលបានដាក់ក្នុងពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង ដោយត្រូវតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។

៨.-វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្ម អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់បន្ថែមដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។

៩.-វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់ ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម ដែល

ប្រាក់តម្កល់នេះត្រូវរក្សាទុកក្នុងគណនីដាច់ដោយឡែករបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រនៅធនាគារពាណិជ្ជ ដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

១០.-វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលនឹង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្ម វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលនឹង ហើយមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងដកប្រាក់កក់ទាំងអស់វិញបាន ដែលអាចធ្វើបានតែក្នុងករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលនឹងបានធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលនឹង។

១១.-ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលនឹងមានចំនួនលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលនឹង ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម តាមវិធានប្រូរ៉ាតា (Pro rata)។

១២.-ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលនឹងមានចំនួនច្រើនលើសលប់ ហើយបានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិក្នុងចំនួនច្រើនលើសលប់លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលនឹង ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ អាចស្នើសុំមកអគ្គនាយកនៃ **គ.ម.ក.** ដើម្បីពិនិត្យសម្រេចធ្វើការបែងចែកក្នុងចំនួនមិនលើសពី ២/៣ (ពីរភាគបី) នៃមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបម្រុងទុកសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលនឹង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលនឹង ហើយផ្ទេរទៅបន្ថែមក្នុងចំណែកនៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលនឹង ដើម្បីបែងចែកជូនដល់វិនិយោគិនដែលបានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងចំនួនច្រើនលើសលប់នោះតាមវិធានប្រូរ៉ាតា។

១៣.-បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិតាមការដាក់ពាក្យស្នើសុំ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវផ្ទេរសាច់ប្រាក់ដែលនៅសល់ពីការធ្វើបរិវិសកម្មជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធនោះវិញ។

១៤.-ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលនឹង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយការធ្វើបរិវិសកម្មនេះមានចំនួនតិចជាងចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលនឹង វិនិយោគិនទាំងអស់ដែលទទួលបានជោគជ័យក្នុងប៊ុកបៀលនឹងត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់។

១៥.-ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងមានចំនួនតិចជាងចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងតាមការស្នើសុំ។ ចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់ត្រូវធ្វើការបែងចែកទៅឱ្យវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

១៦.-ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបម្រុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមវិធានប្រូរ៉ាតា។

១៧.-ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង មានចំនួនទាបជាងចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបម្រុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមការស្នើសុំធ្វើបរិវិសកម្ម ហើយមូលបត្រកម្មសិទ្ធិដែលនៅសល់ត្រូវបែងចែកទៅឱ្យវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង នៅក្នុងករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងបានធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវលៃបម្រុងទុកសម្រាប់ការធ្វើប៊ុកបៀលឌីង។

១៨.-ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដូចមានចែងក្នុងគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាទិញមូលបត្រត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀងជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ។

១៩.-ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន **គ.ម.ក.** ភ្លាម ដើម្បីសុំការពិនិត្យ និងសម្រេច។

## II- ការកំណត់ថ្លៃលក់មូលបត្រ និងការធ្វើបរិវិសកម្មមូលបត្រតាមយន្តការផ្សេងពីការធ្វើប៊ុកបៀលឌីង

១.-ករណីក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ស្នើសុំកំណត់ថ្លៃលក់មូលបត្រផ្សេងពីការធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវស្នើសុំការសម្រេចជាមុនពីអគ្គ-

នាយកនៃ **គ.ម.ក.** លើយន្តការនៃការកំណត់ថ្លៃលក់មូលបត្រផ្សេងនោះ ដោយភ្ជាប់មកជាមួយនូវយន្តការ និងព័ត៌មានលម្អិតពីការកំណត់ថ្លៃលក់មូលបត្រនោះ។

២.-បន្ទាប់ពីក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ធ្វើការកំណត់ថ្លៃលក់មូលបត្ររួចហើយ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវបញ្ជាក់ការយល់ព្រមលើការកំណត់ថ្លៃលក់នោះពីប្រតិបត្តិករទីផ្សារមូលបត្រ និងស្នើសុំការសម្រេចពីអគ្គនាយកនៃ **គ.ម.ក.**។

៣.-វិនិយោគិនអាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់ ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម ដែលប្រាក់តម្កល់នេះត្រូវរក្សាទុកក្នុងគណនីដាច់ដោយឡែករបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រនៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៤.-ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្មដោយវិនិយោគិនមានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិដែលស្នើសុំបោះផ្សាយ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមវិធានប្រូរ៉ាតា។

៥.-ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដូចមានចែងក្នុងគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាទិញមូលបត្រត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀងជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ។

៦.-ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ/ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន **គ.ម.ក.** ភ្លាម ដើម្បីសុំការពិនិត្យ និងសម្រេច។

គោលការណ៍ណែនាំនេះ ត្រូវជំនួសគោលការណ៍ណែនាំលេខ ០០២/១២ គ.ម.ក/គ.ណ.ន ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ។

**គណៈកម្មការមូលបត្រកម្ពុជា**

# ឧបសម្ព័ន្ធទី៣
# គំរូនៃសេចក្តីជូនដំណឹងពីការបែងចែកភាគលាភប្រចាំឆ្នាំរបស់ក្រុមហ៊ុន
# ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MJQ
MENGLY J. QUACH EDUCATION

**ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក**

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបែងចែកភាគលាភ

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ("ក្រុមហ៊ុន") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក ទាំងអស់ឱ្យបានជ្រាបថា យោងតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក លើកទី១ នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ក្រុមហ៊ុន សម្រេចធ្វើការបែងចែកភាគលាភ សម្រាប់ប្រាក់ចំណេញក្នុងឆ្នាំ២០២៣ ជូនដល់ភាគហ៊ុនិកជាសាធារណជនរបស់ក្រុមហ៊ុន ដូចខាងក្រោម៖

1. ប្រភេទភាគលាភដែលត្រូវបែងចែក : **សាច់ប្រាក់**
2. រយៈពេលនៃភាគលាភ : **ប្រចាំឆ្នាំ**
3. អនុបាត នៃការបែងចែកភាគលាភ : **៧,៦០%**
4. ភាគលាភសរុបដែលត្រូវបែងចែក : **១.៤៥១.០៦៨.០៩១,២០ រៀល**
5. ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : **១៤៥,៦០ រៀល**
6. កាលបរិច្ឆេទអិចឌីវីដង់ : **ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤**
7. កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ : **ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤**

   (កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ)

8. កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ : **ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤**

**បញ្ជាក់៖**

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក (Record Date) នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២៤។
- ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅក្នុងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ នៅតែមានសិទ្ធិទទួលបានភាគលាភនេះដដែល។
- ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅក្នុងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ មិនមានសិទ្ធិទទួលបានភាគលាភនេះទេ។
- ការទូទាត់ភាគលាភចាប់ផ្តើមពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤ នៅរៀងរាល់ថ្ងៃធ្វើការ។

សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត សូមធ្វើការទំនាក់ទំនងទៅកាន់ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមអាសយដ្ឋាន និងលេខទំនាក់ទំនង ដូចខាងក្រោម៖

អាសយដ្ឋានៈ អគារលេខ៦១, មហាវិថីព្រះមុនីវង្ស, សង្កាត់ស្រះចក, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ

១- លោក កែន រិទ្ធពុទ្ធា អ្នកឯកទេសបឋមប្រតិបត្តិការ RTP
ទូរសព្ទៈ (៨៥៥) ១៥ ៨០០ ៦៦៣ និង អ៊ីម៉ែលៈ ken.rithputhea@acledabank.com.kh

២- លោកស្រី សំរិទ្ធ វណ្ណិបុប្ផារដ្ឋ អ្នកឯកទេសបឋមប្រតិបត្តិការ RTP
ទូរសព្ទៈ (៨៥៥) ៧០ ៥០០ ៣៧៧ និង អ៊ីម៉ែលៈ samreth.vannybopharath@acledabank.com.kh

ថ្ងៃអង្គារ ៧ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤

**ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក**

# ឧបសម្ព័ន្ធទី៤

# របាយការណ៍ប្រចាំឆ្នាំ២០២៣របស់

# ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន

# ម.ក

MJQ
MENGLY J. QUACH EDUCATION

# ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក

# របាយការណ៍ប្រចាំឆ្នាំ

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣





# ក្រុមប្រឹក្សាភិបាល



អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី
ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ



លោក គួច ផល
អភិបាលប្រតិបត្តិ



លោក គួច អាឡិច
អភិបាលប្រតិបត្តិ



លោកជំទាវ អ៊ឹង លីហុង
អភិបាលប្រតិបត្តិ



លោក គង់ វ៉ាប៉ា
អភិបាលឯករាជ្យ



# ផ្នែកទី ៤. ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់ក្រុមហ៊ុន ម៉េងលី ជេ.គួច អេឌ្យូខេសិន ម.ក

## ក-ព័ត៌មានអំពីមូលបត្រ

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនធម្មតា |
| និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ | MJQE |
| ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ២០០ រៀល |
| ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ២.០៨០ រៀល |
| បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងចរាចរលើទីផ្សារ | ៣២៤.០៥៩.៥២៧ ភាគហ៊ុន |
| មូលធននូបនីយកម្មទីផ្សារ | ៦៩០.២៤៧ លានរៀល |
| ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា |
| កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ | ២៨ មិថុនា ២០២៣ |

# ឧបសម្ព័ន្ធទី៥
# ពាក្យស្នើសុំធ្វើបរិវិសកម្ម

*ឯកជន និងសម្ងាត់*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ជម្រាបជូន**

**លោកអគ្គនាយកក្រុមហ៊ុន**

**អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក**

**កម្មវត្ថុ៖ ការបង្ហាញចំណាប់អារម្មណ៍ និងការស្នើសុំលៃបម្រុងទុកជាមុន នូវភាគហ៊ុនរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក ("ម៉េងលី ជេ. គួច អេឌ្យូខេសិន") សម្រាប់សំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ("សំណើ IPO") និងការចុះបញ្ជីរបស់ ម៉េងលី ជេ. គួច អេឌ្យូខេសិន ក្នុងទីផ្សារគោលនៃផ្សារមូលបត្រកម្ពុជា ("ផ.ម.ក")។**

ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសជាលាយលក្ខអក្សរ ពីចំណាប់អារម្មណ៍ និងស្នើសុំសម្រាប់ការលៃបម្រុងទុកនៃភាគហ៊ុនរបស់ ម៉េងលី ជេ. គួច អេឌ្យូខេសិន ដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះវិនិយោគិន | ៖ | .................................. | ឈ្មោះក្រុមហ៊ុនមូលបត្រ | ៖ | .................................. |
| លេខទំនាក់ទំនង | ៖ | .................................. | លេខគណនីជួញដូរ | ៖ | .................................. |
| ទំហំវិនិយោគ (ដុល្លារអាមេរិក)* | ៖ | .................................. | | | |

*សម្គាល់៖ *ទំហំវិនិយោគអប្បបរមា 1,000 ដុល្លារអាមេរិក*

| សូមគូស ✓ ក្នុងប្រអប់ខាងក្រោមបើអ្នកជា៖ | ខ្ញុំបាទ/ នាងខ្ញុំ សូមប្រកាសថា ខ្ញុំបាទ/ នាងខ្ញុំ គឺជាវិនិយោគិនគុណវុឌ្ឍិដោយខ្ញុំមាន៖ |
|---|---|
| ☐ បុគ្គលិករបស់ក្រុមហ៊ុន ម៉េងលី ជេ.គួច អេឌ្យូខេសិន ម.ក<br>☐ ឪពុកម្តាយរបស់សិស្សនៃក្រុមហ៊ុន ម៉េងលី ជេ.គួច អេឌ្យូខេសិន ម.ក, សូមបញ្ជាក់ឈ្មោះសិស្ស៖ ....................................<br>☐ ផ្សេងៗ | ☐ ទ្រព្យសកម្មសុទ្ធសរុប 1,000,000,000 រៀល (ឬ 250,000 ដុល្លារអាមេរិក) ឬ<br>☐ ចំណូលប្រចាំឆ្នាំលើសពី 80,000,000 រៀល (ឬ 20,000 ដុល្លារអាមេរិក) ឬ<br>☐ បានវិនិយោគលើសពី 100,000,000 រៀល (ឬ 25,000 ដុល្លារអាមេរិក) នៅក្នុងផ្សារមូលបត្រ<br>*សូមជ្រើសរើសលក្ខខណ្ឌមួយ (1) យ៉ាងតិចក្នុងចំណោមលក្ខខណ្ឌទាំងបី (3) ខាងលើ* |

សម្រាប់ការបង្ហាញនូវគោលបំណងរបស់ ខ្ញុំបាទ/ នាងខ្ញុំ ក្នុងការស្នើសុំនូវ ភាគហ៊ុន IPO (ដូចដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មាន) ខ្ញុំបាទ/ នាងខ្ញុំ ទទួលស្គាល់ និងយល់ថា មិនមានការធានាថា ភាគហ៊ុន IPO នឹងត្រូវបានបែងចែកស្របទៅតាមសំណើសុំនេះទេ ហើយការបែងចែក នឹងត្រូវបានធ្វើឡើងតាមរយៈការសម្រេចរួមគ្នារវាង ម៉េងលី ជេ. គួច អេឌ្យូខេសិន និងក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក។

បន្ថែមពីលើនេះ ខ្ញុំបាទ/ នាងខ្ញុំ ទទួលស្គាល់ និងយល់ថា សំណើ IPO តម្លៃ IPO និងការលៃបម្រុងទុកនៃភាគហ៊ុន IPO គឺអាស្រ័យ និងស្ថិតនៅក្រោមការអនុម័តពី និយ័តករមូលបត្រកម្ពុជា ("**ន.ម.ក**")។

ខ្ញុំបាទ/ នាងខ្ញុំ សូមប្រកាសថា ព័ត៌មានដែលបានផ្តល់ជូនខាងលើ គឺពិតជាត្រឹមត្រូវ។

សូមផ្ញើរលិខិតបំពេញរួចមកកាន់ ៖

- Telegram: t.me/rhbsec (username: @rhbsec)
- Email: cf.rhbsc@rhbgroup.com.kh

....................................

ហត្ថលេខា ឈ្មោះ និង កាលបរិច្ឆេទ